# ស្តេចកន និង ព្រះចន្ទរាជា : សង្គ្រាមដើម្បីអ្វី ?



ព្រះរាជបុត្រមួយអង្គ

## ភាគទី១ - ភាគទី២

ពិនិត្យឡើងវិញអំពីព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរ

# មាតិការឿង

**ភាគទី១ - ប្រភពដើម នៃជម្លោះ** ____ 1
សេក្តីសង្ខេប ប្រវត្តិសាស្ត្រ ____ 5
រាជ្យ ព្រះបាទ ស្រីសុគន្ធបទ ____ 15
វាសនា របស់ កន ____ 21
ការរត់គេចខ្លួន នៃចៅពញាចន្ទរាជា ____ 45
សង្គ្រាម រវាង កងទ័ពហ្លួង និង ស្តេចកន ____ 55
កត្តាអ្វីខ្លះ ដែលនាំឲស្តេចកន ឈ្នះសង្គ្រាមព្រះសុគន្ធបទ ____ 75
**ភាគទី២ - ផែនដីស្តេចកន** ____ 80
និវត្តន៍ នៃព្រះចន្ទរាជាមកកាន់ស្រុកខ្មែរវិញ ____ 84
តាមឿងបូជាខ្លួន ____ 102
កម្លាំងប្រយុទ្ធ នៃកងទ័ព របស់ព្រះចន្ទរាជា ____ 123
បន្តនៅពេលខាងមុខ ____ 139

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**



បុរសខ្មែរមួយរូប

# ភាគទី១ - ប្រភពដើម នៃឈ្មោះ

## អារម្មណ៍កថា

ប្រវត្តិសាស្ត្រ ស្តេចកន ជា ព្រឹត្តិការណ៍ ដ៏សំខាន់មួយ កើតមាន ឡើង ក្នុង ប្រវត្តិសាស្ត្រខ្មែរ នៅ ក្នុង សតវត្ស ទី១៦។ របបរាជានិយម តែង ទុក ស្តេចកន ជា ជន ក្បត់រាជបល្ល័ង្ក ព្រោះ ជារាស្ត្រ ហ៊ាន ប្រឆាំងនឹង ព្រះមហាក្សត្រ ដណ្តើមរាជ្យ។ តែ ក្នុង អារម្មណ៍ខ្មែរមួយភាគ តែង ទុក ស្តេចកន ជា និមិត្តរូប នៃការតស៊ូរវណ្ណៈ ឬ ជា ប្រជាបះបោរ ប្រឆាំងនឹង របប រាជានិយមផ្តាច់ការ។

នៅក្នុង អត្ថបទ នេះ ខ្ញុំ គ្មាន បំណង យក ព្រឹត្តិការណ៍ ស្តេចកន មក សរសេរ ជា ការសិក្សាប្រវតិសាស្ត្រ នោះឡើយ តែគ្រាន់តែចង់ធ្វើ វិភាគ ចង់ យល់ដឹង អំពី ការពិត ដែលមាន កើតឡើង នៅក្នុង ព្រឹត្តិការណ៍នោះ។ ហេតុនេះឯង ខ្ញុំ សូម អ្នកអាន មេត្តា អភ័យទោស ពី ការសាកល្បងពិចារណានេះ ហើយបើមានការផ្គុំផ្គងត្រង់កន្លែងណាមួយ សូមអោយលោកអ្នកអានជួយបំភ្លឺឬធ្វើការរិះគន់ផងចុះ។

ប្រលោមលោក ប្រវត្តិសាស្ត្រ មាន ច្រើន ខ្លះដែរ នៅ ស្រុកខ្មែរ។ ប្រលោមលោក ដែល ល្បី មួយ នៅ ក្នុង សម័យ កុមារភាពខ្ញុំ គឺរឿង ព្រះចន្ទរាជា និព័ន្ធ ដោយកវី ប៊ិវ ឆៃលាង។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

លោក បាន យក ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ មកតាក់តែង
សេសេរ ជាប្រលោមលោក ទាក់ទាញ អារម្មណ៍អ្នកអានឲ
រស់ នៅក្នុង សាច់រឿង ដូចខ្លួន ជានាដករសកម្មមួយ នោះ
ដែរ។ រឿង ព្រះចន្ទរាជា របស់ កវី បីវ ឆីលាង បង្ហាញ នូវ
រូបភាព ស្តេចកន ជា ជនក្បត់ រាជបល្ល័ង្កល រីឯ ព្រះចន្ទ
រាជា វិញ ជាវិរបុរសជាតិ ដែលជាទស្សនកថា ជា ផ្លូវការនៃ
របប រាជានិយម ដែល ជា របប ដែលអ្នកនិព័ន្ធ រស់នៅ
ក្នុងពេលដែល គាត់ សរសេរប្រលោមលោកនេះ។

ចំពោះ ខ្ញុំ វិញ ខ្ញុំមិនកាន់ជើង ខាងណាឡើយ តែ គ្រាន់តែ
បង្ហាញ តាម ការយល់ឃើញ របស់ខ្ញុំផ្ទាល់ ថា អំពើណាដែល
ជា អំពើ អវិជ្ជមាន និង វិជ្ជមាន សំរាប់ជាតិខ្មែរ របស់ គួរ
ប្រឆាំងគ្នា គឺ ព្រះចន្ទរាជា និង ស្តេចកន តែប៉ុណ្ណោះព្រោះ
ជម្លោះនេះ មាន លក្ខណ: ជា ជម្លោះ រវាងបុគ្គល នឹង
បុគ្គលផង រវាង វណ្ណ: នឹង វណ្ណ:ផង ហើយ ក៏ទុកជា ជម្លោះ
នយោបាយផង។ ហេតុនេះឯង អ្វីដែលខ្ញុំលើកមក បង្ហាញ
វា អាច ជា ចំណុចរសើប ដល់ អ្នកអាន ដែល មាន គោល
និយម លំអៀង ទៅ រក ខាងណាមួយ ដូច្នេះ សូម អ្នកអាន
ទាំងនោះ ទុកការវិភាគ របស់ខ្ញុំ ជា គំនិត អព្យាក្រឹត ឈរ
លើ មូលដ្ឋាន អក្សរសាស្ត្រ គឺ សេរីភាព នៃ ការនិព័ន្ធ សំរាប់
តែ បំរើ វិចិត្រសិល្បះតែប៉ុណ្ណោះ។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

ការវិភាគ នៅ ទីនេះ គឺ ខ្ញុំ យក ឯកសារ លោក អេង សុត ជា មូលដ្ឋាន ដែលមាន ចំណងជើង ថា « មហាបុរសខ្មែរ-ព្រះរាជពង្សាវតាខ្មែរ »។ លោក អេង សុត ជា សមាជិក នៃ គណកម្មការ ប្រវត្តិសាស្ត្រ និង វប្បធម៌ ខ្មែរ។ លោក មាន អាជីព ជា ចៅក្រមប្រឹក្សា សាលាវិនិច្ឆ័យ។ ឯកសារ នេះ លោក បាន ចុះផ្សាយ នៅ ទស្សវត្សរ៍ ៧០។ ឯកសារ នេះ ជា ព្រះរាជពង្សាវតា សុទ្ធសាធ ដែល បុព្វបុរស ខ្មែរយើង លោក បាន សរសេរ ទុក ក្នុង ក្រាំង ក៏ មាន ខ្លះ ចារ លើ ស្លឹករិត ក៏ មាន ខ្លះ ដើម្បី ទុក ជា កេរ្តិ៍ អោយ បច្ឆាជន ដែល កើត ក្រោយ បានដឹង ជាតិកំណើត នៃ ប្រទេស របស់ខ្លួន អោយបានជាក់ច្បាស់ផង។

អត្ថាធិប្បាយទាំងឡាយនៅទីនេះ ជាវិស័យមតិផ្ទាល់ខ្លួន ធ្វើឡើងនៅក្នុងគំនិតវិភាគ ប្រើចំណេះវិទ្យាសាស្ត្រ ដើម្បីឆ្លុះមើលព្រឹត្តិការណ៍ មានកើតឡើង នៅក្នុងខេមរៈសង្គមបុរាណ ដែលខ្មែរយើងទុកជាប្រវត្តិសាស្ត្រជាតិ ក្នុងគោលបំណងបំភ្លឺទីម្លប់មួយចំនួន សំរាប់ចិញ្ចឹមបញ្ញាតែប៉ុណ្ណោះ តែគ្មានគំនិតទម្លាក់ចោល នៃចំណេរ របស់បុព្វបុរសខ្មែរ ដែលលោក ប្រឹងប្រែងកត់ទុក ព្រឹត្តិការណ៍ជាតិទាំងឡាយ នៅក្នុងបរិបទសម័យនោះ ទុកជាមរតក សំរាប់កូនខ្មែរ យកទៅពិចារណាបន្ថែម ដើម្បីធ្វើឱ្យមរតកនោះ ក្លាយជាគំនិតជាតិ ជាឋាមភាពដល់សង្គមខ្មែរ។ ពិតណាស់ហើយ

ថា គេមិនទុកប្រវត្តិសាស្ត្រ ជាមេរៀនដាច់ខាតនោះទេ តែវាជាជំនួយសំរាប់ប្រជាជាតិមួយ ឆ្លុះមើលលើខ្លួនឯង នៅក្នុងសម័យមួយ នៅក្នុងបរិបទមួយ នៃជីវិតជាតិ របស់ខ្លួន ហើយមានបន្តៗ រហូតរៀងមក។ ដូច្នេះ ការប្រមូលផ្តុំនៃព្រឹត្តិការណ៍ជាតិ ដែលមានកើតកន្លងមក វាជាឃ្លាំងនៃបញ្ញាខ្មែរម្នាក់ៗផង, បញ្ញាជាតិផង ហើយ ក៏មានព្រឹត្តិការណ៍ ជាហានភាគិយ[1] ដល់ជាតិផង។ នៅពេលណាដែលប្រជាជាតិ បាត់ស្មារតីជាសម្គាល់ នូវគ្រោះជតិ វាច្បាស់ជាប្រជាជាតិនោះមិនរឹងប៉ឹងនោះឡើយ។

---

[1] ហានភាគិយ : ដែលបានតែខាងវិនាស ឬ មិនចម្រើន។



ចៅហ្វាយស្រុកម្នាក់

# សេក្តីសង្ខេប ប្រវត្តិសាស្ត្រ

ការលើកផែនដី ព្រះបាទពញាយ៉ាត(១៣៨៤-១៤២៧) ក្នុងសតវត្ស ទី១៤ និង ទី១៥ មកសង្ខេប ជាកញ្ចក់មួយ សំរាប់យល់ដឹង អំពី ស្ថានភាព នយោបាយ សំខាន់ៗ នៅ ស្រុកខ្មែរ ដែល ជា យុគថ្មី នៃ របប ដឹកនាំជាតិ ផ្តាច់ ពីសម័យអង្គរមកសម័យកម្ពុជាថ្មី។ ព្រះបាទពញាយ៉ាតជា និមិត្តរូបនៃមហាក្សត្រដៃ ព្រោះ ទ្រង់ជាអ្នករំដោះជាតិ ពីការត្រួត្រាសៀម តែព្រះអង្គ ក៏ ជា អ្នកបង្កើត សន្តរាជវង្សខ្មែរថ្មី បោះបង់ មហានគរ មកតាំងទីថ្មី កសាង ព្រះរាជវាំង នៅក្នុង ខេត្ត ស្រីសន្ធរ[2] ក្នុងឆ្នាំ ១៣៩២។ ការផ្ទេររាជធានី នេះ ជា យុទ្ធសាស្ត្រ យោធាផង ជា និមិត្តរូប សំខាន់ នៃ ការផ្តាច់ ពី សន្តរាជវង្ស អង្គរផង។

ទី១. ជា យុទ្ធសាស្ត្រ យោធា ព្រោះ មហានគរ ស្ថិត នៅ ក្បែរព្រំប្រទល់ ខ្មែរ-សៀម ព្រោះ ខែត្រខ្មែរ ជា ច្រើន នៅ ទិសខាងកើត នៅ ក្បែរ មហានគរ បាន ធ្លាក់ ក្នុង ការកាន់កាប់ សៀម ដូច្នេះ សៀម ងាយ ស្រួល វាយ ចូល មហានគរ

[2] ខេត្ត ស្រីសន្ធរ ដើមឡើយឈ្មោះខេត្ត បាសាន។ (ស្រីសន្ធរ ជាពាក្យយារពី ស្រីសឈរ)។

និព័ន្ធដោយ ឧប សៅ សង្ហា
ឆ្នាំ ២០១៥

ណាស់ ហេតុនេះឯងហើយ បាន ជា ព្រះបាទ ពញាយ៉ាត ទ្រង់ ផ្ទេរ រាជធានី ដោយ យក «ចម្ងាយ និង រយៈពេល» ធ្វើជា របបង ការពារ ជាចម្បជាតិ នៃទីបញ្ជាការយោធា និង នយោបាយ របស់ប្រទេសៈ ឈរលើ ចម្ងាយ គឺ តម្រូវ អោយ ខ្មាំង ប្រើ ពេល វេលាយូរ លើក ទ័ពមក វាយ រាជធានី ហើយ រយៈពេល យូរនេះ ដែលអាច អោយ ព្រះអង្គ មាន លទ្ធភាព កែន កងទ័ព អោយបានទាន់ពេលវេលា ដើម្បី តតាំងនឹងខ្មាំង។ យុទ្ធសាស្ត្រនេះ ផ្អែកទៅ លើ ការការពារ សុទ្ធសាធ ដែល បើក ឱកាស អោយ ខ្មាំងយក ទឹកដីជាតិ ធ្វើ ជាសមរភូមិ នាំបង្កើតអសន្តិសុខ រំខាន ឬ បំផ្លាញដល់ សេដ្ឋកិច្ចជាតិ ដែល ជាដង្ហើម នៃ ប្រជាជាតិ និង អាយុជីវិត នៃកងទ័ពជាតិ ដូចសុភាសិតខ្មែរ ថ្លែងថា «ធ្វើ ស្រែ នឹងទឹក ធ្វើ សឹកនឹងបាយ»។ ចំណុចមួយទៀត គឺ នៅត្រង់ ថា ជ័យជំនះ ព្រះបាទពញាយ៉ាត លើសៀម គឺ ឈ្នះ លើតែ កងទ័ពសៀម ដែល មក តាំងទីនៅក្នុង មហានគរ តែប៉ុណ្ណោះ ហើយ រំដោះបានរាជធានីខ្មែរ តែមិនមែន ជា ជ័យជំនះ លើប្រទេសសៀមនោះឡើយ ជាពិសេស ខែត្រខ្មែរ ទាំងឡាយ ដែលសៀម វាយ យក បាន ព្រះបាទពញាយ៉ាត មិនមានលទ្ធភាពរំដោះបាន វិញនោះទេ។ ហេតុនេះឯង បានជា ព្រះបាទពញាយ៉ាត មានការបារម្ភជានិច្ច ដល់ការសងសឹងពីព្រះចៅសៀម មក លើរូប

ព្រះអង្គ ដែល ជា អ្នកទទួលខុសត្រូវ លើមរណភាពនៅក្នុង សង្គ្រាម របស់រាជបុត្រ នៃព្រះចៅសៀម ដែល ព្រះអង្គ ទុក អោយ នៅ គ្រងនៅ ក្រុងកម្ពុជា។

ទី២. ជា ការកាត់ផ្តាច់ ពី សន្តរាជវង្សអង្គរ ព្រោះ រាជវង្ស នេះ លែងមានរូបភាព ជា រាជវង្ស ឧត្តុងឧត្តម សំរាប់ជាតិ ខ្មែរ ទៀតហើយ ព្រោះជា សន្តរាជវង្សព្រហ្មញ្ញនិយម ដែល មិនមែន ជាការនិយម របស់ប្រជារាស្ត្រខ្មែរ។ ការប្តូរនោះ មាន តាំង ពី រាជ្យ ព្រះបាទ តាត្រសក់ផ្អែម មកម្លេះ។ នៅ ក្នុង សម័យ នោះ មាន កើត បដិវត្តន៍ នៅ ក្នុង វណ្ណៈ អ្នក ដឹកនាំ រហូតធ្វើឃាត ព្រះមហាក្សត្របចុង ក្រោយ បង្អស់ នៃ សន្តរាជវង្សអង្គរ ព្រះនាមព្រះបាទ សេណករាជ ដើម្បី លើក ពុទ្ធសាសនា ជា សាសនាជាតិ អោយ ស្របនឹង ចំណុច ចិត្ត ប្រជារាស្ត្រ ដែលជាអ្នកកាន់ ពុទ្ធសាសនា។ តាត្រសក់ផ្អែម[3] ត្រូវ បាន នាម៉ឺនមន្ត្រីព្រះរាជវាំង លើក តាំង ជាមហាក្សត្រ ខ្មែរ ព្រោះគាត់ជាមនុស្ស មានសេចក្តីក្លាហានហ៊ាន ប្រហារ ជីវិត ព្រះមហាក្សត្រ។ ពួកទាំងនោះ នាំគ្នា ថ្វាយឃាតកម្ម

[3] ព្រះនាមជាព្រះមហាក្សត្រ គឺ ព្រះរាជឱង្ការ ព្រះបរមរាជាធិរាជ ជ័យ។

នោះជា អំពើអចេតនា ទុកជា កម្មផល របស់ ព្រះបាទ សេណករាជ។ រីឯឃាតករ វិញ ត្រូវបាន ទទួល ផលកុសល ព្រោះ ខ្លួនបាន បំពេញ ករណីយកិច្ច របស់ខ្លួនតាមរាជបញ្ញា។ ម្យ៉ាងមួយទៀត តាត្រសក់ផ្អែម ជា អ្នក កាន់ពុទ្ធសាសនាបរិសុទ្ធ គាត់ មានប្រាជ្ញា ភ្លឺថ្លា មោះមុតជាអ្នកនិព័ន្ធរឿងល្ខោន ប្រកប ដោយ គុណភាព គួរ មើលកំសាន្តព្រោះជា ទស្សនីយភាព ដ៏ អស្ចារ្យ។ ត្រង់ ចុះណុច នេះ គេសួរ ជាសំណួរ បានថា តើ តាត្រសក់ អាច ជា អ្នកដឹកនាំរឿង ពិឃាត ព្រះបាទសេណករាជ បានដែរឬទេ ?ចម្លើយឆ្លើយថា បាន។ ហេតុ អ្វី ក៏ ធ្វើ មិនបាន បើ លើក យកឃាតកម្មសុក្រឹតនេះ មក ពិចារណា បន្តិច វា មាន រូបភាពដូច ជា រឿងល្ខោន ដែលគេរៀបចំឡើង។

ទី៣. ចំពោះ អ្នកស្រាវជ្រាវបរទេស គេ យល់ ឃើញថា វិបត្តវារី ជា កត្តាចម្បង ដែលនាំអោយ ព្រះបាទ ពញាយ៉ាតបោះបង់ មហានគរ ព្រោះ វិបត្តុ នោះ នាំ បង្កើត នូវបញ្ហាសេដ្ឋកិច្ច សំរាប់ ចិញ្ចឹម ជីវិត។ ប្រជាជន រស់ នៅក្នុង មហានគរ ជួបប្រទះនឹង វិបត្ត របបចិញ្ចឹមវិត កើតមកពី កង្វះទឹក ព្រោះ ប្រឡាយទឹក បង្ហូរទឹក ពីទន្លេសាបមក បំពេញបារាយទឹក សំរាប់ ធ្វើ ស្រែ និង សេចក្ដីត្រូវការសំរាប់ ការរស់នៅ ជា ធម្មតា របស់ប្រជាជន វាខូចខាត ព្រោះ គ្មានការថែរក្សា ឲបាន ដិតដល់។ រឿង នេះ មាន ហេតុផល ជា

ច្រើន ជា អាថ៌ គឺ ខ្វះ ធនធាន មនុស្ស ព្រោះ សង្គ្រាមជំរុញ អោយ ប្រជាជន រត់ភៀសខ្លួន ចេញ ពី ដំបន់ មហានគរ ព្រោះ ខ្លាចអាថ្វាធរ កេណ្ឌធ្វើទាហាននិង ខ្លាចសៀម ចាប់ បញ្ជូនទៅ ស្រុកគេ ចោល ស្រុកឯង។

## សង្ខេប ប្រវត្ត នៃ សន្តរាជវង្ស ព្រះបាទ ពញាយ៉ាត

ព្រះបាទ ពញាយ៉ាត មាន ព្រះរាជបុត្រា និង បុត្រី ជាច្រើន តែ បុត្រាមកុដ មានបី អង្គ ដែល មាន ស្នាម ព្រះនាម នៅ ក្នុងប្រវត្តិសាស្ត្រគឺៈ **ព្រះនរាយណ៍រាជា**[4] (សម្គាពនឹង អ្នកម្នាងទេវី) **ព្រះសេរីរាជា**[5] (សម្គាពនឹង អ្នកម្នាងបទុមកេសរ) **ព្រះធម្មរាជា** (សម្គាពនឹង ព្រះម្នាង ស៊ីសាងាម) ជាស្នំឯក។ ព្រះម្នាង ស៊ីសាងាម ជា អតិត ព្រះម្នាង របស់ព្រះឥន្ទរាជា (១៣៨០) ដែលជា កូន ស្តេចសៀម ព្រះនាម ព្រះបរមរា។ ព្រះឥន្ទរាជា ជារាជបុត្រ ទី៣ ដែលព្រះចៅសៀម ទុកឲនៅ

---

4 ព្រះនរាយណ៍រាជា មានព្រះរាជបុត្រាមួយព្រះអង្គ ទ្រង់ព្រះនាម ព្រះសុរិយោទ័យ។ នៅក្នុងរាជ្យ ព្រះសេរីរាជា ជា ព្រះអនុជ របស់ព្រះបិតា របស់ទ្រង់ ហើយឡើងសោយរាជ្យស្នងព្រះជេដ្ឋា ដែលក្រោយមកទ្រង់ ជំទាស់ថាជាការស្នងរាជ្យបន្តវង្ស ខុសពីព្រះរាជប្រពៃណី ក៏កែនប្រជានុរាស្ត្រ ធ្វើសង្គ្រាមដណ្តើមរាជសម្បត្តិពីព្រះមាតុលា។

5 ព្រះសេរីរាជា ជួនកាល សរសេរថា ព្រះស្រីរាជា។

ត្រួតត្រា ក្រុងកម្ពុជា ក្នុង ឋានៈ ជាមហាក្សត្រខ្មែរ។ ក្រោយពេល ដែលព្រះអង្គ ច្បាំងចាញ់ព្រះបាទពញាយ៉ាត ហើយទទួលមរណៈ ក្នុងសង្គ្រាមនៅ មហានគរខ្មែរ ព្រះពញាយ៉ាត ក៏សព្វព្រះទ័យ នឹង អ្នក ស៊ីសាងាម នោះណាស់ព្រោះ អ្នកម្នាងសៀម នោះមានរូបឆោម លោមពណ៌យ៉ាងល្អ។ ទ្រង់លើក តាំង ជា ស្នំឯក មាន ឋានៈ ជា ព្រះម្នាង។

កំណាព្យស្នេហ៍ (បទមេបួន)៖

*ឃើញឯងបាត់នឿយ រូបឆោមល្អម្លេះ*
*នាំចិត្តឲចេះ ស្នេហ៍ឆោមបុប្ផា។*
*អញជាម្ចាស់ថ្មី ក្រុងកម្ពុជា*
*សេរីមានងារ ជាស្រុកឯករាជ្យ។*
*ពញាយ៉ាតដៃ ក្សត្រឈ្នះសង្គ្រាម*
*ចិត្តជាទាហ៊ាន សូមស្នេហ៍កេសី។*
*អញច្បាំងហត់កាយ តែមានរាសី*
*ជួបឯងជាស្រី ឆោមលោមពណ៌ល្អ។*

និពន្ធដោយ ឧប សៅ សង្ហា

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

ព្រះរាជបុត្រ ព្រះម្នាង ស៊ីសាងាម ព្រះបាទ ធម្មរាជា នេះជាអ្នកឈ្នះសង្គ្រាម លើព្រះរាម និងព្រះភាគិនេយ្យា (ក្មួយ)[6] របស់ព្រះអង្គ ទាំងពីរ ព្រះអង្គ ដោយ សារ ព្រះអង្គ ទៅ ពឹង ស្តេចសៀម ក្នុងនាម ព្រះអង្គ ជាកូនកាត់ ខ្មែរ-សៀម ឲ មកធ្វើ អន្តរាគមន៏ ជួយ ព្រះអង្គ ហើយ ប្រើ ល្បិចកល បោកបញ្ឆោត ព្រះរាម និង ព្រះភាគិនេយ្យា ឲ ស្តេចសៀម ចាប់យក ទៅស្រុកសៀម ហើយ ទទួល ស្គាល់ ព្រះអង្គជាមហាក្សត្រខ្មែរ។

[6]ព្រះស្រីសុរិយោទ័យ ត្រូវជាព្រះបុត្រព្រះនរាយណ៍រាជា។ ពេលដែលព្រះបិតាសុគតទៅ ព្រះរាជវង្សានុវង្ស និង នាម៉ឺនសព្វមុខមន្ត្រីនាំគ្នាអញ្ជើញព្រះសេរីរាជា ជាព្រះអនុជបន្ទាប់ឲឡើយសោយរាជ្យស្នងព្រះបិតារបស់ព្រះអង្គ ដែលនាំអោយព្រះអង្គ អាក់អន់ព្រះហទ័យ ហើយ រង់ចាំឳកាសជានិច្ច នឹងដណ្តើមរាជ្យពី ព្រះសេរីរាជា។ នៅក្នុងសម័យនោះ ស្រុកខ្មែរមានមហាក្សត្របី ច្បាំងគ្នាដណ្តើមងារជាមហាក្សត្រស្របច្បាប់ក្រុងកម្ពុជាអស់រយៈពេលជាងដប់ឆ្នាំ។

ព្រះបាទ ធម្មរាជា មាន ព្រះរាជបុត្រា ពីរ ព្រះអង្គ៖ **ព្រះស្រីសុគន្ធបទ**[7] ជា ព្រះរាជបុត្រាច្បង និង **ពញាចន្ទរាជា**[8]។

រឿង ស្តេចកន មានកើតឡើង ក្នុងរាជ ព្រះបាទ ស្រីសុគន្ធបទ (១៥០៤-១៥១២) ដែល ខ្ញុំ លើក យក មក វិភាគ ក្នុងគំនិតថ្មី ដើម្បី ពិចារណា អំពី ស្ថានភាពសង្គម និង នយោបាយខ្មែរ នៅ ក្នុង សតវត្ស ទី១៦។

មាន អ្នកប្រវត្តិសាស្ត្រខ្លះ គេរាប់ បញ្ចូល ការរកឃើញទ្វិបអាមេរិក (១៤៩២) ដោយ លោក Christophe Colombe ជាការចាប់ផ្តើម នៃ សតវត្សទី១៦។ នៅ អឺរ៉ុបគេ ទុក សតវត្សទី១៦ ជាសតវត្ស «បញ្ញាថ្មី» និង «សិល្បៈថ្មី» ជាសតវត្ស ដែល អ្នកប្រាជ្ញ រកឃើញ ចំណេះធំៗ ជាច្រើន សំរាប់មនុស្សជាតិ។ នៅ ស្រុកខ្មែរ វិញ សតវត្ស ទី១៦ ចាប់ ផ្តើម ពីរាជ្យ

---

7 កាលព្រះអង្គមិនទាន់ឡើងគ្រងរាជសម្បត្តិនៅឡើយ ទ្រង់ព្រះនាម ចៅបញាដាំខត្តិ។

8 ពញាចន្ទរាជា កើតចំវេលាចន្ទ្រគ្រាស ដូច្នេះ ក្រុមបារគូបុរោហិតហោរាចារ្យថ្វាយព្រះនាមថា ចន្ទរាជា។ ព្រះមាតា ទទួលអនិច្ចកម្មនៅពេលឆ្លងទន្លេ ព្រះអង្គត្រូវបានជំនាវរារ ជាភរិយាចៅបញាយមរាជ ពីភក្តិរក្សាទ្រង់តាំងពីទារក។ ព្រះអង្គមាននាមទំយើហៅទ្រង់ប៉ៃរា។

ព្រះបាទសុគន្ធបទ ហើយ បញ្ចប់នៅ ផ្តើម រាជ្យពញាអន (១៥៩៩) បន្តពី រាជ្យ ព្រះរាមជើងព្រៃ[9] ដែលជា មហាក្សត្រ ឡើង គ្រងរាជ្យ បន្ទាប់ភ្លាមពី សៀម វាយបែក បន្ទាយ លង្វែក។ ត្រូវដឹងថា សៀម វាយបែកបន្ទាយ លង្វែក មែនពិត តែ មិនមាន ជ័យជំនះ លើ កងទ័ពខ្មែរទាំងអស់នោះទេ។ ព្រះរាមជើងព្រៃ ដែល ជា ញាតិវង្ស ជាមេទ័ពខ្មែរល្បីមួយ ទ្រង់បាន កេណ្ឌទ័ពច្បាំងនឹង សៀមវិញ ភ្លាមដើម្បីតាមដណ្តើម យក មកវិញ នូវ បេតិកភ័ណ្ឌជាតិខ្មែរ ដែលសៀម ប្រមូល យក ពីបន្ទាយលង្វែក និងរំដោះ ប្រជារាស្ត្រខ្មែរ ដែល ព្រះចៅសៀម ព្រះនាម ព្រះនរេន្ទ្រសូរ កៀរតាំងពីក្រោយទាំងសងខាង ពីខែត្រ សំរោងទោង លង្វែក ទៅដល់ ខែត្រ នាងរង ប្រមាណ ១២ សែននាក់ នាំយកទៅស្រុកសៀម។ តែ គោលបំណងនេះ មិនបាន ទទួលជោគជ័យទេ ព្រោះទ័ពសៀម ដក ថយទៅស្រុកគេវិញបានយ៉ាងរហ័ស ទាន់ពេលវេលា។ តែព្រះរាមជើងព្រៃ បានច្បាំងរំលាយ កងទ័ពបរទេស ដែលទុកអោយនៅត្រួតត្រា នៅស្រុក ឧដុង្គ បែករត់ត្រឡប់ទៅស្រុកវិញ បានតិចតួបំផុត។

---

99 ព្រះរាមជើងព្រៃ (១៥៩៣-១៥៩៩)។

៣ឆ្នាំ ក្រោយមក ព្រះរាមជើងព្រៃ ត្រូវ បាន ជនជាតិ ព័រទុយហ្គេស ម្នាក់ ឈ្មោះ ល្វីវែឡូហ្ស និងសេនា ២៤នាក់ ធ្វើឃាត ព្រះអង្គ បាន នៅ ក្នុង ព្រះបរមរាជវាំង ដោយ ប្រើល្បិចកល។ ជនបរទេសនោះ ជាមិត្តនឹងព្រះបាទជ័យជេដ្ឋាជា មហាក្សត្រខ្មែរ ដែល បាន លួច រត់គេចខ្លួន ពី បន្ទាយលង្វែក នៅពេលកំពុង មាន សង្គ្រាម។ ក្រោយ ពីសម្លាប់ព្រះរាមជើងព្រៃ បានហើយ ជនបរទេសនោះ បានទៅអញ្ជើញ ពញាតន់ ដែល ជាបុត្រកណ្តាល របស់ ព្រះបាទជ័យជេដ្ឋា ពី ខែត្រ ស្ទឹងត្រែង ឲ មកសោយរាជ្យ បន្តពីព្រះបិតាក្នុងស្រុកស្រីសន្ធរ។ ក្រោយមក ពញាតន់ ត្រូវបានពួកចាម លួចធ្វើឃាត ដោយប្រើល្បិចកល។ ព្រះមហាទេវីក្សត្រីដែលត្រូវជា ព្រះមាតុច្ឆាពញាតន់ ក៏ ទ្រង់យាងអញ្ជើញពញាអន ដែល ជាបុត្រា មហាក្សត្រខ្មែរ មួយអង្គដែរ ឲ ឡើងគ្រង រាជសម្បត្តិ នៅ ក្រុងកម្ពុជា គឺ ជា រាជ្យ បញ្ចប់សតវត្ស ទី១៦ នោះឯង។



ព្រះរាជបុត្រមួយអង្គ

## រាជ្យ ព្រះបាទ ស្រីសុគន្ធបទ

ក្នុង ជន្មាយុ ២៦ ព្រះវស្សា ព្រះស្រីសុគន្ធបទ ជា ព្រះរាជបុត្រច្បង ទ្រង់ បានឡើង សោយរាជ្យ ស្នង ព្រះបិតា នៅ ឆ្នាំ ១៥០៤ នៅ ចតុម្មុខ ស្រុកភ្នំពេញ។

សោយរាជ្យ បាន ៤ ឆ្នាំ ព្រះអង្គ មានព្រះរាជតម្រិះ ចង់ ប្តូររាជធានី ពី ស្រុក ភ្នំពេញ មក នៅ ស្រុកបាសាន (ស្រីសន្ធរ) ដែលជាអតិត រាជធានីរបស់ព្រះអយ្យាកោ (ជីតា) ព្រះបាទពញាយ៉ាត។ ទន្ទឹករណ៍ របស់ ព្រះអង្គ គឺផ្អែកលើយុទ្ធសាស្រ្តសង្គ្រាម។

ឆ្នាំ១៥០៨ នៅក្នុង អង្គប្រជុំរាជគណសេនាមន្ត្រី ពិសេស ព្រះរាជា មានព្រះបន្ទូល ទៅ កាន់ អង្គប្រជុំ ថាៈ

- *ស្រុក ស្រីសន្ធរ*[10] *ជា ទីកន្លែង ល្អ ប្រពៃ សំរាប់ តាំង ជា រាជធានី ព្រោះ មាន មធ្យោបាយ ជា ធម្មជាតិ សំរាប់*

---

[10] ស្រុកស្រីសន្ធរ ជាស្រុកកំណើត របស់អ្នកម្នាង កេសរបុប្ផា ជាស្នំឯក។ ដូច្នេះប្រហែលជាអ្នកម្នាងនេះឯង ដែលជាអ្នកមានប្រភាពទៅលើ ព្រះសុគន្ធបទ ស្នើសុំអោយព្រះស្វាមី លើករាជធានីទៅនៅស្រុកកំណើតខ្លួនវិញ។ តែនៅទីនោះ អ្នកណាក៏គេដឹងពីដើមកំណើតមាតាជាពលព្រះ ប្រហែលជាអ្នកម្នាងនេះដែរ ស្នើដល់ព្រះ

*ការពារបន្ទាយរាជ្យ ត្បិត មាន បឹង ខណ្ឌ ខាងជើង មាន ទន្លេ ខណ្ឌ ខាងកើត មាន ព្រៃធំ ខណ្ឌ ខាង ទិសត្បូណ។ យើង យល់ឃើញ ថា ទីនោះ នាំមក នូវសេចក្តីសុខកាយ និងចិត្ត ពី ការវាយលុក ពី សំណាក់ ខ្មាំង សត្រូវរាជ្យ និង ខ្មាំង សត្រូវនគរ។ តើ អស់ ព្រះអង្គម្ចាស់ និងអស់ លោក នាម៉ឺន យល់ឃើញ បែប ណាទៅ នូវ គម្រិះ របស់យើង នេះ។*

សុវណ្ណី (សំដី) ព្រះរាជា ទុក ដូច ជា បញ្ហា រួចស្រេច សំរាប់ ព្រះរាជវង្សានុវង្ស និង អង្គអគ្គសេនាមាត្រា។ ដូច្នេះ ត្រូវ មាន ចម្លើយ តប អោយ ស្របនឹង ព្រះរាជគម្រិះ ដើម្បី រក្សាសុខ សំរាប់ ការរស់នៅ នៃជីវិត។ នៅ ក្នុង ទស្សនៈ បែប នេះឯង ដែល សម្តេចនាយក រាជគណសេនាមន្ត្រី ឆ្លើយ តបទៅ ព្រះរាជា៖

---

រាជាអោយដោះងាររញ្ជួតិសន្តាន របស់មាតា ពីពលព្រះនោះឯង។ បើសំអាងលើឆ្នាំកំណើត របស់កន (១៤៨៣) អ្នកម្នាង កេសរបុប្ផា និង ព្រះសុគន្ធបទ មានអាយុមិនច្រើនជាងគ្នា១ឆ្នាំឬ ពីរឆ្នាំតែ ប៉ុណ្ណោះ។ គម្លាតអាយុតិចនេះឯង ដែលនាំអោយអ្នកម្នាង កេសរ បុប្ផា មានប្រភាពខ្លាំង ទៅលើព្រះសុគន្ធបទ ព្រោះនាង មាន ភាពចាស់ទុំ អាចនឹងនិយាយប្រស្រ័យកិច្ចការនគរខ្លះជាមួយព្រះ ស្វាមីបាន។

---

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

*- ពួក យើងខ្ញុំ ជា អ្នកបំរើ យល់ឃើញ ថា ព្រះរាជតម្រិះ ព្រះអង្គ ពិត ជា នាំ មក នូវសេចក្តីសុខ ដល់ អាណាប្រជារាស្ត្រ គ្រប់ស្រទាប់ និង ព្រះពុទ្ធសាសនា។ យើងខ្ញុំ ជា អ្នកបំរើ ហ៊ាន ប្តូរជីវិត មាន តែ ស្វាគមន៍ ដល់ ព្រះរាជតម្រិះ ជា ប្រយោជន៍ជាតិនេះ។*

អង្គប្រជុំ រាជគណរដ្ឋមន្ត្រី ព្រមព្រៀង ដូច្នេះហើយ ក៏ ចែក ចំណែក កិច្ចការ ដល់ ក្រសួង សាធារណៈការ អោយ ទៅ រៀបចំទុក ជា មុន នៅ ស្រុកសន្ធរ សំរាប់ ទទួល ព្រះរាជា ដូច មាន សាង ព្រះបរមរាជវាំង ព្រះដំណាក់ ដោយ ខ្ចីខ្ចា និង បន្ទាយជ័យ អោយ សម ឋានៈ ជា ព្រះរាជធានី ក្រុង កម្ពុជាធិបតេយ្យ។

នៅស្រុកបាសាន (ស្រីសន្ធរ) មាន មន្ត្រីធំម្នាក់ ឈ្មោះពិជ័យ នាគ មានភរិយា ជា ស្រីពល ព្រះរតនត្រ័យ (ពលមាន មុខ ងារ ជា អ្នក ថែរក្សា វត្តអារាម)។ នាង បានមានកូនស្រី មួយ កើតនៅក្នុង រាជ្យ ព្រះធម្មរាជាមានឈ្មោះស។ បន្ទាប់ មក បាន មាន គភ៌ ម្តងទៀត ហើយ ថ្ងៃ មួយ ជិត គ្រប់ ខែ នាង ចុះ ទៅ ដោះ ទុកសត្វ ក្នុង បង្គន់ ក៏ របូត ទារក នោះទៅ ក្នុង ទឹក។ ពេលនោះ មាន ហេតុ អស្ចារ្យ នាំអោយ ឃើញ ថា ទារក នោះមាន បុណ្យ មែន គឺ ថា វេលា នោះ ស្រាប់ តែ មាន ត្រីពោធំ មួយ មក ទទួល លេប ទារក

នោះ ទៅ ក្នុង ពោះ បាត់ទៅ។ នៅ ពេល នោះ ព្រាន ប្រមង់ ម្នាក់ ទៅបង់ សំណាញ់ក៏ត្រូវជាប់ ត្រីពោ នោះ បាន មក។ ជា កុសល ទារក មិនស្លាប់ ដ្បិតក្នុង ថ្ងៃ នោះ ក៏ មាន ហេតុ បណ្ដាល ឲ សម្ដេចពាហរៈ មហាសង្ឃរាជ (កាលនោះ នៅ ជា ព្រះសង្ឃសត្ថា) យប់ នោះផ្ទុំ ស្កល់ទៅ យល់សប្តិ ឃើញថា ដូចមាន ទេវ តាមទូល ថា៖ ព្រឹក នោះ ឲស្ដេច យាង ទៅ កំពង់ទឹក ដើម្បី ជួយសង្គ្រោះទារក ម្នាក់ ជា អ្នក មាន បុណ្យ មាន វាសនា ផង។ លុះ តើន ឡើង សម្ដេច ក៏ ទ្រង់ នូវត្រៃចីវរ ចុះ គង់ក្នុងទូក អោយ សិស្សានុសិស្ស អុំ ចេញទៅ។ ទ្រង់បិណ្ឌបាត តាម សព្វ ដង តែ ព្រះនេត្រ តែង គន់ រំពៃមើល ក្រែង មាន ហេតុ អ្វី ជា ចម្លែក ដ្បិត មាន និមិត្ត ពីយប់មិញនោះ ដូចជាច្បាស់ពេកណាស់។ លុះ សិស្ស អុំបន្តិចទៅ ទូក ក៏ ទក អែប ប្រប ទូក ព្រានប្រមង់ នោះ។ សម្ដេច ឃើញ ត្រីពោ ក្នុង ទូក ព្រាន ប្រមង់ នោះ ធំ ប្លែក ស្ដេច ប្រឹង សង្កេត ទតឲច្បាស់។ ព្រានប្រមង់ ឃើញ ស្ដេច អើតទៅទត ត្រីនោះ ក៏ បង្កើត ឲមាន សទ្ធា លើកត្រី ពោ ថ្វាយ ដល់ ព្រះអង្គ។ ព្រះអង្គ ទ្រង់ ទទួល ហើយ ក៏ ឲអុំ ទូក បិណ្ឌបាត ទៅ ទៀត។ លុះ បិណ្ឌ អស់ ពេលហើយ ស្ដេច ក៏ យាងត្រឡប់ មក អារាម វិញ។ ខណៈនោះ ស្ដេច មាន ព្រះថេរ វាចា ថា ត្រីពោ នេះ ជា ពោធំប្លែក ពី ត្រីពោ សព្វ ដង ប្រហែល ជា មាន ហេតុអ្វី ក្នុងពោះ ត្រី នេះ ជា ពុំខាន

ឡើយ។ អស់ ពួក សិស្សានុសិស្ស ឮពុទ្ធដីកាហើយ ក៏ នាំ គ្នា យក កាំបិត ទៅ វះ ពោះ ត្រីនោះ វះ ទៅ ឃើញ ទារក មួយ នៅរស់។ ទើប ស្ដេច ឲកូននោះ ទៅ ប្ដី ប្រពន្ធ មួយគូរយក ទៅចិញ្ចឹមរក្សា។

រឿង ចម្លែកនេះ បានឮ ដល់ ព្រះពិជ័យនាគ និងភរិយា ក៏ នាំ គ្នា ទៅ ថ្វាយ បង្គំ ព្រះសង្ឃ សូមទារក ជា កូន នោះមក វិញ។ ពេល យក បាន ទារក មកផ្ទះវិញ ហើយ ក៏ នាំគ្នា សំរេច ដូរឈ្មោះកូនពី កៅ ដែល ព្រះសង្ឃ ប្រគេន ឲមកជា កន វិញ។

តើហេតុអស្ចារ្យ ដែល កើត មាន ឡើង នោះ មានទំនង ជា រឿង ពិត ដែរ ឬទេ ?

ចំណុចនេះ ខ្ញុំទុកជូនអ្នកអាន ម្នាក់ៗ យកវាទៅពិចារណា រក ការពិត រៀងៗខ្លួនទៅចុះ ព្រោះ វាជារឿង ក្នុងអារម្មណ៍ បុគ្គល ដែលពុំអាចនរណាម្នាក់ អាចបំពាន បាននោះទេ។

នៅ ក្នុង សម័យ នោះ របប នយោបាយខ្មែរ ជា របប រាជាធិបតេយ្យ ដែល មាន មហាក្សត្រ ជា អ្នកដឹកនាំ ផ្ដាច់ការ។ អ្វី ដែល ព្រះរាជា ចង់បាន ឬ យល់ឃើញ មាន លក្ខណៈ ជា បញ្ញា ជានិច្ច។ សម័យ ថ្ងៃ មួយ ព្រះបាទ ស្រីសុគន្ធបទ ទ្រង់ យាង ទៅ ថ្វាយ បង្គំព្រះ នៅវត្ត។ ពេលនោះ ទ្រង់ ទតព្រះនេត្រ ទៅ ឃើញ ស្រី ម្នាក់ ឈរ នៅ លើ ខឿន ព្រះវិហារ ជា

កូន ព្រះពិជ័យនាគ និង លោកស្រី មេបាន។ ព្រះអង្គ ទត ម្តងហើយម្តងទៀតនាំឲ ព្រះពិជ័យ ចាប់អារម្មណ៍យល់ ដឹង ភ្លាម ពីព្រះរាជហឫទ័យ ព្រះមហាក្សត្រខ្លួន ទើប ក្រោយ មក ក៏ចូល ទៅ ក្រាបថ្វាយ បង្គំ ព្រះរាជា ថ្វាយ កូនស្រី នោះជាខ្ញុំបំរើ ល្អងធូលីព្រះបាទ។ ព្រះរាជា ទ្រង់ សោមនស្ស ណាស់។ ទ្រង់ តាំង នាម នាង ស ជាអ្នក ព្រះម្នាង កេសរ បុប្ផា ព្រះស្នំឯក ហើយ លើក ដំកើង មាតា បិតា អ្នកព្រះ ម្នាង អោយ មាន ឋានៈ ក្នុង រាជវង្សានុវង្សក្នុង វង្ស ធំ មាន នាម ជា ព្រះបិតា ពិជ័យនាគ និងអ្នក ព្រះមាតា មេបាន។

ដោយ មាន សេចក្តីប្រតិព័ទ្ធ នឹង ព្រះស្នំឯក ពេក ព្រះបាទ ស្រីសុគន្ធបទ ទ្រង់ ព្រះបញ្ញត្ត អោយ លើកលែង ហៅ ស្រុក បាសាន អោយ ហៅថា ស្រុកស្រី ស ឈរ ឬ ខែត្រ ស្រី សឈរ តែ ពាក្យ នេះ យារៗ មក ក៏ ប្រែក្លាយ ជា ខែត្រ ស្រីសន្ធរ រហូត មក ដល់ សព្វថ្ងៃ នេះ។



បុត្រមន្ត្រីម្នាក់

## វាសនា របស់ កន

កន កើតនៅឆ្នាំ ១៤៨៣, តាំង ពី កុមារភាព កន ជា ក្មេង មាន ប្រជ្ញា ឈ្លាតវៃ ត្រូវ បាន បិតា មាតា បញ្ជូន ឲ ទៅ នៅក្តី[11] ដែល មាន សម្តេច ពាហរះ មហាសង្ឃរាជ ជា គ្រូ មាន នាម សត្ថា។ លុះ ចម្រើន ធំ ឡើង មាន ចំណេះ លើ សិស្សានុសិស្ស ទាំងពួង ចេះ ស្ទាត់ សាស្ត្រមន្តវិជ្ជាការ គាថា កៅទណ្ឌ ក្បួនតម្រា ទាំងឡាយ គ្រប់ សព្វ សារពើ ឥត ចន្លោះ ឡើយ។ កន ចេះ បម្រើគ្រូ ហើយ គ្រូ ក៏ ពេញចិត្ត នឹងសិស្ស បាន ទំនាយ ថា៖ ក្មេង នេះ នឹង បាន គ្រង ស្រុក ថ្ងៃ ណា មួយ ជា មិន ខាន។ នៅពេល កន អាយុបាន ១៦ ឆ្នាំហើយ, មាតា បិតា ក៏នាំកូនទៅក្រាបទូលព្រះហ្លួង និងថ្វាយជូន ជាខ្ញុំបំរើនៅក្នុងព្រះបរមរាជវាំង។ ព្រះហ្លួង ជ្រាបដឹងថា កន ជាយុវជនមានចំណេះចេះដឹងទាំងអក្សរ សាស្ត្រ គាថា កៅទណ្ឌ ក្បួនតម្រាគ្រប់បែបយ៉ាង ក៏តាំង កន ជាឧកញ្ញាម៉ឺនស្នេហាចមចិត្ត។ អស់រាស្ត្រប្រជា កោត ខ្លាច នាយ កន ហើយតែងតែចូលពឹងបុណ្យអំណាច។

11 ពាក្យទៅនៅក្តី ជាពាក្យបុរាណ គឺមានន័យថាទៅរៀនសូត្រនៅ នៅវត្តអារាម។

នាយ កន មិនគ្រាន់តែជាបញ្ញាវន្ត គឺ នាយចេះវិជ្ជាគុនជាច្រើនទៀត ជាពិសេស សិល្បៈបាញ់ធ្នូល្បីឈ្មោះថែមទៀត ដែលនាំអោយព្រះហ្លួង ចង់ឃើញ ក៏ថ្ងៃមួយ ព្រះអង្គ បញ្ជាអោយកន បង្ហាញថ្វីដៃថ្វាយទត។ នាយកន ឥតរញ៉ា ដំឡើងធ្នូ ចាប់ព្រួញ៥ បាញ់ទៅម្តង ព្រួញចេញទៅត្រូវដើមឈើផ្លែឈើទាំង៥ទិស។ ថ្វីដៃនេះ រឹតតែធ្វើអោយព្រះមហាក្សត្រ កោតសរសើរស្តេចកនក្រៃលែង។

មកដល់ឆ្នាំ ១៥០៧ ព្រះហ្លួងមានព្រះតម្រិះថា នៅត្រោយខាងលិច មានចម្ងាយឆ្ងាយណាស់ពីព្រះរាជធានី ដែលនាំអោយមាន ការពិបាកដល់កិច្ចការត្រួតត្រា អាណាប្រជារាស្ត្រ ដូច្នេះ ព្រះអង្គ ក៏បញ្ជាអោយ ចៅបញចន្ទរាជា ជាព្រះអនុជនោះ យាងទៅគ្រប់គ្រងដំបន់នោះ យកក្រុងចតុម្មុខមង្គលភ្នំពេញ ជាទីតាំងឧបសម្ព័ន្ធរាជរដ្ឋបាលព្រះនគរ ដើម្បី ទំនុកបម្រុងអ្នកស្រុកឲបានក្សេមក្សាន្ត ឥតមានកលិយុគ[12]។ គួរកត់សំគាល់ដែរថា នៅឆ្នាំ ១៥០៧ ព្រះ

12 នៅក្នុងព្រះរាជពង្សាវតាខ្មែរ មានភាពមិនច្បាស់លាស់អំពីឆ្នាំដែលព្រះសុគន្ធបទ ទ្រង់ប្តូររាជធានីពីក្រុងចតុម្មុខ ទៅតាំងនៅស្រុកបាសាន កត់ថានៅឆ្នាំ ១៥០៨ និង ឆ្នាំដែលព្រះអង្គត្រាស់

ចន្ទរាជា ទ្រង់ទើបតែមានព្រះជន្មាយុ ១១ឆ្នាំ តែប៉ុណ្ណោះ ជាកុមារកំព្រាមាតាឥឡូវត្រូវចាកចោលមាតាចិញ្ចឹម ជំទាវវាវទៅនៅឯកា។ ដូច្នេះ ព្រះចិន្តនាការ នៃព្រះសុគន្ធបទថា ព្រះអនុជមានបក្កភាព (ភាពចាស់ទុំ) អាចត្រួតត្រាកិច្ចការនគរ នៅក្រោយខាងលិច វាមិនសមហេតុផលនោះឡើយ ព្រោះព្រះអនុជ ទ្រង់នៅក្នុងកុមារភាពនៅឡើយ។ ការសម្រេចនេះ វាអាចគេគិតបានថា ជាការបោះបង់ប្អូនទេតើ។ ត្រូវកត់សំគាល់ថា ជំទាវវារ ជាភរិយាចៅបញ្ញាយមរាជ ដែលជានាយមេទ័ពហ្លួង ជាអ្នកចិញ្ចឹមបីបាច់ថែរក្សាព្រះចន្ទរាជាតាំងពីទារកមក ដូច្នេះ ពញាយមរាជ

---

បញ្ជាអោយព្រះអនុជ ព្រះចន្ទរាជា យាងទៅត្រួតនៅត្រើយខាងលិច កត់ថានៅឆ្នាំ ១៥០៧ យកចតុម្មុខមង្គល (រាជធានីភ្នំពេញសព្វថ្ងៃ)។ បើដូច្នេះមែន គឺព្រះសុគន្ធបទ នោះទេ ដែលយាងទៅគង់នៅរាជធានីថ្មី នៅស្រុកបាសាននៅក្រោយខាងកើតវិញទេ។ ចំណែកព្រះចន្ទរាជា ទ្រង់គង់នៅមណ្ឌលចតុម្មុខនៅក្រោយខាងកើត ហើយប្រហែលគ្រាន់តែឆ្លងទន្លេមកគង់នៅស្រុកភ្នំពេញនៅក្រោយខាងលិចតែប៉ុណ្ណោះ។ ដូច្នេះ ព្រះចន្ទរាជាចាកចេញក្រុងចតុម្មុខនៅក្រោយខាងកើត មួយឆ្នាំមុន ព្រះសុគន្ធបទលើករាជធានីទៅគង់នៅស្រុកបាសាន គឺនៅឆ្នាំ ១៥០៨។ បើយើងយកឆ្នាំទាំងពីរមកសំអាង យើងអាចសន្និដ្ឋានបានថា ព្រះសុគន្ធបទ ទ្រង់មិននាំ ព្រះអនុជទៅគង់នៅជាមួយទ្រង់ នៅរាជធានីថ្មីនៅស្រុកបាសាន (ស្រីសន្ធរ)។

**និពន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

លោកក៏ជាបិតាចិញ្ចឹម របស់ព្រះចន្ទរាជាដែរ។ ទុកឱ្យព្រះអនុជ បន្តរស់នៅជាមួយពញាយស ក្នុងអារម្មណ៍ របស់ព្រះសុគន្ធបទ វាអាចជាគ្រោះថ្នាក់ដល់រាជ្យ ព្រះអង្គផង និងព្រះរាជបុត្រមកុដ បញ្ញាយសផង នៅពេលអនាគត ព្រោះពញាយសអាចនឹងមានចិត្តគំនិត ចង់ឱ្យកូនចិញ្ចឹមខ្លួនឡើងគ្រងរាជសម្បត្តិ ជំនួស ពញាយស ដែលមានជីដូន ជាអ្នកងារ។

នៅពេលជួបជុំព្រះរាជវង្សា ព្រាហ្មណ៍ព្រឹទ្ធាចារ្យ សេនាបតីមន្ត្រីធំតូច ព្រះហ្លួង ទ្រង់ព្រះចិន្តាថា គួរកែស្រាយងារ ជាពលព្រះស្រីរតនត្រ័យ នៃវង្ស មាតា របស់ព្រះស្នំឯក ព្រះម្នាង កេសរបុប្ផា ដើម្បីលើក កិត្តិយសដល់ព្រះស្នំឯក និងមាតាបិតាក្មេង របស់ព្រះអង្គផង។ តែព្រះចិន្តា ត្រូវបានអង្គប្រជុំក្រាប ទូលព្រះអង្គថា វាមិនស្របនឹងព្រះតម្រិះ របស់ព្រះមហាក្សត្រអំពីបុរាណ ដែលបានព្រះសច្ចាថាគ្រប់ ៥០០០ ព្រះវស្សា ទើបមនុស្សទាំងនោះ ដោះសាចេញរួចពីងារពលនោះបាន។ បើព្រះអង្គ កែស្រាយឥឡូវនេះ រឿងនេះវាដូចជា ព្រះអង្គមិនគោរព ចំពោះពាក្យសច្ចាផង និងចំពោះព្រះស្រីរតនត្រ័យផង។ យល់ឃើញថា ព្រះតម្រិះនេះមានការជំទាស់ច្បាស់លាស់ពីអង្គប្រជុំ ព្រះអង្គក៏នៅស្ងៀមមិនទទួចចង់យកឈ្នះនោះឡើយ។ តែការជំទាស់នេះ វានាំអោយនាយកន មានការអាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង

ចំពោះពួកអ្នកមិនយល់តាមព្រះរាជតម្រិះ។ ដើម្បីលួងចិត្ត ដល់គ្រួសារព្រះស្នំឯក ព្រះហ្លួង បានតែងតាំង នាយកនជា ឃុនហ្លួងព្រះស្ដេច មានជំទប់៤នាក់ ជាអ្នកបំរើកិច្ចការ។ មុខងារនេះគឺត្រួតត្រា មើលពលបម្រើ ព្រះស្រីរតនត្រ័យ ទាំងនគរ អាចមានអំណាចផ្ដន្ទាទោស មនុស្សពាលាលោ មោហ៏បិទ ចិត្តអកត្តញ្ញូ និង បង្ខូចបង្ខុស ព្រះស្រីរតន ត្រ័យ ល្មើសបុរាណរាជប្រវេណី ចាស់ព្រឹទ្ធាចារ្យផងទាំងពួង។ មុខងារនេះ ធម្មតា ត្រូវមានឋានន្តរស័ក្តិ ជារាជឧត្តម មន្ត្រី តែព្រះហ្លួង ទើសទាល់នឹងដើមកំណើត នៃមាតា នាយកន ជាពលព្រះ, បើនឹងថ្វាយស័ក្តយសនោះដល់ នាយកន វាក្រែងខ្ញុំរាជការផងទាំងពួង គេនឹងនិន្ទាព្រះ អង្គ នាំអោយព្រះអង្គខូចកិត្តិយសជាមិនខាន។ ឃុនហ្លួង ព្រះស្ដេចកន ក៏មានកេរ្ដិ៍ឈ្មោះពេញព្រះនគរ អស់ខ្ញុំរាជា ការ ក៏កោតក្រែងណាស់ ដែលនាំអោយ សេនាបតី មន្ត្រីធំ តូចមួយចំនួន ច្រណែន និង ព្រមទាំងមិនចូលចិត្ត អាកប្បកិរិយា ក្រអឺតក្រទម របស់កន ដែលតាំងខ្លួនជា អ្នកចេះដឹង លើសអ្នកដទៃជានិច្ច រួចអាងខ្លួនជាប្អូនព្រះ ស្នំឯក និងពុំកោតក្រែងមន្ត្រីចាស់ទុំឡើយ។ អ្នកមិនចូល ចិត្តនឹងកនខ្លះ យករឿងនេះ ទៅញុះញង់ព្រះមហាក្សត្រ អោយព្រះអង្គ មានការប្រយ័ត្ន ចំពោះកន ព្រោះមនុស្ស នេះ វាអាចមានថ្លើមធំហ៊ានបំពានរាជបល្ល័ងតែព្រះអង្គ

មិនសូវយកចិត្តទុកដាក់នឹង សំដីចាក់រុកនោះឡើយ តែមានការកង្វល់ជានិច្ចនៅក្នុងអារម្មណ៍ព្រោះគិតថាអាកនវាជាមនុស្សមានប្រាជ្ញាណាស់។

ពេលចេះតែកន្លងតៗមក ព្រះស្នំឯក ប្រសូតបានព្រះរាជបុត្រាមួយព្រះអង្គ ព្រះនាម ចៅពញាយសរាជា។ នៅថ្ងៃចូលឆ្នាំថ្មី ក្រោយពីព្រះហ្លួង ធ្វើសក្ការបូជា ថ្វាយព្រះស្រីរតនត្រ័យ សព្វទេពទិសទសស្រេចហើយ ស្ដេចចូលក្រឡាព្រះបន្ទំជាសុខស្ដល់ ទ្រង់ព្រះសុបិននិមិត្តឃើញថា : មាននាគមួយធំ មានឫទ្ធិមហិមា មកដេញព្រះអង្គ និង មនុស្សម្នា អោយរត់ចេញអស់ពីព្រះរាជវាំង ហើយព្រួសពិសភ្លើងឆេះដាលពេញទាំងព្រះមហានគរ។ អំណាចភ្លើងនោះ ក្ដៅពន់ប្រមាណណាស់ ឃើញហាក់ដូចជានាគនោះ ស្ទុះចូលមកខាំពាំស្វេតច្ឆ័ត្រ នាំទៅទិសបូណ៌។ លុះល្ងមព្រឹកឡើង ព្រាងស្វាងព្រះសុរិយា ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង តើនចាកសេយ្យាន៍ស្រេច ស្ដេចព្រួយព្រះទ័យនឹង សុបិនប្លែកនោះពន់ប្រមាណណាស់។ នៅពេលព្រះករុណា យាងមកជួបអ្នកចូលគាល់ទាំងឡាយ ដើម្បីអ្នកទាំងនោះ ថ្វាយទៀនធូបមាលា តាមព្រះរាជប្រវេណី នៅថ្ងៃទី២ នៃបុណ្យចូលឆ្នាំថ្មី នៅវេលានោះនៅក្នុងក្រឡាគំនាល់ ពីលើព្រះទែនទិព្វអាសនា ព្រះហាក់បីជាទតឃើញ មានតួនាគពីរ ព័ទ្ធព័ន្ធលើ ឃុនលួងព្រះស្ដេច កន ហើយងើបក្បាលឆ្វេងស្ដាំទន្ទឹម

គ្នានឹងសេរិសានរ:នោះ ហើយ រូបនាគនោះ ដូចនាគដែលព្រះអង្គទ្រង់ព្រះសុបិននិមិត្ត។ កិរិយានាគនោះ ហាក់ដូចជានឹងស្ទុះទៅខាំព្រះអង្គ ពេលនោះព្រះអង្គ ភ្ញាក់ព្រះទ័យត្រាស់ហៅអោយអស់អ្នកចូលគំនាល់ មើល តែអ្នកទាំងនោះមើលពុំឃើញតាមព្រះរាជបញ្ហាសោះ។ បន្ទាប់មក ព្រះអង្គទទួលសារពី ចៅហ្វាយខេត្តបាត់ដំបង ប្តឹងមកថា : ទឹក សម្រាប់ព្រះមហាក្សត្រ ដែលនៅក្នុង គុហាភ្នំបាណន់នោះ ចេញជាឈាមដាលក្រហម ដូចទឹកល័ខ។ នៅក្នុងចំណោមសារ ទូលថ្វាយដំណឹងផ្សេងៗទៀត ក៏មានសារពីព្រះចៅអធិការ វត្តព្រះវិហារសួគ៌ ប្តឹងមកថា : ព្រះជ្រៃប្រគ្នួល បាក់មែកចេញជាឈាម និង បដិមាករ ព្រះឥសូរព្រះនរាយណ៏ ប្រេះព្រះឧរាចេញជាឈាមដែរ។ នៅពេលជាមួយគ្នានោះដែរ ព្រះរាជគ្រូបុរោហិតក៏ថ្វាយសេចក្តីថា : ព្រះខាន់ជ័យមង្គល មានស្នឹមប្រាលក្រហមពីត្រីសូល៏[13] ដល់គល់។ មានបន្ថែមទៀត សំបុត្រប្តឹងពីចៅហ្វាយស្រុកពោធិសាត់ថា : ព្រះកាំបិតស្តាំ រង្គោះផែពីដង និង មានផែះនៅក្នុងស្រោមកាំបិត។ នៅទីបញ្ចប់ មានចុតហ្មាយពីស្រុកភ្នំថា :

---

13 សូល៏ : ដែកមូលវែងខាងមុខ។

ព្រះពុទ្ធរូបទីបាក្អំ ហូរទឹកព្រះនេត្រមកជាឈាម ក្រហនដូចល័ខ។

គ្រប់ព័ត៌មានទាំងឡាយ នាំអោយព្រះករុណា មានសេចក្ដីព្រួយប្រទ័យណាស់។ លុះពេលវេលា ក្រាបបង្គំគាល់ហើយ ព្រះអនុជអង្គចន្ទរាជាធិបតី និងខ្ញុំរាជការថ្វាយបង្គំលារៀងៗខ្លួន ព្រះករុណា ទ្រង់ចូលទៅសាលារតនបល័ង្គ រួចត្រាស់ព្រះឥសីភ័ទ្ទ ជាមហាគ្រូ និង រាជហោរាធិបតិ អោយចូលគាល់ជាទីសម្ងាត់ ដើម្បីប្រិក្សាការណ៍ផែនដី ស្ដីពីហេតុគ្រប់ប្រការ។

ព្រះឥសីភ័ទ្ទ ទាយថា : អ្វីដែលកំពុងកើតឡើង គឺជាផ្ទួលមិនល្អដល់ព្រះនគរ ហើយវានឹងកើតហេតុធំពុំខាន។

ព្រះរាជហោរាធីបតិ ក្រាបទូលព្រះរាជាថា : ហេតុនេះ ផែនដីនឹងកើតកោលាហលដល់អស្ចារ្យ ព្រោះនឹងមានព្រះគ្រោះកាចខ្លាំងណាស់។

ព្រះហ្លួង ត្រាស់សួរបន្តថា : រាជសត្រូវនោះ មកពីក្នុង ឬក្រៅស្រុក។

ព្រះរាជហោរាទាំងពីរ នាំគ្នាគន់គូរ តាមលេខគម្រាតទៅទៀត រួចស្រេចទើបទោលព្រះរាជាថា : រាជសត្រូវនោះ នៅក្នុងនគរ។ វាកើតឆ្នាំរោង ពង្សនាគ។ ហើយវាគ្មាននរណា

ក្រៅពី យុនហ្លួងព្រះស្ដេចកននេះ ដូច្នេះ សូមអោយព្រះអង្គកុំប្រហែសព្រះអង្គ។

ព្រះអង្គ បានទ្រង់ជ្រាបទំនាយ ត្រូវនឹងហេតុសុបិននិមិត្តទ្រង់ស្លុតក្នុងព្រះរាជហឫទ័យណាស់ ទើបត្រាស់ថា : អញក៏ឃើញពិត ដូចហោឯងទាយដែរ តែបើយកវាទៅប្រហារជីវិតតែម្ដង វាឥតខុសឥតទោសនឹងអញសោះ វាមុខជាមានពាក្យគេនិន្ទាជាពុំខាន, មួយវិញទៀតបងស្រីវាជា ស្នំឯក ព្រមទាំងមានព្រះរាជបុត្រផង បើវាដឹង ក្រែងនឹងញុះញង់កូនវា អោយចេញជាសត្រូវនឹងអញ។ ដូច្នេះ មានតែរកឧបាយកល ធ្វើយ៉ាងណាអោយមរណភាព អាកន ជាគ្រោះថ្នាក់។ អញឃើញមានឧបាយកលមួយល្អប្រសើរ គឺអញនាំ អាកន និង មន្ត្រីក្នុងវាំងទៅបង់សំណាច់ ហើយក្លែងធ្វើជាសំណាញ់ជាប់គល់ រួចហើយបង្គាប់អោយវាមុជចុះទៅដោះ ហើយនៅពេលនោះ យើងព្រួតគ្នាបង់សំណាញ់គ្របវាអោយជាប់ ទុកអោយវាស្លាប់ នៅក្នុងទឹកតែម្ដង។ ព្រះរាជហោរាទាំងពីរ ក៏យល់ស្របនឹងព្រះតម្រិះ។ តែនៅពេលជំនុំសម្ងាត់នោះ ព្រះម្នាងព្រះស្នំឯក លបស្ដាប់ផ្ទាប់ខាងឡប់ឡែ្ទ តែឮមិនសូវច្បាស់ គ្រាន់តែឮចុងពាក្យថា : អោយព្រះស្ដេចកនមុជទឹក ហើយអោយបង់សំណាញ់គ្របវាអោយស្លាប់តែប៉ុណ្ណោះ។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

មកដល់ចំណុចនេះ គួរយើងលើកមកពិចារណា អំពីកិរិយា របស់ព្រះស្រីសុគន្ធបទ និង ព្រឹត្តិការណ៍ទាំងឡាយដែល មានកើតឡើង ដែលនាំអោយព្រះអង្គប្រព្រឹត្តបែបនេះ។

ឃុនហ្លួងព្រះស្តេចកន ជាអ្នកមានចំណេះជាបណ្ឌិត ចេះ វិជ្ជាគុនឥតខ្ចោះ មានរូបស្អាតជាទេវតា នៅក្មេងសោះ តែ មានតំណែងខ្ពង់ខ្ពស់ មានប្រជាប្រិយភាពខ្លាំងណាស់នៅ ក្នុងចំណោមពលព្រះ ដែលនៅក្រោមការត្រួតត្រាដាច់មុខ របស់ខ្លួន។ គុណសម្បត្តិទាំងឡាយនោះ នាំបង្កើតអោយ មានសេចក្តីច្រណែន ពីសំណាក់ មន្ត្រីធំតូចនៅក្នុងព្រះ បរមរាជវាំងផង និង មានសួស្តី ពីសំណាក់ស្ត្រីក្រមុំនៅក្នុ វាំង និង ស្នំក្មេងៗ របស់ព្រះរាជា។ គុណវិបត្តិ របស់ឃុនហ្លួង ដែលពួកមន្ត្រីលើកឡើង គឺ វង្សពលព្រះ របស់មាតា របស់ កន។ ចំពោះមន្ត្រីទាំងនោះ កន មានកំណើត ជាកូនកាត់ ពល ដូច្នេះ គ្មានសិទ្ធិ អាចមានតំណែងជាឧត្តមមន្ត្រីបាន នោះឡើយ ទោះបីតំណែងនេះ ត្រូវបានតែងតាំងពីព្រះរា ជា។ ម្យ៉ាងមួយទៀត ពួកមន្ត្រី នាំគ្នាចោទប្រកាន់ថា កន មានចរិក ក្រអឺតក្រអោង ហើយមាន សេយ្យមានះ ព្រោះ ខ្លួនជាប្អូន របស់ព្រះម្នាងស្នំឯក ហើយ ព្រះរាជាស្រឡាញ់ រាប់អានណាស់ ទ្រង់តែងតែយកចិត្តទុកដាក់នឹងយោបល់ របស់កន វាជួនកាលមានន័យ ផ្ទុយពីព្រះគសិភ័ទ្ទ ជារាជ មាហាគ្រូ ដែលនាំអោយលោក មានការអាក់អន់ចិត្តខ្លាំង

រង់ចាំតែឱកាសដើម្បីនឹងសងសឹក។ ដូច្នោះឯង ពួកសត្រូវនឹងកន តែងតែឆ្លៀតញុះញង់ព្រះរាជា នៅពេលដែលពួកខ្លួនរៀងៗខ្លួន មានឱកាសធ្វើបាន។ យូរថ្ងៃមក ការញុះញង់នោះ វាចាប់មានឥទ្ធិពលទៅលើព្រះរាជា ព្រោះព្រះអង្គ ក៏ហាក់បីមើលឃើញដែរថា កន មានចរិកដូចគេនិយាយមែន ហើយ ថែមទាំងព្រះអង្គ ក៏មានព្រះទ័យច្រណែននឹង ចំណេះ និង រូបសម្បត្តិល្អ របស់កនផង ក៏ចាប់មានព្រះទ័យ ភ័យបារម្ភពីគ្រោះថ្នាក់ដល់ទ្រង់ កើតចេញពីកនថា នឹងអាចដណ្ដើមយករាជបល័ង្កពីព្រះអង្គបាន ព្រោះកនមានប្រជាប្រិយភាពខ្លាំងណាស់ដែរ ជាមួយប្រជារាស្ត្រតូចតាច។ នៅត្រង់ចំណុចនេះ ក៏អាចបញ្ជាក់ថាព្រះស្រីសុគន្ធបទ ជាព្រះមហាក្សត្រ តែងតែមានបារម្ភជានិច្ចអំពីអំពើក្បត់នឹងខ្លួន។ ដូចយ៉ាង បញ្ជាអោយ ព្រះចន្ទរាជា ជាព្រះអនុជ ទៅត្រួតត្រានៅក្រោយខាងលិច ព្រោះមានគោលបំណងតែមួយគត់ គឺមិនចង់អោយព្រះអនុជនៅជិតព្រះអង្គ ក្រែងទ្រង់ នឹងធ្វើរដ្ឋប្រហារដណ្ដើមយក

រាជបល័ង្ក។ រីឯ ព្រះចន្ទរាជា[14] វិញ ទ្រង់យល់ឃើញដូច្នេះឯងនៅក្នុងព្រះចិន្តា ហើយតែងតែមានបារម្ភថា ព្រះរៀមនឹងអាចមាន ឱបាយកល នៅថ្ងៃណាមួយមិនខាន នឹងរលាស់ព្រះអង្គចេញពីវង់អំណាច នៃរាជនគរ ជាពុំខាន ហេតុនេះឯង បានជាព្រះអង្គ មានការប្រុងប្រយ័ត្នណាស់ក្នុងទំនាក់ទំនងជាមួយព្រះរៀម។ ពេលទ្រង់ ចាកចេញពីព្រះរៀមទៅគង់នៅស្រុកភ្នំពេញនៅឆ្នាំ ១៥០៧ ទ្រង់ មានព្រះជន្ម ១១ឆ្នាំ។ គេអាចសួរបានថា តើព្រះចន្ទរាជា មានភាពចាស់ទុំ ដើម្បីត្រួតត្រាដំបន់ខាងលិច នៃព្រះនគរបានដែរឬទេ ?

ឃុនហ្លួងកន កើតនៅឆ្នាំ ១៤៨៣ មានអាយុតិចជាងព្រះសុគន្ធបទ ៤ឆ្នាំ និង ច្រើនជាងព្រះចន្ទរាជា ១៣ឆ្នាំ។ នៅពេលដែល កន បានតែងតាំងជាមន្ត្រីវាំង អ្នកទាំងពីរ ក៏គ្មានទំនាក់ទំនងនឹងគ្នានោះដែរ តែគ្រាន់តែឃើញគ្នាម្តងៗ ទៅវិញទៅមក នៅពេលដែលព្រះចន្ទរាជា យាងមកថ្វាយបង្គំព្រះរៀម តែប៉ុណ្ណោះ ហើយ កន តែងតែថ្វាយបង្គំ

---

14 ព្រះចន្ទរាជា កើតនៅឆ្នាំ ១៤៩៦, ព្រះសុគន្ធបទ កើតនៅឆ្នាំ ១៤៧៩។ ស្តេចទាំងពីរ មានអាយុខុសគ្នា ១៧ ឆ្នាំ។

ព្រះអង្គ តាមរាជប្រវេណី ជាជម្ចតា, ចំណែកខាង ព្រះចន្ទរាជា ទ្រង់មិនសូវយកចិត្តទុកដាក់នឹងកន តែគ្រាន់តែឮគេនិយាយ មិនល្អផង និង គុណសម្បត្តិ ពិសេសខ្លះផង របស់បុគ្គលនុះ។ ហើយព្រះអង្គ ក៏មិនដែលលើករឿងកន ទូលថ្វាយព្រះរាជា, លើកលែង នៅពេលដែលព្រះរាជា ស្នើអោយដោះងារជាពលព្រះ ពីវង្សមាតា របស់កន នៅពេលនោះ ព្រះអង្គ មិនយល់ស្របនឹងព្រះរាជតម្រិះនោះ។ បើកន មានការប្រកាន់នឹងព្រះអង្គ គឺនៅលើចំណុចនេះឯង។

នៅក្នុងព្រះរាជពង្សាវតាខ្មែរ អ្នកនិពន្ធ បែកចែក ដំណើរនៃអំពើបៀតបៀន របស់ព្រះសុគន្ធបទ ទៅលើឃុនហ្លួងកនជាបីដំណាក់កាល : ១. សុបិននិមិត្ត, ២. ចក្ខុនិមិត្ត, ៣. ការប្រព្រឹត្តអំពើឃាតកម្ម។ នៅក្នុងការពិត ដំណើរ នៃអំពើនោះ កើតចេញមកពី គំនិតមមៃ របស់ព្រះរាជា លើអំពើក្បត់ជាទូទៅ ដូចយ៉ាង អំពើក្បត់ព្រះរៀម ឬ ក្បត់ផែនដី របស់ព្រះបិតាទ្រង់ ដែលទ្រង់មានអារម្មណ៍ថានឹងអាចមានកើតឡើងចំពោះព្រះអង្គ។ កន ជាអ្នករងគ្រោះ

ទទួលថ្នូបាក់ម្នាក់ នៃគំនិតមមៃនោះ ព្រោះកនជារំពា[15] ងាយស្រួលមួយ របស់ព្រះសុគន្ធបទ ដ្បិត កន មានសត្រូវជាច្រើន ក្នុងចំណោមអ្នករាជការ នៅក្នុងរាជវាំង។ ចំពោះព្រះអង្គ បៀតបៀន យុនហ្លួងកង វាងាយស្រួលជាងបៀតបៀនព្រះអនុជ ព្រះចន្ទរាជា ព្រោះ កន ជារាស្ត្រ កូនកាត់វង្សពល ចំណែក ព្រះអនុជ វិញ ជាព្រះរាជវង្សានុវង្សមកុដ បើហ៊ានបំពាន វាអាចនឹងនាំមក នូវសេចក្ដីវិនាសដល់ព្រះនគរ ដូចមានកើតសង្គ្រាម ដណ្ដើមរាជ្យគ្នានៅទសវត្សរ៍ ១៤៣៣ រវាង ព្រះបិតា (ព្រះធម្មរាជា) ព្រះជេដ្ឋារបស់ព្រះបិតា (ព្រះសេរីរាជា) និង ក្មួយខ្លួនឯង (ព្រះសុរិយោទ័យ) ជាបុត្រា របស់ព្រះនរាយណ៍រាជា ស្ដេចសុវណ្ណកោដ្ឋ នាំឲបែងចែកនគរជាបីផែនដី។ ដូច្នេះ ការធ្វើឃាតយុនហ្លួងកង ជាវិធានការ សំរាប់បង្ការ ព្រោះកន បើតាមទំនាយ របស់ព្រះសង្ឃសត្ថា ដែលជាគ្រូ របស់កន គឺជាអ្នកមានបុណ្យម្នាក់ អាចនឹងគ្រប់គ្រងនគរបាន។ ទំនាយនេះ វាឮដល់ព្រះសុគន្ធបទ តាមការញុះញង់ពីមន្ត្រី ជាសត្រូវ

---

15 រំពា, ភក្សាហារដែលសត្វកាចពិឃាត ហើយស៊ីបន្តិចម្ដងៗ, proie ។

នឹងកន ហើយ នៅក្នុងព្រះរាជហឫទ័យ នៃព្រះអង្គផងដែរ តាមការពិចារណា របស់ទ្រង់ កន វាអាចធ្វើបានមែន ព្រោះវាមានចំណេះជាអ្នកប្រាជ្ញ និង មានចរិយា ជាអ្នកដឹកនាំ។ ទោះបី កន មានដើមកំណើតជារាស្ត្រ តែ ព្រះសុគន្ធបទ មានអារម្មណ៍ថា វង្សានុវង្ស របស់ទ្រង់ ក៏មានដើមកំណើតពីរាស្ត្រនោះដែរ ជាពង្សាវលី នៃតាត្រសក់ផ្អែមដែលជារាស្ត្រ។

បន្ទាប់ពីហោរាទាយថ្វាយអំពីគ្រោះថ្នាក់ កើតចេញមកពីយុនហ្លួងព្រះស្តេច ព្រះសុគន្ធបទ ក៏បញ្ជាអោយអញ្ជើញ ព្រះស្នំឯក អស់ជំទាវគ្រប់ថ្នាក់ មន្ត្រី សេនាបតី នៅក្នុងព្រះរាចវាំង និង កន ៤ហែព្រះអង្គ ទៅប្រពាតមច្ឆា ក្នុងបឹងនៅវេលាថ្ងៃស្អែក ហើយតម្រូវអោយគ្រប់មនុស្សប្រុស មានសំណាញ់ម្នាក់មួយ។ លុះព្រឹកព្រាងស្វាងស្រេច ក្បួនដង្ហែព្រះទីនាំងនាវា ក៏ចែវ ទៅរកបឹង ដែលព្រះរាជាជ្រើសយក។ ព្រះស្នំឯក មានការសង្ស័យថា ព្រះស្វាមី នឹងមានឧបាយកលអ្វីនឹងធ្វើបាបប្អូន ក៏លួចផ្ញើសំបុត្រសម្ងាត់មួយច្បាប់ដាក់ក្នុងកញ្ចប់បាយ ដើម្បីប្រាប់ប្អូន អោយប្រយ័ត្នមែនទែន ព្រោះគេនឹងសម្លាប់ហើយ បើព្រះរាជាប្រើអោយមុជទឹក ៤ ប្អូនហែលទៅឆ្ងាយ កុំត្រឡប់មកវិញឡើយ។ កន អានសំបុត្រចប់ មានសេចក្តីតូចចិត្តអនេក គិតថា តើអញបានធ្វើអ្វីខុសចំពោះព្រះរាជា ទើបទ្រង់ចង់សម្លាប់ខ្លួន។ ដឹង

ឧបាយកលនេះ កន គិត រកមធ្យោបាយដោះខ្លួន ដោយសង្កេតយ៉ាងម៉ត់ចត់ នូវបរិស្ថាន នៅជុំវិញខ្លួនថា តាមច្រកណា ដែលខ្លួនអាចគេចវេះខ្លួនបាន។ ពេលមួយ ព្រះរាជា នាំទូកមួយចំនួន ចែវចូលទៅដល់អន្លង់មួយ ជ្រៅក្រៃលេងជាងអន្លង់ទាំងពួង មានឫសឈើក៏ច្រើន។ ទៅដល់ទីនោះ មន្ត្រីម្នាក់ បង់សំណាញ់ បន្ទាប់មកស្រែកទូលព្រះរាជាថា ទាញលើកឡើងពុំរួចសោះ។ កន ជាមនុស្សឆ្លាតណាស់ គាត់យល់ដឹងភ្លាមថា នេះឯងជាឧបាយកលសម្លាប់ខ្លួន។ កន សម្លឹងមើលជុំវិញខ្លួន ឃើញថានៅមិនឆ្ងាយពីអន្លង់មរណៈនេះ មានហ្វូងសត្វទាព្រៃច្រើនអនេក មើលទៅពណ៌ខ្មៅព្រាតនៅទីនោះ ហើយចម្ងាយ ក៏ឆ្ងាយល្មមដែលអាចអោយខ្លួន ហែលក្នុងទឹកទៅដល់បាន។ កំពុងតែសញ្ជឹងគិត ស្រាប់តែឮសូរសំនៀងព្រះសុគន្ធបទ បញ្ជាឲខ្លួនមុជទឹកដើម្បីទៅដោះសំណាញ់ពីឫសឈើ។ នៅពេលដែល កន មុជក្នុងទឹកភ្លាម ស្រាប់តែទូករាប់រយ នាំគ្នាចែវចូល ហើយ ពួកមន្ត្រី បង់សំណាញ់គ្របប្រកិន ច្រើនត្រួតជាន់ទៅលើកន។ តែដោយសារកនបានគិតទុកជាមុនពេលដែលខ្លួន មុជជ្រៅភ្លាម ក៏ខំហែលចេញយ៉ាងប្រយាប់ពីទីនោះ។ ត្រូវដឹងថា កន ពូកែហែលទឹកណាស់ តាំងពីកុមាមកម្លេះ ដូច្នេះ ការប្រឹងប្រែងនេះ វាមិនជាការពិបាកដល់ខ្លួននោះឡើយ។ កន ហែលនៅក្នុងទឹក យ៉ាងលឿន

បំផុត សំដៅទៅកន្លែងមានហ្វូងសត្វទាព្រៃ រួចដើរបន្ទុងសន្សឹមៗក្នុងទឹក ងើបតែក្បាល ចេញច្រមុះលើទឹកនៅកណ្ដាលហ្វូងទាព្រៃ កុំអោយវាផ្អើលបាន រួចរត់ដោះទៅជ្រកពួនក្នុងត្រើប[16] ច្រើនមួយអន្លើ ទម្រាំយប់នឹងអាចរត់តទៅទៀត។

យូរបន្តិចមក ព្រះរាជា ទ្រង់អោយស្រាវសំណាញ់ឡើង តែមិនឃើញខ្លួនកន ទ្រង់ក៏អោយយកច្បូក សម ចាក់រកគ្រប់រាម (រូង) ក៏ពុំឃើញទៀត ទើបអោយអ្នកពូកែមុជទឹកឲមុជចុះរកទៀតក៏ពុំឃើញ។ ព្រះអង្គ ទ្រង់ត្រាស់ថា : អានេះរត់រួចទៅ ដូចខ្លារួចពីទ្រុង វាគង់នឹងត្រឡប់មកសងសឹកវិញពុំខានឡើយ។ នៅក្នុងព្រះពង្សាវតាខ្មែរ អភិប្រាយថា សត្វទាព្រៃ នាំគ្នាជួយលាក់បាំងកន ដោយនាំគ្នាទំលើក្បាលកន ព្រោះមាណពនេះ ជាអ្នកមានបុណ្យ ចារទុកនៅក្នុងកាលគត នៃខ្លួន។

---

16 ត្រើប គឺព្រៃដែលកើតលើទឹកដោតស្មៅ ត្រកៀត បបុស ស្បូវដុះលើមមោកចក មមោកកំពីងពួយ។

ព្រះសុគន្ធបទ ទ្រង់ពុំស្បើយព្រះវិតក្ក[17]សោះ ទ្រង់ឲសេនាឯកពីរនាក់ នឹង ទាហានច្រើនកង ទៅល្បាតក្រវែលជុំវិញបឹង ដើម្បីរកចាប់ខ្លួនកន តែពុំបានសម្រេចដូចព្រះចិន្តា នាំអោយព្រះអង្គ កាន់តែព្រួយព្រះហឬទ័យ នៅចំពោះមុខស្ថានការណ៍ដូច្នេះ។ ចំណែកឯ យុនហ្លួងព្រះស្តេច កន វិញ ក្រោយពីបានគេចខ្លួនផុតពីបឹងហើយ ក៏ខំរត់ទាំងយប់ទាំងអាធ្រាត្រតាមគុម្ពព្រៃ ហើយជួបល្បាតពីរដង លើកទី ១ រត់គេចខ្លួនតាមគុម្ពព្រៃ ចេញផុតបាន តែលើកទី២ កនប្រយុទ្ធនឹងមនុស្សល្បាតនោះ រួចសម្លាប់ចោលទៅ។ បន្ទាប់មក បន្តរត់ទៅដល់វត្តស ម្តេចព្រះសង្ឃរាជសត្ថា ដែលជាគ្រូ។ ព្រះសត្ថា ឃើញកន ក៏មានព្រះបន្ទូលថា បា[18] កុំនៅទីនេះឡើយ បើបាឯងចង់អោយរួចភ័យ ចូររបារត់ទៅទិសបូព៌ចុះ តែបីឆ្នាំ បានឹងបានជាធំពុំខានឡើយ។ ស្តេចកន ក៏ក្រាបបង្គំលាព្រះគ្រូ ដើរចេញពីវត្ត ស្រាប់តែជួបនឹងបរិវារ របស់ខ្លួនម្នាក់ ដែលមាតាបិតា ឲដើររកខ្លួន។ ឃើញភ្លាម កន ត្រេកអរណាស់ ក៏ប្រើមនុស្សនោះអោ

17 វិតក្ក : រំពឹងគិត, ជញ្ជឹង។
18 បា ជាពាក្យសំរាប់ហៅកូនប្រុស ឬ អ្នកដែលខ្លួនស្រឡាញ់ដូចកូនខ្លួនឯង។

យទៅយកធ្នូព្រួញសម្រាប់ខ្លួននៅផ្ទះ ហើយប្រមូលអ្នកស្ម័គ្រនឹងខ្លួនបានមួយក្រុម ចំនួន៥០ នាក់ ភាគច្រើនជាទាសករ។ ព្រះស្តេចកន ក៏នាំស្ម័គ្រពួកទាំងនោះ រត់ទៅដល់ស្រុកបាភ្នំ។ ទៅដល់ទីនោះ វេលាព្រលប់ ទាំងអស់គ្នា ក៏ឡើងទៅផ្ទះចៅហ្វាយស្រុក ឃើញគាត់ កំពុងស្តីការរាជការជាមួយសហការីមួយចំនួន កន ក៏ស្រែកថា : មានព្រះរាជឱង្ការ អោយអញមកប្រហារជីវិតឯង ដ្បិតឯងក្បត់ ចូលនឹងចៅពញាចន្ទរាជា។ ថាហើយ កនស្ទុះទៅកាប់ចៅហ្វាយស្រុក ដល់អនិច្ចកម្មទៅ។ អស់ក្រមការ រាស្ត្រប្រជា ក៏ភ្ញាក់ផ្អើលឆោឡោអឹងកង ទើបព្រះស្តេចកន ឧបាយស្រដីថា : ចៅហ្វាយស្រុកនេះ ក្បត់នឹងព្រះស្តេចសោយរាជ្យ ចូលនឹងព្រះចន្ទរាជា ដើម្បីដណ្តើមរាជ្យ។ ដូច្នេះអញមកទីនេះ កេណ្ឌទ័ព តស៊ូប្រឆាំងនឹងអំពើក្បត់ តាមព្រះរាជឱង្ការ ដើម្បីលើកចៅពញាយសរាជា ជាព្រះរាជឱរស ដែលត្រូវជាក្មួយអញ អោយឡើងសោយរាជ្យបន្តពីព្រះបិតាទ្រង់។ អស់អ្នករាល់គ្នា កំគិតរឹកររបារម្តឡើយ ចូរនាំគ្នាយកអាសាពញាយស ជាទាយាទ ហើយបើបានសម្រេចការណ៏ថ្ងៃណា ពេលនោះ គ្រប់ពូជមនុស្ស ដែលទុកជាវណ្ណៈថោទាបជាងគរបំផុត មនុស្សដែលមានទោសធ្ងន់ ទទួលទោសគពូជ នឹង

អោយរួចជាព្រៃងារ[19] នឹងមានសេរីភាពអាចធ្វើអ្វីបានគ្រប់យ៉ាង រហូតអាចឡើងជា មន្ត្រីតាមគុណបំណាច់តិចច្រើន ក្នុងកិច្ចការបំរើការតស៊ូ។

សុរោហារ ឃុនហ្លួងព្រះស្តេច កន កៀងគរបានរាស្ត្រប្រជាជាច្រើន ភាគច្រើនគឺពួកពលព្រះ និង ទេសករ។ កន ក៏រៀបចំទ័ព ចាត់តាំង មេកងតូចធំ មេទ័ព រួចធ្វើការវាយប្រហារសង្កត់ស្រុកតូចធំ រៀងមកដល់ខេត្តព្រៃវែង បណ្តាលអោយ ចៅ ជហ្វាយស្រុកទាំងនោះ ជឿស្តាប់អំណាចខ្លួន។ បន្ទាប់មក កន បន្តវាយយកបានខេត្តមួយចំនួននៅបែបខាងលិច ដែលនៅក្រោមការត្រួតត្រា របស់ព្រះចន្ទរាជា។ ដំណឹងនេះ ត្រូវបាន ពញាវង្សាអគ្គរាជ ជាសេនាបតី ក្រាបបង្គំទូលព្រះសុគន្ធបទ គ្រប់ប្រការ ហើយស្នើសូមអោយព្រះរាជា បង្គាប់អោយព្រះពិជ័យនាគ ជាបិតា របស់កនសរសេរសំបុត្រប្រាបប្រាមទៅកូន អោយចូលមកគាល់ព្រះរាជា។ បើ កន មិនស្តាប់បង្គាប់ សូមយើងលើកទ័ពទៅបង្ក្រាប និង ចាប់វាយកមកធ្វើទោសតាមច្បាប់។ តែវិធីសាស្ត្រនេះ ពុំបានសម្រេចឡើយ ព្រោះកន ឆ្លៀតយកឱកាស

---

19 ព្រៃងារ : មនុស្សអ្នកជាជម្ចាតា។

នោះ ដើម្បីពង្រឹងអំណាចខ្លួនទៅវិញ ដោយប្រើក្រឡេច ទាញយកប្រយោជន៍ គឺថា កន ទទួលរាជបំរើ យកសំបុត្រ បិតាមកអោយខ្លួន តាមរាជប្រពៃណី គឺ ចេញមកទទួល យក ក្រាបថ្វាយបង្គំបីដង តែមិនអាននៅចំពោះមុខពួក រាជបំរើ និង សហការី របស់ខ្លួននោះឡើយ។ កន អានជា សម្ងាត់ រួចឆ្លើយប្រាប់ក្លែងទៅនឹងរាជបម្រើថា : អាយជំ រាប មាតាបិតា និង បងស្រី ថា ទុកពេលវេលាអោយខ្លួន រំសាយទ័ពសិន រួចខ្លួននឹងចូលទៅជាក្រោយ។ តែនៅពេល រាជបម្រើ រៀបនឹងចេញដំណើរវិលត្រឡប់ទៅរាជធានីវិញ កន ធ្វើជារត់តាមស្រែកផ្តាំអោយ បរិវារ និង មនុស្សមក ឈរមើលកកកុំ ឮថា : អោយលោក ឪពុក និង អ្នកបង ក្រាបទូលការណ៍នេះដល់ព្រះរាជាផងថា ជិតបានសម្រេច ហើយ ខ្ញុំនឹងលើកទៅឆាប់ហើយ អោយទ្រង់ទុកព្រះរាជ ហឫទ័យចុះ។ អ្នកឯងមកឃើញមនុស្សម្នាមកកកកុំនឹង ភ្ញែកហើយ។

ពួករាជបំរើ ឮដូច្នេះ តែមិនយល់ន័យអ្វីនោះឡើយ មនុស្ស ដទៃទៀតណៅទីនោះ បានឮ ក៏នាំនឹកស្មានថាព្រះរាជា អោយរាជបំរើ យកចុតហ្មាយ ក្នុងនោះ មានរាជបញ្ជាថ្មី ទៀតដល់យុនហ្លួងព្រះស្តេច អោយអនុវត្ត ដូច្នេះក៏នាំគ្នា កាន់តែជឿកនគ្រប់បែបយ៉ាងថា យុននេះ ជាអ្នកបម្រើ ពិសេស របស់ព្រះមហាក្សត្រ ដើម្បី ប្រឆាំងនឹងពញាចន្ទ

ដែលជាជនក្បត់។ បន្ទាប់មក ឃុនកន ប្រកាសសារត្រា ជំរាបដល់សាធារណជន ថា ព្រះមហាក្សត្រ បញ្ជាអោយឈ្មោះណា ចាប់ចៅពញាចន្ទរាជាបាន នឹងទទួលអោយលើកយសសក្តិអ្នកនោះ ជានាម៉ឺនធំ។ អស់ក្រមការ និង ប្រជារាស្ត្រ បានឃើញសំបុត្រការប្រកាសហើយ ក៏នាំគ្នាចុះចូលទទួលអាសាជាច្រើន។

ពួករាជបំរើ កាលមកដល់ព្រះបរមរាជវាំងវិញ ក៏ប្រយ៉ាប់ឡើងគាល់ព្រះរាជា ទូលថ្វាយថា ឃុនហ្លួងព្រះស្តេច ព្រមធ្វើតាមអស់ហើយ គ្រាន់តែសូមពន្យាពេលវេលា នឹងចូលខ្លួនមកបំរើព្រះអង្គជាថ្មី។ ព្រះរាជាឮសព្វគ្រប់ហើយ ក៏ស្មានថាជាការពិតមែន ទ្រង់ពុំបានអោយកេណ្ឌកងទ័ពទៅបង្ក្រាប កន ថែមទាំងបង្គាប់អោយព្រះស្នំឯក អោយចាត់បម្រើស្រីស្អាតៗ ទៅស្តីលួងលោមព្រះស្តេចកន អោយឆាប់ កុំបង្អង់អោយយឺតយូរឡើយ កុំអោយព្រះរាជាដូរព្រះទ័យ ហើយនាំអោយមានកើតសង្គ្រាមនៅក្នុងនគរ។ កន រួមរ័កជាមួយស្រីទាំងនោះរួច អោយវិលត្រឡប់ទៅប្រាប់បងស្រី អោយទូលថ្វាយព្រះរាជាថា ខ្លួននឹងត្រឡប់ទៅស្រុកវិញ ប្រហែលជាខែក្រោយ។

ឧបាយសឹកបែបនេះ អាចទាញបានប្រយោជន៍បីយ៉ាង :
១. ឃុនកន អាចពន្យារពេលអោយបានយូរការវាយលុក

របស់ទ័ពហ្លួង មកលើកងទ័ពខ្លួន ដែលជាពេលវេលាទុកឱកាសអោយខ្លួន មានពេលគ្រប់គ្រាន់នឹងពង្រឹង និងពង្រេច ដែនដី និង អំណាច នៅតំបន់ខាងលិច; ២. រំគាយឥទ្ធិពលព្រះចន្ទរាជា និង ខាយាំងព្រះអង្គ កុំអោយអាចធ្វើសម្ពន្ធភាព ជាមួយនឹង ព្រះជេដ្ឋាបាន ដោយបង្កើត ជម្លោះតាមផ្លូវចិត្ត រវាងបងនិងប្អូន ដោយលើកយកអំពើក្បត់នឹងរាជបល័ង្ក ដើម្បីបង្ខូចកិត្យានុភាពព្រះអង្គ។

ក្នុងរយៈពេលនោះដែរ ព្រះស្តេចកន កេណ្ឌអាណាប្រជានុរាស្ត្រ អោយចូលធ្វើទាហានបានកាត់តែច្រើន បើកមណ្ឌលហ្វឹកហ្វើនយោធានៅគ្រប់ស្រុកតូចធំ ដើម្បីបំរុងវាយព្រះរាជវាំងថៅបញ្ញាចន្ទរាជា ចាប់ព្រះអង្គ ថ្វាយព្រះជេដ្ឋា។ ដំណឹងនេះឮដល់ព្រះចន្ទរាជា ទ្រង់កោះប្រជុំមន្ត្រី សេនាធំតូច ហើយទ្រង់ត្រាស់ថា រឿងនេះ វាអាចជារឿងពិត ព្រោះព្រះជេដ្ឋាធិរាជ ហាក់បីទើសទាល់នឹងព្រះអង្គណាស់តាំងពីដើមមក ដូចយ៉ាង បញ្ជាអោយទ្រង់ អោយមកនៅឆ្ងាយពីព្រះអង្គ ហើយមកដល់ពេលនេះ មិនដែលបានទទួលរាជចុតហ្មាយពីព្រះជេដ្ឋាធិរាជ ថ្វាយដំណឹង អំពីស្ថានការណ៍នគរ ដែលកំពុងកើតឡើង អោយទ្រង់ធ្វើបែបណា។ ដូច្នេះកុំបង្កើតបញ្ហាបន្តទៅមុខទៀត មានតែអញ ចាកចេញពីស្រុកខ្មែរ ទៅសូមជ្រកកោន ក្រោមបារមីព្រះថៅ

ក្រុងទេពបុរី ទើបអាចបញ្ចប់បញ្ហាព្រះនគរបាន។ ព្រះចិន្តារូច ព្រះអង្គប្រមូលខ្ញុំបំរើ និង សេនា មានស្វាមីភក្តិនឹងព្រះអង្គ បាន ៥០ នាក់ ហើយក៏នាំគ្នាចាកចេញពីក្រុងចតុម្មុកទាំងរាត្រី។ នៅពេលនោះ ព្រះចន្ទរាជា មានជន្មាយុ ១៨វស្សា, ឃុនហ្លួងព្រះស្តេចកន មានជន្មាយុ ២៧ វស្សា ចំណែកព្រះសុគន្ធបទ ព្រះអង្គ មានជន្មាយុ ៣២ វស្សា។



រូបចម្លាក់តាមឿង នៅខេត្តពោសាត់ បច្ចុប្បន្ន

## ការរត់គេចខ្លួន នៃចៅពញាចន្ទរាជា

គួរលើកយកមកពិចារណា អំពីការជម្រុញចិត្ត របស់ចៅបញាចន្ទរាជាទៅស្រុកសៀម។ ក្នុងព្រះរាជពង្សាវតាខ្មែរ ដូចបានជំរាបខាងលើនេះ គេសេសេរថាព្រះចន្ទរាជា ទ្រង់ចាកចេញពីស្រុក ដើម្បីដោះស្រាយ នូវបញ្ហា ដែលព្រះជេដ្ឋាធិរាជ មានអារម្មណ៏មកលើព្រះអង្គ។ គំនិតនេះ វាហាក់បីគ្មានភាពប្រាកដ ព្រោះព្រះចន្ទរាជា អាចរកការបំភ្លឺបានពីព្រះរៀម អំពីការសង្ស័យនៅក្នុងព្រះចិន្តាថា រឿងកនប្រឌិត តើវាជាការពិតមែនឬទេ។ ចុះហេតុអ្វី ក៏ព្រះអង្គនៅសៀម ថែមទាំងមិនព្រម តស៊ូប្រឆាំងនឹងកន បន្ថិចបន្តួចសោះ ដើម្បី យកការពិតទៅថ្វាយព្រះជេដ្ឋាធិរាជ។ តាំងពីព្រះចន្ទរាជា យាងទៅរស់នៅក្រោយខាងលិចតាមព្រះរាជបញ្ជា ពេលនោះទ្រង់មានជន្មាយុ ១១ឆ្នាំ ចំណែកព្រះជេដ្ឋា មានជន្មាយុ ២៨ឆ្នាំ។ បង និង ប្អូន មានចំណាស់ខុសគ្នាដល់ទៅ១៧ឆ្នាំ ហើយស្ថិតនៅឆ្ងាយពីគ្នាផង ដូច្នេះមិនសូវមានការរាប់អានគ្នាច្រើននោះឡើយ។ អារម្មណ៏ នៃសាច់ញាតិ វាផ្ដាប់គ្នានៅត្រឹមតែ តំណជីវសាស្រ្ត ហើយអវត្តមាន នៃសេចក្ដីស្រឡាញ់ ដែលនាំអោយបង និង ប្អូនគ្មាន ការសន្ទនាស្មោះពិតនិងគ្នា និង ជាជម្រៅ។ ព្រះសុគន្ធបទ មានចំណាស់ច្រើនណាស់ជាងប្អូន ទ្រង់ត្រូវការតែការស្ដាប់បង្គាប់ ដាច់ខាតពីប្អូន រីឯ ប្អូន វិញ ស្គាល់តែ

---

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

អំណាចផ្តាច់ការរបស់បង ជាព្រះរៀមមកុដ និង បន្ទាប់មកជាព្រះមហាក្សត្រ តែប៉ុណ្ណោះ។ លក្ខខណ្ឌទាំងនោះហើយ នាំអោយញាតិខាងមាតា និង បក្ខពួកចាស់ក្មេង របស់ព្រះចន្ទរាជា មានការបារម្ភថា ព្រះសុគន្ធបទ ថ្ងៃណាមួយនឹង ទ្រង់ប្រើឧបាយកល កំចាត់ប្អូនម្តាយខុសគ្នា ជាពុំខាន ព្រោះមិនចង់អោយមាន ស្តេចមកុដណាមួយផ្សេង នៅក្នុងព្រះរាជវង្សានុវង្ស ក្រៅពីព្រះរាជបុត្រមកុដតែមួយ របស់ព្រះអង្គ គឺ ពញាយស ដែលត្រូវជា ក្មួយនឹងយុនហ្លួងព្រះស្តេចកនផង។ ជាពិសេសនៅក្នុងព្រះរាជវង្សានុវង្សភាគច្រើន មានគំនិត ពិបាកនឹងយល់ព្រមអោយពញាយស ឡើងសោយរាជ្យ ព្រោះ បញាយស មានម្តាយជាកូនកាត់ព្រៃងារ[20] ដែលវានាំអោយខូចកិត្យានុភាព ដល់ព្រះរាជបល័ង្ក។ គំនិត ស្តេចយាងទៅស្រុកសៀម[21] ដើម្បី ស្វែងរកអនាគត វាមានរួចមកហើយនៅក្នុងព្រះរាជវាំង របស់ព្រះចន្ទរាជា ដើម្បី ការពារជាមុននឹងល្បិចខ្មៅ របស់ព្រះ

20 ព្រៃងារ : មនុស្សរស់នៅក្នុងទាសភាព។
21 ព្រះចន្ទរាជា ឆ្នាំ (ប្រហែលជាឆ្នាំ ១៥០៩ ឬ ១៥១០) ដែលព្រះអង្គរត់ទៅស្រុកសៀម ទ្រង់មានជន្មាយុ រវាង ១៣ និង ១៤ ព្រះវស្សា។

សុគន្ធបទ តែវាគ្រាន់តែ គ្មានឱកាសអំណោយផលតែប៉ុណ្ណោះ។ ដូច្នេះ កោលាហល របស់ឃុនហ្លួនព្រះស្តេចកន វាបើកផ្លូវល្អដល់បក្ខពួកព្រះចន្ទរាជា អាចនាំទ្រង់ រត់ទៅស្រុកសៀម ហើយមាន លេសាបទេស[22] គ្រប់គ្រាន់ នឹងស្នើពឹងផ្អែកព្រះចៅក្រុងទេព អោយជួយដោះស្រាយបញ្ហារាជបល័ង្ក ដែលវានឹងអាចមានកើតឡើងនៅពេលអនាគត ព្រោះគេដឹងច្បាស់ថា ព្រះសុគន្ធបទ មិនអាចច្បាំងឈ្នះស្តេចកន ហើយនរៈនេះ ឬក៏ឡើងសោយរាជសម្បត្តិខ្លួនឯង ឬក៏ប្រគល់ រាជសម្បត្តិអោយ ពញាយស ជាក្មួយ។ ចំណែកព្រះចន្ទរាជា ទ្រង់នៅក្មេងណាស់ មិនអាចមានលទ្ធភាពតតាំងនឹងស្តេចកនបានដែរ។ នៅពេលដែល ស្តេចកនមានវិវាទ ជាមួយនឹងព្រះសុគន្ធបទ នៅឆ្នាំ ១៥០៩ ឬ ១៥១០ ព្រះចន្ទរាជា មានជន្មាយុ ១៤ឆ្នាំ ដូច្នេះ ទ្រង់គ្មានប្រជាប្រិយភាព នៅក្នុងនគរ និង នៅក្នុងដែនដីនៅក្រោមការត្រួតត្រា របស់ព្រះអង្គនៅឡើយ។ តតាំងនឹងស្តេចកនក្នុងលក្ខខណ្ឌបែបនេះ គឺទុកជា ផ្ញើអត្តឃាតកម្ម

22 លេសាបទេស : ការអាងលេស។

នោះឯង។ ដូច្នេះ រត់ទៅស្រុកសៀម វាអាចទុកជាផ្លូវអនាគតមួយ សំរាប់បក្ខពួក របស់ព្រះកុមារចន្ទរាជា[23]។

ត្រូវដឹងទៀតដែរថា ព្រះសុគន្ធបទ មិនដែលថ្វាយជូនដំណឹង អ្វីបន្តិចបន្តួចសោះដល់ព្រះអនុជ អំពីកោលាហលរបស់កន ព្រោះទ្រង់ ទុកព្រះអនុជ នៅជាកុមារនៅឡើយ ហើយទ្រង់ គ្មានទម្លាប់នឹងពិភាក្សា កិច្ចការព្រះនគរអ្វីជាមួយប្អូននោះដែរ។

ដំណើរព្រះចន្ទរាជា មកដល់ខេត្តពោសាត់ ទ្រង់ក៏ចូលទៅសំណាក់អាស្រ័យនៅផ្ទះមេស្រឹងភ្នំក្រវាញ មានឈ្មោះ « ខ្លាងមឿង[24] »។ តាមឿង ទទួលព្រះចន្ទរាជា តាមទម្លាប់អ្នកស្រែ ប្រើភាសារាស្ត្រ ព្រោះគាត់មិនសូវដឹង នូវទំនៀមទម្លាប់ស្តេច។ ទោះបីយ៉ាងនេះក៏ដោយ ក៏ព្រះចន្ទរាជា មាន

---

23 នៅក្នុងព្រះរាជពង្សាវតាខ្មែរ សរសេរថា នៅពេលដែលព្រះចន្ទរាជា រត់ទៅស្រុកសៀម ទ្រង់មានព្រះជន្ម ២៤ វស្សា។ អាយុនេះ វាមិនអាចជាការពិតបាននោះឡើយ បើយោងទៅតាមឆ្នាំកំណើតរបស់ព្រះចន្ទរាជា។

24 ខ្លាងមឿង តែខ្មែរយើង ហៅតាមវាយារៗ មកជា ឃ្លាំងមឿង។ នៅក្នុងសាស្ត្រាវត្តកំពង់ត្រឡាចក្រោម គេសរសេរថា តាមឿងនេះ មិនមែនឈ្មោះមឿងនោះទេ គឺគាត់មានឈ្មោះជា ពេជ ដូច្នេះទៅវិញ។

អំណរណាស់ នូវការស្វាគមន៍សមញ្ញនោះ ហើយព្រះអង្គបានរៀបរាប់រឿង ដែលនាំអោយទ្រង់គេចខ្លួនចេញពីព្រះនគរ។ តាមឿង សង្វេគណាស់ ព្រោះឃើញព្រះចន្ទរាជា នៅជាកុមារ ជាព្រះអនុជ តែត្រូវរត់ចោលនគរដូច្នោះ។ បន្ទាប់ពីដឹងហេតុគ្រប់ប្រការ តាមឿង គាត់ក្រាបថ្វាយបង្គំព្រះចន្ទរាជា រួចថ្លែងថា នឹងថ្វាយដំរី ៨ សេះ ១០ និង កូនប្រុសបួននាក់ តាមហែរថែរក្សាស្ដេចទៅក្រុងទេព។ លុះព្រឹកឡើង ព្រះចន្ទរាជា លាតាមឿង និង គ្រួសារ បន្តដំណើរទៅទីក្រុងទេព។ លុះមកដល់ទីដៅហើយ ព្រះអង្គ ក៏អោយមន្ត្រីសៀម នាំឡើងក្រាបបង្គំទូល ព្រះចៅចក្រពត្តិតាមដំណើរគ្រប់ប្រការ។ ព្រះចៅសៀម ត្រាស់តបថា ព្រះអង្គនឹងជួយទំនុកបម្រុងដល់ទ្រង់ និង បក្ខពួក នូវគ្រប់សេចក្ដីត្រូវការនៃជីវិត ហើយអោយរៀបចំដំណាក់ថ្វាយស្ដេចខ្មែរនៅខាងវត្តប្រណែងធឿន អោយគង់នៅជាមួយបរិវារ ជាសុខរៀងមក។

ការរត់គេចខ្លួន នៃចៅពញាចន្ទរាជា លេចឮដល់កនហើយគាត់ក៏អរណាស់ ព្រោះគាត់ ក៏មានការញញើតខ្លាំងដែរនឹងបក្ខពួកពញាចន្ទរាជា ព្រោះពួកនេះ ក៏មានឈ្មោះល្បីល្បាញខាងសិល្បៈគុណ ជាពិសេស ជាអ្នកជំនាញម្នាក់ខាងទាក់ដំរី។ ដូច្នេះ ការភៀសខ្លួន របស់ក្រុមនេះទៅស្រុកសៀម វាជាការបើកទ្វារចំហរ ដល់គំនិតសងសឹង របស់កន

ចំពោះព្រះរាជា។ យុទ្ធហ្លួងព្រះស្តេច មិនបង្អង់គំនិតនេះទេ ក៏ប្រមូលរេហ៍ពល ទៅបោះនៅចុងខេត្តស្រីសឈរ ក្នុងដែនព្រះនគរហ្លួងស្តេចគ្រងរាជ្យ។ ដឹងដំណឹងនេះភ្លាម ព្រះករុណា ទ្រង់ខ្វាល់ណាស់ ក៏ត្រាស់បញ្ជាអោយកែនពលបានចំនួន ជាងប្រាំពាន់ប្លាយនាក់ ហើយបញ្ជាឲសេនា ទៅប្រាប់ព្រះអនុជ អោយកេណ្ឌទ័ព សំរាប់ជួយព្រះអង្គផងតែមន្ត្រី ថ្វាយដំណឹងថា ព្រះចន្ទរាជា រត់ទៅស្រុកសៀមបាត់ទៅហើយ ព្រោះកន ប្រមូលកងទ័ព លើកទៅលុកព្រះអង្គ។ ព្រះករុណា ទ្រង់ស្តាយណាស់ ត្រាស់ថា មិនគួរជាប្អូនមិនសួរបងសិន មិនគួររត់ចោលអោយបងព្រួយដល់ម្លេះ។

មេទ័ពស្រួច របស់ទ័ពហ្លួង មានចំនួនមួយពាន់នាក់ ដឹកនាំដោយ ចៅពញាយោធាសង្គ្រាម ដើរទៅរកខ្មាំងរាជ្យជួបប្រទះនឹងទ័ពកន ពេលនោះ ចៅពញាយោធាសង្គ្រាម បរដំរីចេញមុខកងទ័ព រួចស្រែកថា : យើងអ្នកព្រះស្តេច ម្តេចក៏អ្នកឯហមិនកោតក្រែងព្រះចេស្តាសោះ។ បំណាច់ទ្រង់ ព្រះមេត្តាប្រោសអ្នកឯងដល់ម្លេះ ម្តេចក៏ហ៊ានក្បត់ប្រព្រឹត្តអកតញ្ញូនឹងព្រះមហាករុណាទិគុណយ៉ាងនេះ។ ព្រះស្តេចកន ឮហើយគិតថា : បើអញនឹងបើកអោយចៅពញានិយាយវែងទៅទៀត ក្រែងកងទ័ពយល់ថាខ្លួនជាមនុស្សក្បត់ ពុំមែនជាត្រាស់ប្រើទេ ទើនឆ្លើយថា : អ្នកឯងកុំនិយាយការអ្វី ជាជ្រៅខាងក្នុងនោះអោយសោះ ទ្រង់ព្រះប

ណ្តាំនឹងខ្លួនខ្ញុំសព្វគ្រប់ហើយ។ ឆ្លើយចប់ហើយ ក៏យឹតធ្នូបាញ់ទៅត្រូវដើមក ចៅពញា ក៏ធ្លាក់ពីដំរីស្លាប់មួយរំពេជ។ កងទ័ពឃើញនាយបរាជ័យហើយ ក៏នាំគ្នារត់ទៅរកកងទ័ពធំមានចំនួនទហានពីរពាន់ដឹកនាំដោយចៅពញាចក្រី។ មេទ័ពនោះ គ្មានរញ់រា ក៏បញ្ជាអោយទ័ពចូលវាយប្រហារកងទ័ពកនភ្លាម តែទប់មិនឈ្នះនឹងការវាយតបវិញ ក៏បកសំបុត្រ ចាត់បម្រើអោយចូលសុំកងទ័ពជំនួយថែមទៀតពីព្រះរាជា។ ចៅពញាយមរាជ ជាអ្នកយុទ្ធសាស្ត្រនៃកងទ័ព ជូនយោបល់ដល់ព្រះករុណាថា បើយកកងទ័ពល្បាត មានចំនួន មួយពាន់នាក់ ទៅជួយច្បាំង មិនសួនការណ៍ នឹងទទួលតនឹងទ័ពធំ របស់កនបាននោះឡើយ ដូច្នេះគួរព្រះអង្គដកថយទៅឯក្រុងចតុម្មុខសិន ដើម្បីកេណ្ឌទ័ពបន្ថែមនៅក្រោយខាងលិច ហើយ ខ្លួនខ្ញុំ និងសេនាទាំងឡាយ នឹងយកអាសាការ ការដកថយនេះ កុំអោយទ័ពព្រះស្តេចកន តាមវាយប្រហារបាន។ ក្រោយបន្តិចមក ព្រះពិជ័យនាគ ដែលជាបិតាព្រះស្តេចកន យកសេចក្តីក្រាបបង្គំទូលព្រះរាជាថា : ខ្លួនសុំទ័ព ១ពាន់នាក់ចេញទៅតដៃនឹងកូនខ្លួន ថាបើខ្លួនប្រែចិត្តក្បត់ជាមួយកូន វិញ សូមទទួលព្រះបង្គន់ ស្លាប់តែនឹងត្រូវគ្រឿងសស្ត្រាវុធ ហើយសូមអោយសម្លាប់ភរិយាញាតិសន្តានទូលព្រះបង្គំជាខ្ញុំទាំងអស់តាមសព្វព្រះរាជហឫទ័យ។ សំណើរនេះ ត្រូវ

បានព្រះរាជាអនុញ្ញាត ព្រោះព្រះអង្គនឹកក្នុងចិត្តថា វានឹងអាចមានប្រយោជន៍ ដ្បិតកន វាគោរពបិតាណាស់ ដូច្នេះអាចឱពុក ពន្យល់កូនបាន អំពីកម្មវិបាក នៃសង្គ្រាម បើនៅតែបន្តទៀត។ មួយទៀត ក៏វាអាចនឹងពន្យារពេលអោយបានយូរ នូវការដេញតាម របស់កងទ័ព របស់កន តាមវាយប្រហារកងទ័ពហ្លួង។

ដូចតាមការស្នើ របស់ចៅពញាយមរាជ ព្រះស្តេចគ្រងរាជ្យក៏ចាកចេញពីសមរភូមិមុខ ឆ្លងទូក ជាមួយអស់គ្រូហ្លួង និង គ្រប់គ្រួខ្ញុំរាជាផ្ទាល់ ទៅក្រុងចតុម្មុខ។ ព្រះអង្គឈប់មួយរយៈនៅបន្ទាយលង្វែក ហើយនៅទីនោះ ទ្រង់អោយកេណ្ឌទ័ពបានចំនួន ២៥ពាន់នាក់។ ចំណែក ចៅពញាយមរាជ វិញ លុះឃើញទ័ពហ្លួង ចេញផុតទៅ ក៏រៀបចំក្បួនទ័ព ដើម្បីតតាំងនឹងការវាយប្រហារ របស់ស្តេចកន តែចាំបាត់ៗ មិនឃើញវាយប្រហារសោះ ក៏សំរេចចិត្តថយទព័តាមហែទ័ពព្រះរាជាពីចម្ងាយ រហូតមកដល់ស្រុកភ្នំពេញ។ និយាយអំពី ចៅពញាចក្រី មេទ័ពស្រួច របស់ទ័ពព្រះនគរដែលប្រឈមមុខនឹងទ័ពធំ របស់កន នៅរង់ចាំជំនួយទ័ពដែលបាន ស្នើសូមទៅទីបញ្ជាការជាន់ខ្ពស់ តែមិនឃើញមកដល់សោះ មិនតែប៉ុណ្ណោះ ក៏គ្មានដំណឹងអ្វីសោះពីយុទ្ធសាស្ត្រថយទ័ព។ ចំណែក ឃុនកន វិញ ដឹងដំណឹង អំពីការថយទ័ពហ្លួងភ្លាម ក៏បញ្ជាអោយទ័ព វាយទីតាំងចៅបញា

ចក្រី រហូតបែកទ័ព ហើយសម្លាប់ មេទ័ពនោះចោលទៅ។ យើងឃើញថា យុទ្ធសាស្រ្ត ថយទ័ពនេះ ចៅពញាយមរាជ លោកបោះបង់ បញ្ចក្រី ជាមិត្តរួមអាវុធ ទុកមរណៈភាព ជាការការពារ ព្រោះបើនឹងប្រាប់អោយថយទ័ពជាមួយគ្នា ច្បាស់ជាយុនកន តាមវាយប្រហារភ្លាម ហើយនឹងអាច ដេញទាន់ ទ័ពហ្លួង ហើយនឹងអាចចាប់បានព្រះរាជាជាពុំខាន ព្រោះទ័ពយុនកន មានចំនួនច្រើនណាស់ ប្រមាណ ៥ ម៉ឺននាក់ លើសទ័ពហ្លួង ដប់ដង។ បន្ទាប់មក យុនកន បញ្ជាទ័ព អោយដេញតាមទ័ពហ្លួង រហូតដល់ព្រះនគរ នៅស្រុកបាសានតែវាឃើតពេលបន្តិចមិនតែប៉ុណ្ណោះ ស្រាប់តែ ប្រទះនឹង ទ័ពបិតាខ្លួន។ យុនកន ឃើញបិតា ក៏ចុះពីសេះ ឈរនៅស្ងៀម ចាំស្តាប់ឳពុកនិយាយ តែឈរគិតបន្តិច មក ក៏បញ្ជាអោយទាហាន ចូលទៅចាប់បិតា តែកុំបីធ្វើ អោយសៅហ្មងដល់រូបកាយលោក។ ទ័ពព្រះជ័យនាគ ឃើញ ទ័ពយុនកន ចូលមកចាប់មេខ្លួន ក៏វាយប្រហារតភ្លាម តែ ដោយសារចំនួនខ្លួនតិចជាង ក៏ទទួលបរាជ័យមួយរំពេច ទៅ។ តែទ័ពដែលនៅសល់ ក៏នាំពិជ័យនាគ រត់ចូលក្នុងព្រះ នគរ រួចនាំគ្នារត់ទៅជ្រកកោនក្នុងវត្តស្ទឹងធំ ដែលមានព្រះ សគ្គា ជាគ្រូ របស់យុនកន គង់នៅ។ យុនកន ដេញតាម មកដល់មុខវត្ត តែប្រទះនឹងព្រះគ្រូ ក៏ចុះពីសេះ មកសំពះ គ្រូ ខណៈនោះ ព្រះគ្រូនិយាយទៅកាន់សិស្សថា : កូនឯងធ្វើ

ដូច្នេះ មិនល្អទេ ព្រោះបិតាជាអ្នកមានគុណ ដូច្នេះ ជាមថម កូនឯងត្រូវចូលទៅសូមទោសបិតាសិន មុននឹងពិគ្រោះ អោយអស់អាថ៌សេចក្តី រវាង ឪពុក និង កូន។ កូនឯងជាអ្នកមានបុណ្យ នឹងទៅជាព្រះមហាក្សត្រ ក្នុងកម្ពុជានេះហើយ ដូច្នេះត្រូវមានកតញ្ញូតាចំពោះបិតា ទើបគេទុកជាក្សត្រ មានគុណធម៌។ ឮដូច្នេះ ព្រះពិជ័យនាគ ឆ្លើយថា : បើសម្តេចមានបន្ទូលដូច្នេះ បុត្រ ភរិយា ញាតិសន្តានរបស់ខ្ញុំព្រះករុណា មិនស្លាប់អស់ហើយឬ ? ថាហើយ ពិជ័យនាគ ក៏ស្ទុះទៅនឹងកាប់ព្រះស្តេចកន តែត្រូវ ក្រុមអង្គរក្សព្រួតគ្នាចូលដណ្តើមចាប់យកដាវពីដៃព្រះពិជ័យនាគ។

បន្ទាប់មក សម្តេចព្រះគ្រូ នាំព្រះពិជ័យនាគ យកទៅទុកក្នុងព្រះវិហារ។ ក្រោយនោះ ព្រះអង្គ មានថេរវាចា អោយបិតា និង បុត្រ សះជានឹងគ្នាទៅ។ លុះផ្សះផ្សាស្រេចហើយ សម្តេចព្រះគ្រូ រៀបចំ ពិធីស្រោចទឹក ចំរើនជ័យមង្គលសិរីសួស្តី អោយយកគ្រឿងអាវុធមកប្រគងប្រកល់កំពស់ស្មើក្បាលមនុស្ស ហើយអោយ បិតា និង បុត្រ ឡើងលើគំនរអាវុធទាំងពីរនាក់ ធ្វើសច្ចាធិដ្ឋានថា រួមកម្លាំងគ្នា ជាបិតា និង បុត្រ អស់មួយជីវិត។ ចប់ពិធីស្រេចហើយ សម្តេចព្រះគ្រូ ឲយក អាវុធនោះទៅកប់ ហើយយកដីលុបពីលើ ធ្វើជាថ្នល់ ចេញពីព្រះវិហារ ហើយប្រែឈ្មោះវត្ត អោយឈ្មោះថ្មីថា វត្តព្រះថ្នល់ រៀងមកដល់ឥឡូវនេះ។

**និព័ន្ធដោយ ឧប សៅ សង្ខា**
**ឆ្នាំ ២០១៥**



រូបចម្លាក់នៃសង្គ្រាមនៅស្រុកខ្មែរ ជំនាន់មហានគរ

## សង្គ្រាម រវាង កងទ័ពហ្លួង និង ស្ដេចកន

លុះចូលកាន់កាប់រាជធានីបានរួចហើយ ស្ដេចកន ឲកេណ្ឌទ័ព និង សង្កត់ខេត្តធំតូច នៅក្រោយខាងកើតទាំងអស់ហើយ អោយលើកទ័ពជើងគោក ជើងទឹក សន្ធឹកមហិមាឆ្លងទន្លេមេកុង ទៅវាយបន្ទាយភ្នំពេញ ជាពន្លាជ័យ របស់ព្រះរាជាគង់។ ព្រះសុគន្ធបទ បញ្ជាអោយកងទ័ព វាយប្រហារតបយ៉ាងស្វិតស្វាញនឹងកងទ័ពស្ដេចកន អស់រយៈពេលបីថ្ងៃ តែគ្មានខាងណា ចាញ់ឈ្នះគ្នាសោះ។ ឃើញស្ថានភាពដូច្នោះ ស្ដេចកន យល់ឃើញថា បើបន្តវាយបង្ខំចំមុខវាគ្មានប្រៀបលើសត្រូវបានឡើយ ព្រោះទ័ពហ្លួងរបឹងរឹងរូសណាស់ ដូច្នេះ ត្រូវដូរយុទ្ធសាស្រ្តថ្មី : វាយពីរកន្លែងសឹក,ទិសខាងត្បូង និង ទិសខាងលិច។ ពេលនោះ កងទ័ពព្រះស្ដេចកន មានចំនួនទាហាន ១២ពាន់នាក់ ជល់ដៃនឹងកងទ័ពហ្លួន មានចំនួនតែ ៣០ពាន់នាក់ប៉ុណ្ណោះ។ ស្ថានភាពមិនល្អបែបនេះ នាំអោយទាហានហ្លួង ចេះតែរត់រាមិនហានបន្តទទួលច្បាំង។ នៅពេលដែលស្ដេចកននាំទ័ពឆ្លងទន្លេដើម្បីប្តូរយុទ្ធសាស្រ្ត ព្រះសុគន្ធបទ ឆ្លៀតឱកាសដែរនាំទ័ពគេចចេញពី បន្ទាយភ្នំពេញតាមទិសខាងលិច ដើរតាមដងទន្លេសាប ឆ្លងកាត់ស្រុកព្រែកព្នៅ, ស្រុកព្រែកតាទែន និង វិហារលួង សព្វថ្ងៃនេះ ទៅតាំងទីនៅខេត្តលង្វែក ហើយអោយនាំគ្រួសារ របស់ព្រះអង្គ និង អស់

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

ទាហាន ទៅរង់ចាំនៅសំរោងសែន ដែនខេត្តអាសន្ទុក[25]។ បន្ទាប់មកព្រះអង្គ បញ្ជាអោយនាយកង ទៅកេណ្ឌទ័ពនៅខេត្តកំពង់ធំ កំពង់ឆ្នាំង បានទាហានមួយចំនួនក្រែល។ ព្រះស្តេចកន ក្រោពី បានរៀបពលជាថ្មីរួចស្រេច ក៏បញ្ជាអោយ កងទ័ពចូលវាយ បន្ទាយភ្នំពេញ បែកមួយរំពេចព្រោះបន្ទាយនេះ មានកងទាហានការពារតិចតួចណាស់ គឺគ្រាន់តែ សំរាប់បង្ហែរឱកាស អោយទ័ពហ្លួងធំ ដកថយងាយស្រួលតែប៉ុណ្ណោះ។ ជ័យជំនះនេះ អាចអោយស្តេចកនសង្កត់បានខេត្តខាងលិច និង នារតី ជាច្រើន ដូចជាខេត្ត បាទី ព្រៃក្របាស ទ្រាំង បន្ទាយមាស កំពត កំពង់សោម បាសាក់ ព្រះត្រពាំង ឱម៉ា ក្រមួនស ទឹកខ្មៅព្រៃនគរ បារៀន ដូនណា លង់ហោ ផ្សារដែក ព្រោះចៅហ្វាយខេត្ត និង បណ្តារាស្រ្ត ចូលចិត្តថា ស្តេចកន ជាមនុស្ស មានបុណ្យខ្លាំងណាស់ ក៏នាំគ្នា ចុះចូលនឹងម្ចាស់ផែនដីថ្មីនេះទៅ។

---

25 សព្វថ្ងៃសំរោងសែនជាឃុំមួយនៅក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ខេត្តសន្ទុកនេះ ក៏ហៅថា ខេត្តកំពង់ស្វាយដែរ។

ស្តេចកន បញ្ឈប់សឹកមួយរយៈ ដើម្បី រៀបចំរដ្ឋបាលមជ្ឈមនិង ខេត្ត ជាថ្មី នៅក្នុងដែនដីរបស់ខ្លួន អោយបានរឹងមាំ។ ចំណែក នៅក្នុងយុទ្ធសាស្ត្រទ័ព វិញ ស្តេចកន បានរៀបពល ជាបួនកងទ័ព: មួយកងទ័ព មានចំនួនរេហ៍ពល ៥ម៉ឺននាក់ តាំងនៅបន្ទាយភ្នំពេញ, មួយកងទ័ពទៀត មានចំនួនរេហ៍ពល ៣ម៉ឺននាក់ តាំងនៅផ្លូវទន្លេធំ, មួយកងទ័ពទី៣ មានរេហ៍ពល ៤ម៉ឺននាក់ ត្រឡប់ទៅនៅខែត្រស្រីសន្ធរវិញ ហើយ មួយកងទ័ពទី៤ មានរេហ៍ពលចំនួន ៤ម៉ឺននាក់ ដើរទៅវាយបន្ទាយលង្វែក។

មេកងទ័ព តាំងនៅផ្លូវទន្លេធំ បោះបន្ទាយទ័ពនៅស្រុកកំពង់សៀមមួយកង នៅស្ទឹងត្រែងមួយកង ចាំបញ្ជាស្តេចកន។ រីឯ កងទ័ព ដើរទៅវាយបន្ទាយលង្វែក លុះទៅដល់ទីដៅ ក៏ចោមវាយភ្លាម តែមិនទាន់ជាបានការយ៉ាងណាឡើយ។ ព្រះសុគន្ធបទ ទទួលបានដំណឹងពីចៅហ្វាយខេត្តកំពង់សៀម និង ស្ទឹងត្រែង ថាកងទ័ពព្រះស្តេចកន មកបោះបន្ទាយសឹកនៅទីនោះ ទ្រង់ក៏បញ្ជា ពញាក្រឡាហោមអោយនាំទ័ព ១ម៉ឺននាក់ ទៅជួយ, ទុករេហ៍ពលតែ ២ម៉ឺនប្រាំសែននាក់ សំរាប់ការពារ បន្ទាយលង្វែក។ ចំណែកមេទ័ពរបស់ព្រះស្តេចកន មើលឃើញថា បន្ទាយលង្វែក ជាបន្ទាយមាំមួនណាស់ ក៏ផ្ញើសំបុត្រ ប្តឹងដល់ស្តេចកន សុំជំនួយទ័ពបន្ថែម ទើបនឹងអាច វាយបែកបន្ទាយនោះបា

ន។ ស្តេចកន យល់ស្របតានសំណើរ ក៏បញ្ជូនរេហ៍ពល ១ ម៉ឺននាក់ទៀត ជាជំនួយ ហើយក៏នាំគ្នា វាយបន្ទាយនោះ ទាំងយប់ទាំងថ្ងៃគ្មានឈប់ ព្រោះ មានចំនួន រេហ៍ពល ច្រើន អាចផ្លាស់ប្តូរគ្នាបាន។ ព្រះសុគន្ធបទ មើលឃើញ ស្ថានការណ៏បែបនេះ ទ្រង់ព្រះចិន្តាថា វាមិនល្អដល់ទ័ពព្រះ អង្គ ដ្បិតរេហ៍ពល នឹងបាក់កម្លាំងកាយ និង ចិត្ត មិន អាចទ្រាំតទល់នឹងសត្រូវ ព្រោះគ្មានពេលសំរាកសោះ ទ្រង់ ក៏សំរេចចិត្ត ដកទ័ពថយពីបន្ទាយលង្វែក ទៅតាំងទីនៅ ខែត្រ អម្រាគគិរិន្ទបូណ៏ (គឺស្រុកបរិបូណ៏សព្វថ្ងៃនេះ)។ ការ ដោះដៃនេះ ត្រូវបានទ័ពស្តេចកន តាមកិន តែទព័ហ្លួន រត់ផង វាយតបផង នឹងការវាយប្រហារសត្រូវ ពីខាង ក្រោយទ័ព។

និយាយពី ពញាក្រឡាហោម មេទ័ពហ្លួង ដែលទទួលរាជ បញ្ជាទៅជួយការពារខែត្រកំពុងសៀម និង ស្ទឹងត្រែង ដឹងដំណឹងថា ទព័ហ្លួង ជួបគ្រោះ ក៏បរទ័ពត្រឡប់ក្រោយ មកជួយព្រះរាជា។ លុះមកដល់សមរភូមិ ពញាក្រឡាហោម ក៏បញ្ជាអោយរេហ៍ពល វាយខ្សែក្រោយ នៃទ័ពស្តេចកន យ៉ាងសាហាវ នាំអោយ កងពលនោះ ភ្ញាក់ផ្អើលជាខ្លាំង។ ដឹងថា ពញាក្រឡាហោម នាំទ័ពមកជួយ ហើយកំពុងវាយ ទ័ពសត្រូវពីខាងក្រោយ ពញាយមរាជ ជាមេទ័ពហ្លួង ក៏ ប្រមូលផ្តុំកម្លាំងទ័ព បកក្រោយ វាយប្រហារទ័ពស្តេចកនពី

មុខយ៉ាងខ្លាំង។ រេហ៍ពលទ័ពព្រះស្តេចកន ទទួលការវាយផ្ទប់ទាំងសងខាង ក៏ស្លុតស្លាប់ជាច្រើនពាន់ប្លាយ អន្តរាយបែកទ័ព នាំគ្នារត់ចូលមកភ្នំពេញវិញ។

ព្រះមហាក្សត្រខ្មែរ គិចផុតពីក្រញ៉ាំដៃទ័ពស្តេចកន ទ្រង់យាងមកដល់ស្រុកបរិបូណ៌ដូចបំណង។ លុះមកដល់នៅទីនោះ ព្រះអង្គ បញ្ញាយមរាជ និង បញ្ញាក្រឡាហោម ជួបប្រជុំគ្នា ដើម្បី រៀបពល និង យុទ្ធសាស្ត្រសឹក ជាថ្មី ដូចមានតទៅ : ស្តេចគ្រងរាជ្យ ត្រាស់អោយចៅពញាសួគ៌ាលោក (ងារ របស់ចៅហ្វាយខែត្រពោធិ៍សាត់) ឃុំពល ១ម៉ឺននាក់ ទៅឈររក្សាខែត្ររលាប្អៀ និង ឱពុកចិញ្ចឹម របស់ចៅពញាយមរាជ នាំទ័ព ៥ពាន់នាក់ ទៅតាំងធ្វើជាក្បាលស្ពានទ័ពនៅក្នុងដែនដីខាងកើត។ ចំណែកព្រះអង្គ និង ទ័ពហ្លួងលើក ទៅតាំងនៅក្នុងខែត្រអាសន្ទុក (គឺស្រុកសន្ទុកនៅក្នុងខែត្រកំពង់ធំសព្វថ្ងៃ)។

ទ័ពមុខហ្លួង ដើរមកដល់ស្រុកបារាយណ៏ ជួបប្រទះនឹងកងទ័ពចល័តដ៏ធំមួយ របស់ព្រះស្តេចកន ហើយច្បាំងគ្នា ជាកោលាហលយ៉ាងខ្លាំង។ នៅក្នុងសមរភូមិនោះ ទ័ពស្រួចរបស់ចៅពញាយមរាជ ជាមេទ័ពហ្លួង មានកម្លាំងខ្លាំងជាង ក៏វាយបែកទ័ពសត្រូវ ស្លាប់អស់រាប់ពាន់នាក់ប្លាយ។ បន្ទាប់មក ចៅពញាយមរាជ លោក បញ្ជាអោយវាយ

បន្ទាយកិល របស់សត្រូវបែកជាច្រើនកន្លែង នៅ ស្រុកបារាយណ៍ ជើងព្រៃ ស្ទឹងត្រង់ និង អាសន្ទុក ដើម្បីពង្រឹងនិងពង្រីក ដែនដី របស់កងទ័ពហ្លួង និង សុវត្ថិភាពព្រះរាជា។ ជៃជំនះសំខាន់នេះ លើកចិត្តព្រះមហាក្សត្រកម្ពុជា និង រេហ៏ពល ដែលកំពុងហត់នឿយជាខ្លាំង។

ចំណែកស្ដេចកន វិញ រស់នៅព្រះនគរ នៅស្រុកបាសានខិតខំរៀបចំកងទ័ព ហើយ ប្រមូលរេហ៏ពល ទាំងចាស់ទាំងថ្មីចំនួន ១០ម៉ឺននាក់ បំរុងទុកនឹងវាយលុកជាថ្មីម្ដងទៀតនៅពេលឱកាសហុចហើយ។ បន្ទាប់មក ស្ដេចកន អោយរៀបចំពីធីលើកខ្លួនឯងឡើងជាមហាឧបរាជ ភូ[26] សម្រេចរាជការមហាក្រស័ត្រសឹក រួចអោយធ្វើទង់ផែនដី ពណ៏ក្រហម ប៉ាក់រូបនាគក្បាល៨ ហើយពេល ចេញដំណើរទៅណាមកណា អោយគេបាំងក្លស់ដូចព្រះមហាក្សត្រ ហេតុនេះឯងបានជាប្រជារាស្ត្រ ហៅពាក្យកាត់ថា ស្ដេចកនខុសពីឈ្មោះព្រះរាជាថ្វាយជូន ឃុនហ្លួងព្រះស្ដេច។ រៀបចំដែនដីនគររួចស្រេចអស់ហើយ លោក ទុកអោយបិតា នៅរក្សាបន្ទាយក្នុងនគរ ឯខ្លួនឯង វិញ លើកទ័ពឆ្លងទន្លេទៅ

26 ភូ : ផែនដី; ឧបរាជភូ គឺ ឧបរាជផែនដី។

បោះនៅខែត្រកំពុងសៀម ប្រទល់នឹងទ័ពហ្លួង។ អស់សេនាមន្ត្រី នៅទីនោះ កាលបើឃើញទ័ពស្តេចកន ច្រើនលប់លើកម្លាំងទ័ពខ្លួនដូច្នេះ ក៏នាំគ្នា ដកថយមកខែត្រអាសន្ទុក ចូលប្តឹងចៅពញាយមរាជ អំពីស្ថានការណ៍សឹក។ លំដាប់នោះ ស្តេចកន ធ្វើសំបុត្រមួយច្បាប់ ឲអាល័ក្ស[27] យកទៅថ្វាយព្រះសុគន្ធបទ ក្នុងនោះ គាត់ស្នើសូមព្រះរាជាអោយដោះលែងម្តាយ និងញាតិបងប្អូន របស់ខ្លួន បើព្រះអង្គនៅព្រះរាជករុណាមែន ខ្លួននឹងរំលាយកងទ័ព ហើយចូលបំរើព្រះអង្គ ដូចពីដើមវិញ ព្រោះអ្វី ដែលខ្លួនធ្វើមកដល់សព្វថ្ងៃនេះ គឺធ្វើសំរាប់តែការពារជីវិតខ្លួនតែប៉ុណ្ណោះ គ្មានគំនិតក្បត់ និង ប្រទូសរ៉ាយ ដល់លំអងធូលីព្រះបាទបន្ទិចនោះឡើយ។ សព្វថ្ងៃនៅមានចិត្តជានិច្ច ចង់មកនៅជាខ្ញុំព្រះរាជាឡើងវិញ ប៉ុន្តែក្រែងទ្រង់ជាម្ចាស់ពុំប្រោសព្រះរាជាទាន។

ព្រះសុគន្ធបទ សណ្តាប់សេចក្តីសំបុត្រសព្វគ្រប់ហើយ ព្រះអង្គក៏អោយ ឧទ័យធិរាជ ចៅហ្វាយខែត្រអាសន្ទុក តបសំបុត្រទៅកនវិញថា : យុនហ្លួងព្រះស្តេច ធ្វើបែបនេះ វា

---

27 អាល័ក្ស : ឈ្មោះអ្នករាជការនៅក្នុងព្រះបរមរាជវាំង។

មិនត្រឹមទំនៀមទេ។ បើយុន មានចិត្តស្លូតត្រង់មែន គួរយុន រៀបចំខ្លួនរំលាយទ័ព ចូលតែខ្លួន ទៅក្រាបបង្គំទូលគាល់ព្រះបាទអម្ចាស់ជាមុន ទើបត្រូវតាម រាជាសណ្តាប់។ បើយុនប្រែចិត្តលែងក្បត់ យើង ឧទ័យធិរាជ ចៅហ្វាយខែត្រអាសន្នុក នឹងបង្គំទូល សុំទោសអោយយុន។ ប៉ុន្តែ បើយុនប្រឹងតែទទឹង មិនចូលខ្លួន យើងនឹងអោយសម្លាប់ម្តាយយុន និងគ្រប់គ្រួទាំងអស់ អោយស្លាប់ពុំគ្រាប្រណីឡើយ។ ស្តេចកន អានចប់សេចក្តីហើយ ក៏អោយបម្រើនាំសំបុត្រនោះ ទៅជូនបិតា អោយបានដឹងផង។ ព្រះពិជ័យនាគ កាលបើដឹងដំណឹងថា មានសំបុត្រពីចៅបញាឧទ័យធិរាជមកដូច្នេះ ក៏ស្ទុះរត់ទៅ ប្រុងនឹងទទួលសំបុត្រនោះ លុះរត់ទៅទន្ទឹមនឹងទ្វារ ក៏ភ្លាត់ជើងដួល ហើយទៅត្រូវនឹងចុងដាវ ដែលដាក់នឹងដៃកែវ ចំចន្លោះឆ្អឹងកាំបិត ហើយដួលចុះសន្លប់ បាត់ស្មារតីក្នុងទីនោះទៅ[28] រួចក៏អនិច្ចកម្មទៅដែរ។ ស្តេចកន ដឹងដំណឹងនេះ ក៏ផ្អាកសង្គ្រាម ថយទ័ព ទៅធ្វើបុណ្យឱពុកជាឧឡារិក។ ឆ្លៀតឱកាសនោះ ព្រះសុគន្ធ

---

28 ជំនឿមនុស្សក្នុងសម័យនោះថា ពិជ័យនាគនេះ ចាញ់សម្បថ ទើបបីបានជាអន្តរាយដល់ខ្លួនយ៉ាងនេះ។

បទ ទ្រង់ត្រាស់បង្គាប់អោយ ចៅពញាឧទ័យធិរាជ លើកទ័ពទៅវាយយកបន្ទាយលង្វែក និង ខែត្រកំពង់សៀម បើបានឈ្នះហើយ អោយលើកទៅ វាយខែត្រត្បូងឃ្មុំទៀត។ ជាមួយគ្នានោះដែរ ចៅពញាក្រឡាហោម លើកទ័ពទៅវាយបន្ទាយភ្នំពេញ។ ស្តេចកន ដឹងដំណឹងនេះ បែជាមានចិត្តសប្បាយទៅវិញ ហើយអោយរៀបចំពិធីជប់លៀងដ៏ធំមួយអញ្ជើញអស់មេទ័ព មេកង មេពួកជំតូច មកទទួលទានភោជនាហារ ហើយគ្រានោះ ស្តេចកនឡើងធ្វើសុន្ទរកថាប្រកបដោយសុវោហារ មានសេចក្តីជាសង្ខេបថា: ព្រះសុគន្ធបទ ជាព្រះមហាក្សត្រ គ្មានសីលធម៌ មិនគោរពទំនៀមព្រះនគរ គឺថា ពេលគេធ្វើបុណ្យសពបិតាគេនេះមួយ ទោះបីម្តេចម្តា ក៏សត្រូវគេតែងតែឈប់ធ្វើសង្គ្រាមកំណត់មួយថ្ងៃសិនដែរ តែឥឡូវស្តេចនេះ លើលទ័ពមកចោមបន្ទាយយើង គឺថា គេធ្វើល្មើសនឹងបទព្រះអយ្យការយ៉ាងនេះហើយ នោះយើងយល់ថា ស្តេចនេះនឹងអស់បុណ្យជាពិត ហើយដែនដីនឹងបានមកយើង ដូចទំនាយលោកគ្រូយើងទាយអោយយើងមិនខាន។ ធ្វើសុន្ទរកថា ចប់សេចក្តីហើយ ស្រាប់តែមាននាយទាហានមួយក្រុម នាំគ្នាដើបក្រោកឈរស្រែក ហើយចង្អុល ទៅលើមេឃថាឃើញនាគហោះព័ន្ធរោងបុណ្យបីជុំ។ ខណៈនោះ ពួកអ្នកចូលរួមពិធីជប់លៀង ក៏នាំក្រោកឈរទាំងអស់គ្នា រួចទះដៃតាំង

ហ៊ោថា : បន្ទូលព្រះមហាឧបរាជនោះ ពិតជាត្រូវដូចទំនាយហើយ។

នៅត្រង់ចំណុចនេះ ស្តេចកន ប្រើយុទ្ធសាស្ត្រ នៃសង្គ្រាមចិត្តសាស្ត្រ ឆ្លៀតយកកំហុសសីលធម៌ របស់ព្រះសុគន្ធបទ មកធ្វើជាអាវុធចិត្តសាស្ត្រ ដើម្បីធ្វើយុត្តិកម្ម នូវអំពើ របស់ខ្លួនអោយមានធម្មានុរូប និង ពង្រឹង នូវជំនឿ នៃរេហ៍ពល និង ប្រជារាស្ត្រថាខ្លួនជាអ្នកមានបុណ្យ មាននៅក្នុងទំនាយព្រះគ្រូ ដែលបានទាយទុកតាំងពីខ្លួននៅកុមារភាពមកម្លេះ។

លុះពីធីបូជាសពឱពុកចប់សព្វគ្រប់ កន ភូ (កន ផែនដី) តាំងឱពុកមា ជាប្អូនម៉ែ ឈ្មោះនាយកៅ ជាចៅហ្វាទឡ្ហ ហើយចាត់អោយលើកទ័ព ១៥ពាន់នាក់ ទៅជួយទ័ព នៅបន្ទាយភ្នំពេញ តាំងឧកម៉ឺនកែវ[29] ជាចៅពញាក្រឡាហោម នៃផែនដីខ្លួន ហើយចាត់អោយលើកទ័ព ១៥ពាន់នាក់ដែរ ទៅជួយកម្លាំងទ័ពនៅបន្ទាយលង្វែក ចំណែកខ្លួនឯងវិញ លើកទ័ព ចំនួន ៤ម៉ឺននាក់ ទៅជួយ មេទ័ពខ្លួននៅខែត្រ

---

29 ឧកម៉ឺនកែវ ជាបុត្រា របស់ចៅពញាសង្គ្រាម មេទ័ពស្តេចកងទ័ពហ្លួង ដែលស្តេចកន បាច់ផ្សព្រូវ-ក ធ្លាក់ពីដំរីសឹកស្លាប់។

កំពង់សៀម។ កងទ័ពទាំងបី ជួបប្រទះនឹងទ័ពហ្លួងនៅគ្រប់សមរភូមិ ចូលច្បាំងគ្នា ឥតសំចៃកម្លាំង តែលើកនេះទ័ពស្ដេចកន មានកម្លាំងជាង ក៏វាយបែកទ័ពហ្លួងទាំងបីកងទ័ព។ មេទ័ពហ្លួង ក៏នាំគ្នាថយទ័ពទៅខែត្រអាសន្ទុក។ ព្រះសុគន្ធបទ ដឹងច្បាស់ណាស់ថាបរាជ័យនេះ គឺដោយសារចំនួនទ័ពហ្លួង មានចំនួនតិចជាងឆ្ងាយណាស់ទ័ពសត្រូវទ្រង់ក៏ត្រាស់បញ្ជា អោយមន្ត្រីកងទ័ព ទៅកេណ្ឌរាស្ត្រនៅខែត្រ ស្ទឹងត្រែង សូរិន្ទ ខ្លងសិញ រិមជួស ជាំក្សាន្ត ចុងកាលបាក្រង់ ទង់តែ ទំនប់ មង្គលបុរី ឬស្សីសាញ ទឹកជោរ បាត់ដំបង ពោសាត់ ក្រគរ ខ្លុងក្រង បរិបូណ៌ រលៀប្អៀ បានចំនួនតែ ១សែននាក់តែប៉ុណ្ណោះ ព្រោះរាស្ត្រខ្លាចច្បាំងនាំគ្នារត់ចូលព្រៃអស់ជាង ១លាននាក់ ដើម្បីគេចវេះនឹងរាជកំណែន។ យើងអាចសួរជាសំនួរដែរថា តាមឿង ជាអ្នកស្រុកខែត្រពោសាត់ ចុះហេតុអ្វីក៏គាត់មិនស្ម័គ្រចិត្តចូលមកបំរើព្រះសុគន្ធបទ ប្រឆាំងនឹងស្ដេចកនដូចគាត់ជួយឧបត្ថមព្រះចន្ទរាជា ?

ស្ដេចកន ដឹងថាទ័ពខ្លួនកំពុងមានប្រៀបលើទ័ពហ្លួង ក៏ប្រញាប់លើកទ័ពអោយទាន់ការទៅវាយបន្ទាយជ័យ របស់ព្រះសុគន្ធបទ នៅខែត្រអាសន្ទុក។ តែមកដល់ខ្សែសីមាខែត្រ ស្ដេចកនគិតថា បើនឹងចូលវាយពិតជាឈ្នះ តែវាអាចអោយ ព្រះរាជាខ្វាល់ ហើយប្រាកដជា ហ្លួងអោយ

សម្លាប់មាតា និង ញាតិសន្តាន ស្លាប់ឥតប្រយោជន៍ ដូច្នេះ គួរគិតរកឧបាយកល យកម្តាយ និងញាតិសន្តានអោយ បានសិន ហើយអោយមានជ័យជំនះផង។ ស្តេចកន ថ្លែង ប្រាប់មេកងទ័ពខ្លួននៅពេលប្រជុំសឹកថា : នៅសម័យស ម្តេចពញាយ៉ាតនោះ ព្រះអង្គប្រើឧបាយ អោយទាហាន ពិសេស១២នាក់ ក្លែងជាបចុជ្ជន តែចេះវិជ្ជាគន់ល្បីល្បាញ ធ្វើជាទៅ សុំចុះចូលបំរើព្រះឥន្ទកុមាររាជា (បុត្រាស្តេច សៀមដែលព្រះបិតាទ្រង់ទុកអោយនៅ សោយរាជ្យសម្បត្តិ នៅមហានគរខ្មែរ ក្រោយពីខ្មែរចាញ់សង្គ្រាមសៀម)។ ដឹង ដំណឹងនេះ ព្រះបុត្រាព្រះចៅសៀម ព្រះអង្គអនុញ្ញាត អោ យពួកអ្នកសុំចុះចូលនោះ ចូលគាល់នៅក្នុងក្រឡាគំនាល់ តែគ្រានោះ នៅពេលដែលពួកនោះ កំពុងលូនចូល ទៅ ក្រាបថ្វាយបង្គំ ព្រះឥន្ទកុមាររាជា ស្រាប់តែ បុរសម្នាក់ លោតរំលង សេនាអង្គរក្សព្រះមហាក្សត្រ ដកកាំបិទពីក្នុង ផ្នួងសក់ ចាក់សម្លាប់ព្រះអង្គបានភ្លាមនៅលើព្រះសយនា សនៈ[30]។ តែបន្ទាប់មក អ្នកទាំង១២នាក់នោះ ត្រូវទាហាន

30 សយនាសនៈ : កន្លែងសំរាប់ អង្គុយ និង ដេក។

សៀម ចាក់កាប់សម្លាប់បានទាំងអស់នៅក្នុងក្រឡាគំនាល់។ ថ្លែងសេក្ដីចប់ ស្ដេចកន ប្រកាសរកអ្នកក្លាហានណាហ៊ានទទួលបេសកកម្មពិសេសបែបនេះ។ ខណៈនោះ ឧកម៉ឺនកែវ[31] ក៏សុំខ្លួនទទួលបំពេញបេសកកម្មនេះ ស្ដេចកនលុះបានស្ដាប់ ឧកម៉ឺនកែវរួចសព្វសេចក្ដី ក៏នាំនរៈនោះចូលទៅក្នុងបន្ទប់ រួចប្រាប់ពីឧបាយកលរបស់ខ្លួនគ្រប់ប្រការ គឺមានដូចតទៅ : ឧកម៉ឺនកែវ ត្រូវទទួលទោសដល់ប្រហារជីវិត ដោយសារខ្លួន ធ្វេសប្រហែសនឹងភារៈកិច្ច ជាមេទ័ព ដែលត្រូវវេនយាមល្បាតបន្ទាយនៅពេលរាត្រី ព្រោះខ្លួនរវល់តែដេកទាល់ថ្ងៃ។ ទទួលបានសេចក្ដីរាយការណ៍ពី

---

31 ជាបុត្រា របស់ចៅពញាសង្គ្រាម មេទ័ពស្រួចកងទ័ពហ្លួង ដែលស្ដេចកន បាច់ផ្គត្រូវ-ក ធ្លាក់ពីដំរីសឹកស្លាប់ តាំងពីផ្ដើមសង្គ្រាមភ្លាម។ នាយនោះ មានចិត្តឃោរឃៅ ខឹងនឹងព្រះសុគន្ធបទថាទ្រង់ប្រើបិតាខ្លួន ទៅចាប់ស្ដេចកន ហើយស្ដេចកនបាញ់ស្លាប់នៅក្នុងសមរភូមិ ព្រះអង្គមិនរវល់ចិញ្ចឹមបងប្អូនកំព្រាបិតា ក៏សំរេចចិត្តរត់ទៅបំរើឃាតករបិតា ដើម្បីរកឱកាសសងសឹកនឹងព្រះសុគន្ធបទ ដែលខ្លួន ទុកជា គ្មានសេចក្ដីអាណិតអាសូរសោះ ដល់គ្រួសារកំព្រា របស់ខ្លួន។ នាយនោះទុកការសម្លាប់បិតា របស់ខ្លួនជាកិច្ច នៃសង្គ្រាម តែទុក ចិត្តព្រងើយ របស់ព្រះសុគន្ធបទ ជាការប្រមាថដល់វិញ្ញាណក្ខន្ធ របស់បិតាខ្លួន ដែលលោកបានបូជាជីវិតក្នុងសមរភូមិ។

សកម្មភាពកងទ័ពប្រចាំថ្ងៃ ក្នុងនោះ មានសេចក្ដីកត់ហេតុអំពីការផ្ទេស របស់ឧកម៉ឺនកែវ ស្ដេចកន ធ្វើជាខឹង ហើយបង្គាប់អោយភូឃុំ (តម្រួតឃោជា) ទៅចាប់ខ្លួនចៅពញាកែវ អោយតម្រួតឃោជា វាយខ្នង ៣០ខ្វាប់ អោយបណ្ដើរ អារក្រាសគ្រប់បីថ្ងៃ ហើយអោយ សម្លាប់ចោលជាឱទាហរណ៍ដល់កងទ័ព។ មុននឹងសម្លាប់ អោយយកទៅចងនៅមុខបន្ទាយកងទ័ពហ្លួន បោះប្រទល់នឹងបន្ទាយស្ដេចកន ដែលមានចៅពញាឱទ័យរាជា ជាមេទ័ពហ្លួងរក្សាបន្ទាយ។ ខណៈដែលកំពុងតែរៀបចំសម្លាប់ ចៅពញាឱទ័យរាជា កំពុងគន់មើលពីបន្ទាយហ្លួង ស្រាប់តែឃើញមានទាហានមួយកងធំ រត់ចេញមករំដោះអ្នកទោសនោះ ហើយនាំគ្នា រត់សំដៅមករកបន្ទាយខ្លួន ហើយស្រែកសុំចុះចូលផង។ ចៅពញាឱទ័យរាជា អោយបើករបងខ្សែការពារបន្ទាយ អោយទាហានទាំងនោះ រត់ចូលមកចុះ តែយកទៅឃុំទុកមួយកន្លែងសិន ដើម្បីសួរចម្លើយអោយដឹងហេតុការណ៍គ្រប់ប្រការ។ និយាយអំពីក្នុងឧបាយកល របស់ស្ដេចកន គាត់អោយ ឧកម៉ឺនកែវ សម្រាំងយកទាហានពីររយនាក់ដោយខ្លួនឯង ហើយសន្យាថា នឹងចិញ្ចឹមគ្រួសារកូន

ចៅផៅសន្តានតទៅ៧ជួរគោត្រ[32] បើទាហានណាស្លាប់នៅក្នុងភារៈកិច្ចរបស់ខ្លួន។ បន្ទាប់មក ស្តេចកន ក៏យកមាស់ប្រាក់ស្លឹកបុរាណ ជាច្រើន ប្រគល់អោយទៅកែវ ឲយកទៅចែកទាហានជ្រើសរើសទាំងនោះ ជាប្រាក់រង្វាន់ សំរាប់លើកទឹកចិត្ត។ មុននឹងអនុវត្ត ឧបាយកល ឧកម៉ឺនកែវ និង ចះម៉ឺនចៃចុងរ៉ាក់សោម ជាប្រិយមិត្ត ដែលខ្លួនលើកតាំងជានាយរង ជួបប្រជុំជាសម្ងាត់ជាមួយទាហានពីររយនាក់ ដើម្បីពន្យល់យ៉ាងពិស្តាពីកិច្ចការដែលត្រូវធ្វើ និងត្រូវនិយាយសម្តីតែមួយ នៅពេលពួកភ្នាក់ងារចារកិច្ចហ្លួងនាំទៅសួរចម្លើយម្នាក់ម្តងៗ ថាខ្លួននាំគ្នាជួយឧកម៉ឺនកែវព្រោះយល់ឃើញថា មេទ័ពនេះ ទទួលទោសដល់ប្រហារជីវិតដោយអយុត្តិធម៌ជាទីបំផុត ដ្បិតការហត់នឿយ របស់ទាហានម្នាក់ៗ វាពិបាកនឹងទ្រាំណាស់សព្វថ្ងៃនេះ ជូនកាល

---

[32] ច្បាប់ពុទ្ធសាសនា ចែក៧ជួរគោត្រ ជាបីជាន់ គឺជាន់លើ ជាន់កណ្តាល ជាន់ក្រោម។ ជាន់លើមានបីថ្នាក់ គឺមាតាបិតា ជីដូនជីតា ជីដូនទួតជីតាទួត។ ជាន់កណ្តាល គឺខ្លួនឯង ហើយជាន់ក្រោមមានបីថ្នាក់ដែរ គឺ កូន ចៅ ចៅទួត។ តាមច្បាប់រដ្ឋប្បវេណីយបុរាណខ្មែរ ៧ជួរគោត្រ គឺ តា តាទួត តាលួត តាលា តាប៉ុក តាប៉ានិងចុងគល់ឬតាម៉ៅ ចុងគល់។

ក៏ដេកលក់នៅពេលយាមល្បាត ដូចលោកមេទ័ពកែវនោះឯង។

ចៅពញាឱទ័យរាជា មេទ័ពហ្លួង ទទួលសេចក្តីរាយការណ៍យ៉ាងពិស្តា ពីពួកភ្នាក់ងារសួរចម្លើយ ជឿជាក់ថាជារឿងពិត ក៏អាណិតអាសូរដល់ឧកម៉ឺនកែវ ព្រោះជាបុត្រ របស់សពមិត្តរួមអាវុធផង ក៏សរសេរសំបុត្រ ប្តឹងទៅព្រះសុគន្ធបទ អំពីហេតុ ដែលមានកើតឡើងនៅក្នុងបន្ទាយខ្លួន ហើយអោយនាំ អស់ទាហានហ្លួងទាំងនោះដាក់ក្តី តាមច្បាប់អាជ្ញាសឹក ទៅបន្ទាយស្ទឹងសែនផង ដើម្បីសុំសេចក្តីវិនិច្ឆ័យពីព្រះរាជា។ ព្រះសុគន្ធបទ ទ្រង់សណ្តាប់សេចក្តីសំបុត្រចប់សព្វគ្រប់ ទ្រង់ចាត់អោយ ក្រុមភ្នាក់ងារសួរចម្លើយសត្រូវ នាំទាហានទាំងនោះ យកទៅសួរចម្លើយជាថ្មីម្តងទៀត។ លុះឃើញថាចម្លើយ វាត្រូវដូចចម្លើយ ក្នុងសំបុត្រចៅបញាឧទ័យរាជហើយ ព្រះសុគន្ធបទ ទ្រង់អាសូរដល់ឧកម៉ឺនកែវណាស់ ថាឱពុកក៏ស្លាប់ ខ្លួនឯងត្រូវអាកនជាឃាតករ របស់សពបិតា ចាប់បង្ខំអោយបំរើវា រហូតចាប់កំហុសយកទៅសម្លាប់ចោល កុំតែបានទាហានទាំងនោះជួយរំដោះបាន កុំអីនឹងស្លាប់ ឥតប្រយោជន៏។ ទ្រង់ក៏បញ្ចូលអ្នកទាំងនោះ ទៅក្នុងកងទាហាន រក្សាព្រះអង្គ នៅបន្ទាយស្ទឹងសែន។

ស្តេចកន ក្រោយបន្តិចមក ក៏ចាប់ផ្តើមវាយលុកបន្ទាយ ចៅពញាឧទ័យរាជា យ៉ាងសាហាវ ទាំងយប់ទាំងថ្ងៃ។ ទ័ពហ្លួងមានចំនួនតិចជាងសត្រូវផង ហើយស្លាប់ច្រើនទៀតផងក្នុងសមរភូមិ នឹងទ្រាំច្បាំងតទៀតពុំបាន ក៏ដោះថយនៅវេលាយប់ទៅបន្ទាយស្ទឹងសែន។ លុះមកដល់ទីដៅ ចៅបញាឧទ័យចូលគាល់ព្រះសុគន្ធបទ ស្នើព្រះអង្គអោយដកទ័ពថយ ទៅខេត្តពោធិ៍សាត់ជាប្រញាប់ ព្រោះស្តេចកនមានទ័ពច្រើនក្រៃ លើសកម្លាំងជាង កងទ័ពហ្លួងឆ្ងាយណាស់ ហើយវានឹងមកវាយលុកបន្ទាយស្ទឹងសែន នៅពេលឆាប់នេះជាពុំខាន។ ព្រះសុគន្ធបទ យល់ព្រមតាមសំណើរ តែនៅក្នុងរយៈពេលដែលកំពុងរៀបចំថយទ័ពនោះ ឧកម៉ឺនកែវ និង ចៈម៉ឺនចៃចុងរ៉ាក់សោម ក៏នាំទាហាន របស់ខ្លួនវាយលុក ចូលដំណាក់ព្រះរាជា នៅវេលាយប់ ចាក់កាប់ជាមួយក្រុមទាហានរក្សាព្រះអង្គផ្ទាល់ ខណៈនោះ ឧកម៉ឺនកែវ វាយចូលបានទៅក្នុងក្រឡាគំនាល់ ឃើញព្រះសុគន្ធបទភ្លាម គាត់ក៏លោតទៅចាក់សម្លាប់ព្រះអង្គស្លាប់ បានសំរាច់ ដូចគ្រោងការណ៏ទុក ក្នុងឧបាយកល។ តែទ័ពហ្លួងចាប់បាន ទាហានឧកម៉ឺនកែវ ៣០នាក់ យកមកកាត់ក្បាលភ្លាម ហើយ សម្លាប់បានច្រើននាក់ទៀតនៅពេលប្រយុទ្ធគ្នា តែក៏មានសត្រូវខ្លះ រត់គេចខ្លួនបានចេញពីបន្ទាយ។ ចំណែកទ័ពហ្លួងស្លាប់ជាងមួយរយនាក់។ ចៅពញា

ឧទ័យរាជា លើកសពព្រះសុគន្ធបទ បញ្ចុះនៅទីសមគួរ ហើយ ក៏ប្រញាប់នាំកងទ័ពខ្លួន ថយចេញពីបន្ទាយស្ទឹងសែន តាមផ្លូវទឹក ចោលចៅបញ្ញាយមរាជ ជាមេទ័ពហ្លួង ព្រោះខ្លួន បានរៀបចំទូកចំណុះ និង ទូកឆ្លងរួចស្រេចអស់ហើយ សំរាប់រំដោះ ព្រះសុគន្ធបទចេញពីបន្ទាយ។ ក្នុងព្រះរាជពង្សាវតាខ្មែរ ចារថា ព្រះសុគន្ធបទ សុគតក្នុងជន្មាយុ ៣៨វស្សា ព្រះអង្គសោយរាជ្យបាន ៩ឆ្នាំ។

ដឹងដំណឹងភ្លាមថា ចៅពញាឧទ័យរាជ បានដោះថយកងទ័ពពីបន្ទាយ ស្តេចកន ក៏បញ្ជាអោយវាយបន្ទាយស្ទឹងសែន ជាប្រញាប់ ព្រោះទ័ពហ្លួង គ្មានស្តេចត្រួតត្រាផងគ្មានមេទ័ពមានការពិសោធ សំរាប់ការពារផង។ ឃើញកងទ័ពស្តេចកនមកដល់ ចៅពញាយមរាជ ចេញទទួលច្បាំងនិងសត្រូវ តែពុំអាចតតាំងយូរបាន ក៏នាំចៅពញាយសជាព្រះបុត្រមកុដ និងជាក្មួយ របស់ស្តេចកន ចុះទូករត់ចេញពីសមរភូមិ[33]។ រហែពលទព័ហ្លួង កំព្រាមេទ័ពដូច្នោះ

33 សម្តេចឥសីភ័ទ្ទសួស ជារាជព្រះគ្រូ ប្រមូលព្រះលំពែងជ័យ ព្រះខ័នរាជ្យ និង គ្រឿងបញ្ចក្សេត្រ ចុះទូក អោយសិស្សឈ្មោះ សួរ ថែវ តាមក្បួនទូកចៅបញ្ញាយមរាជ ដល់ពាក់កណ្តាលផ្លូវ លោកគិតថា

ខ្លះក៏នាំគ្នាដាក់អាវុធ ខ្លះទៀត ក៏នាំគ្នារត់ខ្ចាត់ខ្ចាយទៅ។ លុះមកដល់ខេត្តមហានគរ ចៅពញាយមរាជ ក៏សុំយកដំរីសេះ ពីចៅហ្វាយស្រុក ដើម្បីធ្វើដំណើរទៅក្រុងទេព។ លុះធ្វើដំណើរ បានពាក់កណ្តាលផ្លូវ លោកក៏ឈឺ អនិច្ចកម្មនៅក្នុងព្រៃទៅ។ អស់មន្ត្រីក្រមការមហាតលិក រៀបដាក់ស្នែងបញ្ចុះសពនៅទីកន្លែងសមគួរហើយ ក៏នាំអញ្ជើញចៅពញាយសរាជា ចូលទៅក្នុងទេព ដើម្បីសុំជ្រកកោនក្រោមព្រះបារមី ព្រះចៅចក្រពត្តិ ជាព្រះមហាក្សត្រ នៃស្រុកសៀម។ ស្តេចកនទទួលបានជ័យជំនះជាស្ថាពរហើយ ក៏រៀបចំរដ្ឋបាលនគរជាថ្មី ទុកក្រុងស្រីសន្ធ ជាព្រះនគរដដែល។ លុះរៀបចំសេនាបតីរួចស្រេចហើយ អស់មន្ត្រីសេនាបតីធំតូចជំនុំព្រមគ្នា រៀបចំពិធី ប្រាប្តាភិសេក[34] ស្តេចកនឲ្យឡើងសោយរាជសម្បត្តិ គ្រប់គ្រងក្រុងកម្ពុជាធិបតី បង្កើតសន្តតិវង្ស និង រាជវង្សានុវង្សថ្មី។ ក្នុងព្រះរាជពង្សាវតារខ្មែរ

---

បើអញទៅស្រុកសៀម ច្បាស់ជាស្តេចសៀម ទារយក របស់រាជ្យទាំងនេះជាពុំខាន គិតដូច្នេះហើយក៏បញ្ជាសួរអោយថែរទុកគេចចេញពីក្បួនទូក ហើយក៏ឡើងគោក នាំរបស់ទសងនោះទៅលាក់ទុកនៅក្នុងរន្ធ នៃប្រហោងដើមចំបកធំមួយនៅខេត្តបាទី ស្រុកកណ្តាលស្ទឹងសព្វថ្ងៃនេះ។

34 ប្រាប្តាភិសេក : អភិសេកស្តេចដែលបានជ័យជំនះក្នុងសង្គ្រាម។

ចារទុកថា ស្ដេចកនឡើងសោយរាជសម្បត្តិនៅឆ្នាំ ១៥១២ ក្នុងព្រះជន្មាយុ ២៩ឆ្នាំ ក្នុងព្រះរាជវាំងបាសាន ខែត្រស្រីសឈរ ទ្រង់ព្រះនាម ព្រះបាទ ព្រះស្រីជេដ្ឋាធិរាជ រាមាធិបតី ក្រុងស្រីសឈរបាសាន។

សាកល្បងសិក្សា

## កត្តាអ្វីខ្លះ ដែលនាំឲស្តេចកន ឈ្នះសង្គ្រាមព្រះសុគន្ធបទ

នៅទីនេះយើងសាកល្បងសិក្សាអំពីកត្តាមួយចំនួន ដែលនាំអោយស្តេចកន ធ្វើសង្គ្រាមឈ្នះព្រះសុគន្ធបទ។ កត្តាទាំងឡាយនោះដែរ វាអាចជាចម្លើយនឹងសំនួរខាងលើថា តើហេតុអ្វី បានជាតាមឿង មិនចេញមកជួយព្រះសុគន្ធបទជាព្រះរៀមព្រះចន្ទរាជា។

### កត្តាមនុស្ស

ព្រះបាទសុគន្ធបទ និង ស្តេចកន មានជាតិកំណើតខុសគ្នា ម្នាក់ជាវង្សស្តេច ម្នាក់ទៀតជាវង្ស។ អ្នកទាំងពីរ អាចទុកបានថាជាមនុស្សចំណាស់ប្រហែលគ្នា ដ្បិតមាន គម្លាតអាយុខុសគ្នាតែ៤ឆ្នាំតែប៉ុណ្ណោះ។ ព្រះសុគន្ធបទ កើតនៅឆ្នាំ ១៤៧៩ រីឯស្តេចកន វិញ កើតនៅឆ្នាំ ១៤៨៣[35]។ ជាមនុស្ស បើតាមដាន ជីវិត របស់ព្រះសុគន្ធបទ ដែលបានតាមពិនិត្យ ខាងលើមក គេឃើញថា ព្រះអង្គ ជាមនុស្សម្នាក់ មានអក្សកិរិយាពិបាក ដែលនាំអស់មន្ត្រីសេនាបតីនិង រាជវង្សានុវង្ស មិនសូវមានការទុកចិត្ត លើព្រះអង្គ

35 បើយកអាយុស្តេចកន ទៅប្រៀបធៀបនឹង អាយុព្រះចន្ទរាជាកើតនៅឆ្នាំ ១៤៩៦ ស្តេចកនមានអាយុច្រើនជាង១៣ឆ្នាំ។

ព្រោះទ្រង់មានការបារម្ភគ្រប់បញ្ហានៅក្នុងចិត្ត ហើយឲតែសង្ស័យទៅលើរឿងអ្វីមួយ ទ្រង់រំអុកនៅក្នុអារម្មណ៍គ្មានសំរាក។ ការខ្វល់នោះ ជួននាំឲទ្រង់យល់ទរសុបិន រួចជឿហោរាទាយថាជាការពិត។ វាពិតណាស់ហើយថា នៅក្នុងបរិបទនៃសម័យនោះ ហោរាសាស្ត្រ ជាផ្នែកសំខាន់មួយ សំរាប់បំភ្លឺផ្លូវអនាគត នៃជីវិតរស់នៅរាល់ថ្ងៃ ដូច្នេះព្រះសុគន្ធបទ ទ្រង់មិនខុសពីស្តេចកននោះដែរ តែស្តេចកនជាមនុស្ស មានអក្សកិរិយាវិជ្ជមាន តែងតែប្រើប្រាជ្ញា សំរាប់ដោះស្រាយបញ្ហា ហើយទុកទំនាយព្រះគ្រូ ជាសេចក្តីសង្ឃឹមនៅក្នុងចិត្ត ដែលជាការលើកទឹកចិត្តដល់គាត់នៅពេលណាគាត់ សំរេចធ្វើអ្វីមួយ ក្រោយពីបានវិភាគរកចំណុចខ្សោយ និង ខ្លាំង នៅក្នុងយុទ្ធសាស្ត្រ ដែលត្រូវធ្វើហើយប្រយ័ត មិនទុកទំនាយ អោយលើសលុប លើបញ្ញាដូចយ៉ាងប្រើប្រាជ្ញាមុនសិន ទើបលើកទំនាយយកមកធ្វើជាបង្អែក សំរាប់រកការគាំទ្រ។ រីឯ ព្រះសុគន្ធបទ វិញ ទ្រង់មានអកប្បកិរិយាអវិជ្ជមាន ទ្រង់ទុកទំនាយជាសច្ចះភាពដាច់ខាត នាំអោយទ្រង់ប្រតិកម្មគ្មានការពិចារណា ដោយឈរលើ គោលការណ៍ថា « លទ្ធផលបង្ហាញពីមធ្យោបាយត្រឹមត្រូវ » តែទ្រង់ពុំបានគិតថា មធ្យោបាយ បើយកមកប្រើសំរាប់តែលទ្ធផល វាក៏អាចបង្កើតបញ្ហាមួយចំនួន នៅ

ក្នុងអភិក្រម នៃការអនុវត្តិផែនការ ដែលនាំឲលទ្ធផល មិនជាលទ្ធផលជាចុងក្រោយ នោះឡើយ។

ជា ប្រមុខរដ្ឋ ព្រះសុគន្ធបទ មិនសូវមានការផ្ដួចផ្ដើម គំនិតច្រើនទេ មិនតែប៉ុណ្ណោះទ្រង់ជាមនុស្សស្មាក់ស្មើរជាទី បំផុត ដែលនាំឲ ស្ដេចកន ទាញយកប្រយោជន៏បានងាយ ស្រួលអំពីទុព្វលភាពនេះ ព្រោះគាត់ជា មនុស្សវាងវៃ និង រហ័សរហួន ក្នុងឋានៈជាមគ្គុទេសក៏។ ស្ដេចកនត្រួតត្រា មនុស្សជាជម្នូតា ដោយអនុវត្ត វិធីឲរង្វាន់ ចំពោះអ្នកណា ដែលជួយគាត់ តាមគុណស្រ័យតិចច្រើន ដែលបានធ្វើរៀ ងៗខ្លួន។ ចំណែកព្រះសុគន្ធបទ ទុកជំនួយការ របស់សហ ការី ជាកតព្វកិច្ច នៃអ្នកបំរើ។ ក្នុងគោលការណ៏ របស់ព្រះ មហាក្សត្រ ព្រះអង្គជា អ្នកថែរក្សារាស្ត្រ រីឯរាស្ត្រវិញ ជាអ្នក បំរើក្សត្រ ជាកតវេទី[36] ចំពោះព្រះអង្គជាអ្នកមានគុណ។

## កត្តាភូមិសាស្ត្រ និង សេដ្ឋកិច្ច

ចាប់ពីផ្ដើម មានជម្លោះអាវុធ ជាមួយព្រះសុគន្ធបទ ស្ដេចកន កាន់កាប់បានទឹកដីមួយចំនួន ដែលមានប្រជានុ

---

36 កតវេទី : អ្នកដែលគិតតែនឹងតបស្នងសងគុណដល់អ្នកមាន គុណ។

រាស្ត្រ រស់នៅច្រើនកុះករ ដែលអាចអោយគាត់ ងាយស្រួល នឹងកែនរាស្ត្រធ្វើទាហាន។ ដំបន់ដែលមានមនុស្សរស់នៅច្រើនដូច្នោះ គឺជាដំបន់ មានភាពសម្បូណ៌ នៃ សេដ្ឋកិច្ច ដែលជាកត្តាមួយសំខាន់សំរាប់ទទួលរាប់រង សោហ៊ុយ នៃសង្គ្រាម។ លក្ខខណ្ឌទាំងឡាយនោះឯង ដែលនាំឲស្តេចកន មានប្រៀបភ្លាមជាងព្រះសុគន្ធបទ។ កាប៉ុនប៉ង របស់កងទ័ពហ្លួង ដើម្បីកាន់កាប់ ខេត្តអាសន្ទុក ដែលជាជង្រុកស្រូវមួយនៅស្រុកខ្មែរ មិនបានគង់វង់យូរ ដូចបំណងឡើយ ព្រោះ ស្តេចកន លើកទៅវាយទ័ពហ្លួង យ៉ាងប្រញាប់ ដើម្បីហូត សេចក្តីសង្ឃឹមនេះចេញ។

## កត្តាសំណាង

កត្តាសំណាងនេះ ជាចំណែកមួយសំខាន់ ក្នុងការរស់នៅរបស់មនុស្ស។ ស្ដេចកន ជាមនុស្សមានភ័ព្វ ព្រោះ ត្រូវបានព្រះសង្ឃសត្វា ជួយសង្គ្រោះតាំង ពីទារក រហូតដល់ធំពេញក្ដី និង តាមជួយរហូតដល់មានជ័យជំនះ, មាន បងស្រីប្រថុយជីវិតដើម្បីសង្គ្រោះប្អូន និង ជួបនឹងបរិស្ថាន ជាអំណោយផលដល់ខ្លួន គឺមាន ហ្វូងសត្វទាព្រៃច្រើនក្រៃនៅក្នុងបឹង ដែលអាចអោយរំដោះខ្លួនបានពីបំណងខ្មៅរបស់ព្រះសុគន្ធបទ។ ការជួបភ័ព្វសំណាងទាំងឡាយនោះ ដែលស្ដេចកន យកមកទុកក្នុងចិត្តថាជាវាសនាវិជ្ជមានរបស់ខ្លួន ដែលមាននៅក្នុងទំនាយព្រះគ្រូ។ តែស្ដេចកន គាត់មានអកប្បកិរិយា ជាមនុស្សស្ញូវច្ឆន្ទ[37] ដែលជាកត្តាអភ័ព្វទៅថ្ងៃមុខ។

---

[37] មនុស្សស្វច្ឆន្ទ : មនុស្សមានសេចក្ដីពេញចិត្តចំពោះខ្លួន នាំអោយខ្លួនធ្វើតាមទំនើងចិត្តខ្លួន ; Narcissisme។



នាគព្រួសភ្លើង

# ភាគទី២ - ផែនដីស្ដេចកន



រាជក្រឡាគំនាល់ នៃមហាក្សត្រមួយអង្គ

## របបថ្មី សំរាប់ផែនដីថ្មី

ស្ដេចកន ធ្វើសង្គ្រាមនឹងសពព្រះបាទសុគ្គបទ អស់រយៈពេល៤ឆ្នាំ។ នរៈនេះ ឡើងសោយរាជសម្បត្តិនៅឆ្នាំ ១៥១២ ក្នុងព្រះជន្មាយុ ២៩ឆ្នាំ ក្នុងព្រះរាជវាំងបាសាន ខែត្រស្រីសឈរ (ស្រីសន្ធរ) ទ្រង់ព្រះនាម ព្រះបាទ ព្រះស្រីជេដ្ឋាធិរាជរាមាធិបតី ក្រុងស្រីសន្ធរបាសាន។ នៅឆ្នាំនោះ ព្រះចន្ទរាជា មានព្រះជន្ម ១៦ឆ្នាំ ទ្រង់គង់នៅស្រុកសៀម ជាមួយបរិវារខ្មែរ ជាអ្នកជំនិតទ្រង់ចំនួន ៥០នាក់ ដែលនាំទ្រង់រត់ទៅស្រុកសៀម និង កូនប្រុសតាមឿងបួននាក់ ដែលដង្ហែរទ្រង់ តាមបញ្ញាឱពុក ទៅរស់នៅក្រុងទេព។

---

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

នៅឆ្នាំ ១៥១៤ ស្ដេចកន ត្រាស់បង្គាប់ ឱយអស់សព្វមន្ត្រីសេនាបតី ឲកែនប្រជានុរាស្ត្រ លើករាជធានីពីក្រុងបាសាន ទៅទិសខាងកើត។ មូលហេតុ គឺស្ដេចកន ចង់លុបចោលឱ្យ អស់ស្នាមរបបចាស់ ដើម្បីបើកយុគថ្មី ទាំង អត្ថរូប និង អត្ថរស់ សំរាប់រាជ្យរបស់គាត់ ។ លុះទៅដល់ភូមិចន្លក់ដូនតី គាត់ឲបោះពន្លាជ័យ ឈប់នៅទីនោះអស់រយៈពេល៥ខែ។ នៅកន្លែងនោះ ស្ដេចកន យល់សប្តិឃើញតាចាស់ម្នាក់ ឈរប្រាប់គាត់ឱ្យទៅតាំងរាជធានីថ្មី នៅភូមិស្រឡប់ ក្នុងចុងខេត្តត្បូងឃ្មុំ ទល់ដែនខេត្តបាភ្នំ ទើបមានសេចក្ដីសុខ បើបន្តនៅទីនេះ នឹងអាចជួបប្រទះគ្រោះថ្នាក់។ ស្ដេចកន ក៏ចាកចេញពីភូមិចន្លក់តាមបណ្ដាំនៅក្នុសុបិន ទៅសាង រាជបូរីទូលំទូលាយ នៅភូមិស្រឡប់ នៅទីនោះ គាត់បង្គាប់ឱ្យសាង ប្រាសាទស្អាតល្អ ភាគបន្ទាយព័ន្ធដោយប្រាការ[38] មានប៉មមាំមួន មានស្រះធំនៅកណ្ដាលកំផែង។ ការកសាងនោះ បានឆាប់រហ័ស ព្រោះរាស្ត្រស្រុះស្រួលណាស់។ ស្ដេចកន ឱ្យឈ្មោះរាជធានីថ្មីនោះថា ក្រុងសន្លប់ដូនតីព្រៃនគរ។ នៅក្នុងបុរីនោះ ក៏មានសេណី

---

[38] ប្រាការ : កំផែងបន្ទាយ។

ជំនាញច្រើនក្រៃ មានសាមគ្គី ជាហេតុញ៉ាំងរដ្ឋថ្មីឱ្យថ្លៃចំរើនសុខស្ងប់។ បីឆ្នាំក្រោយមក ក្រុងថ្មីនេះ បានទាក់ទាញរាស្ត្រប្រជា និង អ្នកបរទេស ចូលមករស់នៅកុះកុំជុំជិតប្រកិនគ្នាច្រើនក្រៃ រួចក្លាយទៅជា មណ្ឌលផ្សារសេដ្ឋកិច្ច ដ៏ធំមួយនៅក្នុងនគរ ដូច្នេះ ដើម្បីសំរួលដល់ការទូទាត់នៃការលក់ទិញដូរ ស្តេចកន ឱ្យបោះប្រាក់ស្លឹក មាសស្លឹកត្រារូបនាគឱ្យរាស្ត្រចាយ។

គ្រាឡប់មក និយាយអំពីព្រះខាន់រាជ្យ ដែលស្តេចឥសីភ័ទ្ទ និង ខ្ញុំបំរើ យកទៅលាក់ទុកនៅក្នុងរន្ធ នៃប្រហោងដើមចំបកធំមួយនៅខេត្តបាទី (ស្រុកកណ្តាលស្ទឹងសព្វថ្ងៃនេះ)។ នៅពេលស្តេចកន ឡើងគ្រងរាជសម្បត្តិ ដើម្បីឱ្យស្របនឹងទំនៀមក្សត្រ គាត់ឱ្យគេធ្វើព្រះខាន់រាជ្យថ្មី សំរាប់ជំនួសព្រះខាន់ដែលបាត់នោះដើម្បីបង្គ្រប់ពិធី តែគាត់ក៏បានប្រកាសឱ្យរកព្រះខាន់រាជ្យ និង គ្រឿងបញ្ចក្សត្រ ថាបើនរណារកឃើញ ហើយយកមកប្រគល់ដល់គាត់ គាត់និងប្រទានរង្វាន់ ជាមាស ៥០០តម្លឹង។ ឥសីភ័ទ្ទ លុះបានដំណឹងនេះ គិតថា សព្វថ្ងៃខ្លួននៅម្នាក់ឯងក្រីក្រលំបាក[39]

[39] អ្នកបំរើ ជាខ្ញុំស្លាប់។

ណាស់ ក៏សំរេចចិត្តយក រតនមង្គលទាំងនេះ ដែលខ្លួនបានលាក់ទុកនោះ ទៅប្រគល់ឱ្យស្តេចកន ព្រោះមិនដឹងកាលណាឡើយ ពញាចន្ទរាជា និង បញាយសរាជា ទាំងពីរអង្គ នឹងបានត្រឡប់មកស្រុកខ្មែរវិញ។ បានដល់គ្រាមួយសម្តេចឥសីភ័ទ្ទ ក៏ធ្វើដំណើរទៅយករតនមង្គល រៀបនឹងលូកដៃចូលប្រហោងដើមចំបក ក៏ស្រាប់តែឃើញពស់មួយយាំងធំ លូនឡើងទៅលើដើមចំបកនោះដែរ, ឃើញពោះ សម្តេច ក៏ភ័យញ័ររន្ធត់ ភ្លាត់ដៃ ធ្លាក់ចុះមកបាកកស្លាប់ក្នុងព្រៃនោះឥតមានអ្នកណាឃើញសោះឡើយ។



ដំរីមួយក្បាល

# និវត្តន៍ នៃព្រះចន្ទរាជាមកកាន់ស្រុកខ្មែរវិញ

## សកម្មភាព នៃព្រះចន្ទរាជា នៅស្រុកសៀម

នេះនឹងនិយាយអំពីព្រះចន្ទរាជា រស់នៅស្រុកសៀម។ ស្តេចយាងទៅគង់នៅក្រុងទេពបានបីឆ្នាំ ទើបព្រះពញាយសរាជា បុត្រាមកុដ ជាក្មួយ រត់ទៅដល់ស្រុកសៀម ហើយព្រះចៅក្រុងទេព អនុញ្ញាតឱ្យទៅគង់នៅជាមួយទ្រង់។ ដឹងដំណឹងសព្វគ្រប់ពីព្រះនគរ និង មរណភាព របស់ព្រះជេដ្ឋាព្រះចន្ទរាជា ទ្រង់វិយោគ សោលអន្ទោះអាល័យបង និងស្រុកជាខ្លាំង។ ព្រះអង្គ ចាប់មានព្រះហឫទ័យ ចង់តែត្រឡប់ទៅស្រុកវិញ។ ព្រះអង្គ ទន្ទឹងចាំតែ ព្រះចៅចក្រពត្តិជួយឧបត្ថម្ភទ្រង់ ដោយថ្វាយទ័ព ឱ្យនាំទៅក្រុងកម្ពុជាដើម្បីច្បាំងតតាំងនឹងស្តេចកន ជារាជ្យភង្គ[40]។ តែការរង់ចាំនេះគ្មានដំណឹងទាល់តែសោះ។ ព្រះអង្គអន្ទះសាក្នុងចិត្តរកតែកល នឹងដោះមកស្រុកកម្ពុជាវិញជានិច្ច តែរកពុំទាន់បាននោះឡើយ។ ព្រះអង្គ បានរស់នៅស្រុកសៀម ៧ឆ្នាំហើយ មានព្រះជន្ម ១៩ឆ្នាំហើយដែរ ជាបុរសដែលកំពុងពេញជំទង់ មានកម្លាំងកាយ និង ប្រជ្ញាឆ្លាតវៃ ហើយទ្រង់

40 រាជ្យភង្គ : អ្នកដណ្តើមរាជ្យ។

សព្វព្រះរាជហឫទ័យទាក់ដំរីព្រៃណាស់ រហូតមានឈ្មោះល្បី នៅក្រុងទេព ថាជាអ្នកជំនាញម្នាក់។

គ្រាមួយនៅស្រុកកាញ្ចនបុរី មានហ្លួសៀមម្នាក់ឈ្មោះពាម នាំស្ទូគ្រព្ទក ទៅចាប់ដំរីសជំមួយ តែមិនបានសំរេចសោះ។ ដំណឹង នេះឮដល់ព្រះចៅចក្រពត្តិ ព្រះអង្គចង់បានដំរី នោះណាស់ តែមិនដឹងរកអ្នកណា ល្មមជាទីសង្ឃឹម ឱ្យចេញ ទៅធ្វើការនេះថ្វាយបាន។ មន្ត្រីសៀម ដែលគាល់ទូលថា : មានតែព្រះចន្ទរាជា និង ស្ទូគ្រព្ទក អាចធ្វើការនេះបាន សម្រេចជាពុំខាន។ ព្រះចៅចក្រពត្តិ ទ្រង់សណ្តាប់ហើយ ទ្រង់ព្រះអំណរណាស់ ទ្រង់ក៏ត្រាស់សុំឱ្យព្រះចន្ទរាជា ស្តេច ជួយយកអាសាកិច្ចការនេះផង។ ព្រះចន្ទរាជា ក្រាបទូល ទទួលទៅទាក់ដំរីនោះ យកមកថ្វាយតាមព្រះរាជតម្រិះ។ អិនយូរប៉ុន្មាន ព្រះចន្ទរាជា ទាក់ដំរីនោះបានថ្វាយព្រះចោះ ចក្រពត្តិ ព្រះអង្គទ្រង់ព្រះអំណរណាស់ ទ្រង់សរសើរឫទ្ធី ហើយប្រទានរង្វាន់ជាច្រើន។ ព្រះចៅចក្រពត្តិ ព្រះប្រទាន នាមដំរីសនោះថា ព្រះគជេន្ទ្រនរោត្តម។

ក្រោយបន្តិចមក ព្រះចន្ទរាជា ចូលគាល់ព្រះចៅចក្រពត្តិ សុំបង្គំលា ទៅបង្ក្រាបស្តេចកន ជាជនថ្លើមធំហ៊ានដណ្តើម រាជបល័ង្កព្រះជេដ្ឋា ថាបើព្រះអង្គនឹងបង្អង់យូរ ឃើញថាពុំ បានឡើយ។ ព្រះចៅចក្រពត្តិ ទ្រង់ត្រាស់ថា : កុំឱ្យក្លួយរួស

រាក់ពេក ចាំដល់ឆ្នាំក្រោយ មានឹងឱ្យគេជូនក្លួយទៅមិនខាន។ បានឮព្រះសែងដូច្នោះកាលណា ក៏កាត់យល់ភ្លាមថា ព្រះសែងជាសំដីទូត ការពិតគឺព្រះអង្គមិនព្រមអនុញ្ញាតឱ្យទ្រង់វិលត្រឡប់ទៅស្រុកវិញបានឆាប់ឡើយ។ លុះទ្រង់ត្រឡប់ពីគាល់ ក៏កោះប្រជុំ ស្ន័គ្រពួក ១៥នាក់ ពិគ្រោះគ្នា រកល្បិចកលបែបណា ដើម្បីអាចវិលត្រឡប់ទៅកម្ពុជាវិញ ឱ្យបានឆាប់រហ័ស ព្រោះពេលវេលា កំពុងហុចប្រយោជន៍ឱ្យស្តេចកន។ ទាំងអស់គ្នា រកឃើញក្រឡេច ជាបញ្ញាមួយដែលអាចនឹងធ្វើបានផង ហើយ វាថែមទាំងមិនឱ្យព្រះចៅចក្រពត្តិមានការសង្ស័យទៀតផង។ ឧបាយកលនោះគឺ ប្រឌិតព្រឹត្តិការណ៍មួយ ឱ្យអ្នកស្រុកផ្អើលថាមានដំរីស កំពស់ប្រហែលជាងដប់ហត្ថក្នុងព្រៃ។ ដើម្បីឱ្យគេជឿបានត្រូវធ្វើយ៉ាងណា ឱ្យមានភស្តុតាងជាសម្ភារៈ ដូច្នេះ ព្រះចន្ទរាជា និង ស្ន័គ្រពួក នាំគ្នាយកឈើឆ្លាក់ជើងដំរី ហើយយកទៅ លបសង្កត់ដី ឱ្យមានស្នាម ដូចជើងដំរីមែនទែន រួចយកលាមកដំរី ញាត់ក្នុងជាល ធ្វើឱ្យបានជាដុំធំៗ លុះធ្វើបានហើយ ឱ្យរលាក់ចេញពីជាល ហើយចាត់គ្នាឱ្យទៅទំលាក់រាយចោល ជាច្រើនកន្លែង ហើយយកភកទៅលាបតាមដើមឈើណា ល្មមជាដំរីឈរស្រប់បាន និងយករោមចៀមពីរបីសរសៃ ទៅសៀតនឹងសំបកឈើ ធ្វើជារោមដំរីត្រដុសនឹងដើមឈើ។ រៀបចំសព្វគ្រប់អស់ហើយ ក៏ចាត់

គ្មេគ្នា ដើរបង្ហួសកន្លងដានទៅទិសព្លិសាន ដល់ទៅខេត្ត នាងរង ស្រុកនគររាជ ហើយនៅតាមផ្លូវ នាំគ្នាប្រាប់ពួកអ្នកស្រុកថា ពួកខ្លួនបានឃើញដំរីធំ សម្បុយដូចសំឡីបានជាដើរតាមរកមើលឱ្យច្បាស់ទីកន្លែងរបស់វា។ ដំណឹងនេះឮដល់អស់ថៅមឿង (មេឃុំ) ថៅបាន (មេភូមិ) ក្នុងដែនដីសៀមទិសខាងកើត ក៏បញ្ជាឱ្យអ្នករាជការចូលព្រៃទៅពិនិត្យមើល តើរឿងនេះជារឿងពិតឬទេ។ ពួកអ្នកទាំងនោះឃើញដានដំរី លាមក ធំក្រៃលែង មើលទៅលើដើមឈើខ្លះក៏ឃើញមានរោមសសុទ្ធ សដូចជាសំឡី ច្រើនអន្លើមែន។ ថៅមឿង ថៅបាន ទាំងនោះ នាំគ្នាអរណាស់ ក៏ប្រញាប់ប្រញាល់ ធ្វើសំបុត្រ មកប្ដឹងចូលទៅសេនាបតី យកសេចក្ដីក្រាបទូល ព្រះថៅចក្រពត្តិ។ ទ្រង់ជ្រាបហើយ មានព្រះអំណរណាស់។ ថ្ងៃមួយ ស្ដេចចេញគង់ព្រះរាជរោងរម្យ ជួបជំព្រះរាជបុត្រាធម៌ គឺថៅពញាអុង ដែលត្រូវជាព្រះរាជបុត្រានៃព្រះស្រីរាជាខ្មែរ[41] និង ព្រះវង្សា សេនាបតី មន្ត្រីទាំងពួង

41 ព្រះស្រីរាជា ដែលកើតសង្គ្រាមនឹងព្រះស្រីសុរិយោទ័យ ហើយស្ដេចសៀមមកអញ្ជើញស្ដេចទៅស្រុកសៀមទសងពីព្រះអង្គទៅ។ ប៉ុន្តែទ្រង់ មិនបានយាងដល់ស្រុកសៀម ស្ដេចសុគត នៅបាត់ដំបង ហើយនៅសល់តែពញាអុងជាព្រះរាជបុត្រានេះ។

ក្រាបបង្គំគាល់ត្រៀបត្រា ទើបស្តេចត្រាស់សួរថា : ឈ្មោះណានឹងទទួលអាសាទៅតាមទាក់ដំរីប្លែកនោះបាន ? ជាលើកទីពីរហើយ អស់មន្ត្រីសៀម នាំគ្នាក្រាបទូលថា : ទូលបង្គំយើងខ្ញុំទាំងឡាយឃើញតែចៅពញាចន្ទរាជាមួយប៉ុណ្ណោះដែលជាអ្នកក្លាហាន មានតម្រិះខាងទាក់ដំរីនោះជាងគេ។ ម្យ៉ាងវិញទៀត ទ្រង់ក៏បានធ្វើការទាក់ដំរី ថ្វាយរៀងមកហើយផង។ ព្រះចៅចក្រពត្តិ សណ្តាប់យោបល់នេះហើយ មានហដ្ឋចិត្ត[42] ទ្រង់ក៏សួរយោលបល់ ព្រះចន្ទរាជាថាក្មួយឯងយល់ដូចម្តេចដែរ។ ឮដូច្នេះ ស្តេចខ្មែរ ទ្រង់គិតថាដូចគំនិតទ្រង់ហើយ ទើបទ្រង់ ក្រាបទូលតបថា : តាមសំបុត្រច្រើនច្បាប់ ដែលចៅហ្វាយស្រុកច្រើនស្រុក ប្តឹងចូលមកនោះថា ដំរីនោះធំខ្ពស់ ដល់ទៅ ១០ហត្ថ ហើយបើតាមដំណឹងក្រៅសំបុត្រទៀតថា ដំរីនោះមានបរិវារគោតស្ត (ដំរីឈ្មោលឥតភ្លុក មានតែថែ) នៅរក្សាជាច្រើន ហើយ លើសដំរីទាំងពួង ទាំងសម្បុរ និង កំពស់ ក៏ល្អគួរចេតនា។ នៅក្នុងលក្ខខណ្ឌបែបនេះ ទូលព្រះបង្គំ សូមសម្តេច ស្តេចព្រះរាជទានពល ៥ពាន់នាក់ ដំរីផ្ទាក់ ១ពាន់ក្បាល កាំភ្លើង ធ្នូ

42 ហដ្ឋចិត្ត : ចិត្តរីករាយ។

ស្នា សស្ត្រាវុធ សម្រាប់បាញ់ បង្អើលដំរីកាចៗច្រើនណាស់ ដែល នៅរក្សាដំរីសនោះ ឱ្យវាខ្លាច ហើយចៀសចេញទៅ ទើបស្រួលទាក់ឱ្យបានឆាប់រហ័ស ដូចសេក្តីប្រាថ្នា របស់ព្រះករុណា។

ព្រះចៅចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ព្រះអំណរណាស់ ទើបទ្រង់ព្រះរាជទានព្រះសែង (គឺដាវស្រោមមាស, អ្នកកាន់ដាវនេះ មានអំណាចកាប់សម្លាប់បានតាមចិត្ត) ហើយ ត្រាស់បង្គាប់ចៅពញាចក្រី ឱ្យកេណ្ឌពលពាហនៈ ថ្វាយតាមសុំកុំបីខាន។ កាលបានពល និង ស្បៀងអាហារព្រមទាំងព្រះរាជអាជ្ញា ព្រះសែងអាជ្ញាសឹកគ្រប់អស់ហើយ ក៏ថ្វាយបង្គំលា ចេញមកក្រៅ។ ក្នុងគ្រានោះ ទ្រង់ទៅថ្វាយបង្គំពញាអុង ក្រាបទូលថា អ្នកបងលែងគិតស្រុកយើងហើយឬ ក៏បានគង់នៅព្រៃងើយ មិនអើពើនឹងរឿងអាក្បត់ឈ្មោះកន យករាជសម្បត្តិបានដូច្នេះ ? ទ្រង់មិនស្តាយព្រះវង្សមហាក្សត្រ និងគ្រងព្រះមហានគរទេឬ ?ពញាសុវណ្ណខាក់លោក[43] (ពញាអុង) ទ្រង់ឆ្លើយតបថា : អូនអើយ បងមកនៅស្រុកទេពនេះ ជាឈ្លើយព្រះពុទ្ធចៅទេ។

---

43 ងាវដែលស្តេចសៀមថ្វាយជូនព្រះអង្គ។

ព្រះពុទ្ធថៅស្ដេចពុំយកទោសបង ស្ដេចប្រោសបង ឱ្យបងគ្រងស្រុកសុវណ្ណខាត់លោក ជាខេត្តធំស្មើនឹងខេត្តព្រះរាជបុត្រទៅហើយ។ បងបានប៉ុណ្ណោះហើយ បងក៏បានសុខណាស់ហើយ។ បើបងបានសុខដូច្នេះហើយ បងនឹងគិតរកសុខឯណាទៀត។ ចំណែកឯស្រុកខ្មែរវិញ បងលែងនឹករលឹកអាឡោះអាល័យហើយ តាមតែអ្នកអូន គិតគូរចុះ។ ព្រះចន្ទរាជា ស្ដេចដឹងព្រះរាជហឫទ័យបងជីដូនមួយហើយ ទ្រង់មិនហ៊ាន ត្រាស់សួរតទៅទៀត ក្រែងរឿងលួចរត់ទៅស្រុកខ្មែរ វាពុំបានស្ងាត់ នឹងនាំឱ្យខូចការណ៍។ បន្ទាប់មក ទ្រង់ក៏ថ្វាយបង្គំលា វិលមកដំណាក់វិញ។

មកដល់ឆ្នាំ ១៥១៦, ព្រះចន្ទរាជា មានព្រះជន្មាយុ ២០ឆ្នាំ[44] ជាស្ដេចវយ័ស្ថ[45] មានមេធា[46]ខ្ពង់ខ្ពស់ ចេះសុវិជ្ជា[47] សំរាប់ជីវិត និង នគរ មានភាវរូបអង់អាច សមជាបញ្ញាជនផង និង មេទ័ពនិរភ័យផង ទ្រង់ និង បណ្ដាជាខ្ញុំ លើកទ័ពសៀម តាមស្នាមជើងដំរី ទាំងយប់ទាំងថ្ងៃ ពុំបានឈប់

44 នៅក្នុងព្រះពង្សាវត្តាខ្មែរថាព្រះអង្គមានព្រះជនវស្សា៣៦ឆ្នាំ។
45 វយ័ស្ថ : ដែលកំពុងពេញជំទង់
46 មេធា : គំនិតប្រាជ្ញា។
47 សុវិជ្ជា : ចំណេះមានប្រយោជន៍។

ឈរសោះ។ លុះធ្វើដំណើរបាន៧ថ្ងៃ បានមកជិតដែនស្រុកខ្មែរហើយ ក៏ធ្វើសំបុត្រ ភ្ជាប់និងរោមចៀម និង គូរទាំងស្នាមជើងដំរី ឱ្យបម្រើសៀម នាំវិលថ្វាយព្រះចៅចក្រពត្តិ។ ស្ដេចសៀម ទទួលសំបុត្រនោះ នៅក្នុងក្រឡាគំនាស់ ក៏សួរទៅអ្នកនាំសារថា: ឥឡូវ ក្បួនរាក់ដំរីទៅដល់ណាហើយ ? បម្រើ ក្រាបទូលថា: សូមទ្រង់ព្រះមេត្តាប្រោស ក្រោមល្អងធូលីព្រះបាទ ក្បួនដំរីនោះ បានទៅដល់ជិតដែនស្រុកខ្មែរហើយ។ កាលទ្រង់ព្រះសណ្ដាប់ចម្លើយ ដែលបម្រើក្រាបទូលឆ្លងហើយ ព្រះអង្គគ្នាន់ក្នុងព្រះទ័យណាស់ ទើបត្រាស់សួរព្រះអង្គសុវណ្ណខាក់លោក (ពញាអុង) ថា ចៅពញាចន្ទទៅតាក់ដំរីលើកនេះ ហេតុអ្វីក៏ស្រូតរូត ទៅឯដែនស្រុកខ្មែរ។ បើដំរីនៅក្នុងដែនប្រទេសយើងឯណោះទេ ? ការណ៍នេះនាំឱ្យអញមានកង្ខា[48]ណាស់។ ចៅពញាអុង ក្រាបទូលថា: ចៅពញាចន្ទរាជា មានចិត្តមានះណាស់ មានស្មារតីរឹងប៉ឹងហើយចិត្តរឹងរូសកាន់វង្សត្រកូលណាស់ទៀត មុននៅចេញដំណើរ ទ្រង់មកប្រាប់ខ្ញុំថា អាស្ដេចកន សម្លាប់ព្រះជេដ្ឋាយកព្រះនគរ ទូលព្រះបង្គំមិនអាចទ្រាំបាននឹងកិរិយាអា

48 កង្ខា : សេចក្ដីសង្ស័យ។

កនបានទៀតទេ ហើយថែមទាំងសួរទូលព្រះបង្គំថា អ្នកបង លែងនឹកស្រុកទេសហើយឬ យ៉ាងនេះផង។ ដូច្នេះទូលព្រះបង្គំ យល់ឃើញថា ព្រះចន្ទរាជា លើកទ័ពទៅវាយអាកន ពុំខានឡើយ គឺមិនមែនទៅទាក់ដំរី ដូចត្រាស់បង្គាប់ទេ។ ព្រះចៅចក្រពត្តិ បានទ្រង់ជ្រាបដូច្នោះហើយ ទ្រង់ព្រះពិរោធខ្លាំងណាស់ទ្រង់ត្រាស់ ប្រើម៉ឺនពេជ្យដាវិចិត្រ ឱ្យនាំទាហានសេះ ៣០នាក់ លើកទៅតាមព្រះចន្ទរាជា ហើយទ្រង់ផ្តាំបណ្តិប[49]ថា បើចៅពញាចន្ទរាជា ពុំព្រមត្រឡប់ទេ ឱ្យឯងប្រាប់ពលទាំង ៥ពាន់នាក់នោះ ឱ្យត្រឡប់មកវិញ ឱ្យខានតែបានមក។

ត្រឡប់មកនិយាយ អំពីព្រះចន្ទរាជាវិញ លុះមកដល់ព្រំដែនខ្មែរសៀមហើយ ទ្រង់ក៏បញ្ចុះបញ្ចូលអាណាប្រជារាស្ត្រខ្មែរ បាន ១.៨០០ នាក់ បន្ទាប់មក ស្តេចក៏លើកទ័ព ចូលស្រុកខ្មែរ មកដល់ខែត្រទឹកជោរ ជួបនឹងខ្ញុំបម្រើម្នាក់ ដែលធ្លាប់បំរើព្រះអង្គ នាំមនុស្ស ២០០នាក់ មកជួយយកអាសាព្រះអង្គ។ ហើយ ទ្រង់ក៏លើកទ័ពខ្មែរសៀម ចូលវាយ

---

49 បណ្តិប : សំដីហាមបញ្ជាក់ ដោយដាក់កំហិត ឱ្យអ្នកស្តាប់ទទួលប្រតិបត្តិដោយដាច់ខាត។

បន្ទាយខែត្រនគរសៀមរាប។ វាយបែកដូចប្រាថ្នា ទ្រង់កែនបាននរហ៏ពល ៧ពាន់នាក់ថែមទៀតផង ហើយក៏លើកទ័ពចូលទៅក្នុងបន្ទាយមហានគរ។

ដឹងដំណឹងថា ព្រះចន្ទរាជា យាងចូលស្រុកខ្មែរ ហើយកំពុងគង់នៅក្នុងមហានគរ ម៉ឺនពេជ្យដាវិចិត្រ នាយសេនាសៀម ក៏ប្រញាប់ប្រញាល់ ទៅសូមចូលគាល់ស្តេចខ្មែរ ដើម្បីថ្វាយរាជបណ្ណិប របស់មហាក្សត្រខ្លួន។ ទទួលបានការអនុញ្ញាតឱ្យចូលគាល់ នាយសៀមនោះ ទូលថា : ព្រះពុទ្ធចៅ (ព្រះចៅចក្រពត្តិ) ត្រាស់ប្រើព្រះបង្គំ ឱ្យមកតាមទ្រង់ឱទ្រង់លើកពលត្រឡប់ទៅវិញឱ្យឆាប់។ ថារឿងទាក់ដំរីនេះសូមទ្រង់បង្អង់សិនចុះ។ ព្រះចន្ទរាជា សណ្តាប់ហើយ ទ្រង់ក៏ហូតព្រះសែងអាជ្ញាសឹក ដែលព្រះចៅចក្រពត្តិប្រទានមក ហើយត្រាស់ថា : ព្រះសែងនេះ ដែលព្រះពុទ្ធចៅ ប្រគល់ឱ្យអញ សំរាប់បំពេញនាទីពីរយ៉ាង : មួយឱ្យតាមទាក់ដំរីម្យ៉ាងទៀតឱ្យអញ ទៅចាប់អាកនថ្វាយព្រះអង្គ។ បន្ទាប់មក ទ្រង់ចង្អុលទៅម៉ឺនដាវិចិត្រ ត្រាស់ថា ខ្លួនឯងនេះឬមានអំណាចលើសដាវអាជ្ញាសឹកនេះ ? សំដីដែលឯងថា ព្រះចៅ ឱ្យឯងមកយកអញនោះ តើព្រះរាជឱង្ការ ចារជាចុតហ្មាយនៅឯណា យកមកឱ្យអញមើល ? បើឯងគ្មានទេ អញទុកឯងជាក្លែងព្រះរាជឱង្ការ ទុកឯងជាបង្ខូចបង្ខានរាជាការផែនដី ហើយអញត្រូវកាត់ក្បាលឯង ព្រមទាំង

គូកនឯកផង ដោតជាបម្រាម។ ទ្រង់សន្ទប់ម្តងទៀតថា តើព្រះចុតហ្វាយឯងនោះនៅឯណា យកមកឱ្យអញមើល ? ម៉ឺនពេជ្រដាវិចិត្រ រាជនាយសេនាសៀម គ្មានព្រះចុតហ្វាយ ជាទីអាង លុះឃើញព្រះសែងអាជ្ញាសឹកថែមទៀត ខ្លួនឯង និង ទាហានសេះ ៣០នាក់ ដែលអមមក ក៏ភិតភ័យតក់ស្លុត លុតជង្គង់ សូមព្រះរាជទានទោសគ្រប់គ្នា។ ទាហានសៀម ៥ពាន់នាក់ ដែលហែរព្រះចន្ទរាជាមកទាក់ដំរី រួចហួសចូលមកស្រុកខ្មែរ ឃើញដូច្នោះ ក៏នាំគ្នាលុតជង្គង់គោរពព្រះសែងអាជ្ញាសឹកដែរ។

ត្រូវដឹងថា ព្រះចៅចក្រពត្តិមិនបានធ្វើចុតហ្វាយទេ គ្រាន់តែបង្គាប់អ្នកបំរើ ឱ្យនិយាយតាមសំដីព្រះអង្គ។ ប្រហែលជាព្រះអង្គពិរោធពេក នាំឱ្យទ្រង់ភ្លេចភាពល្អិតល្អន់នេះ ? ឬមួយ ព្រះអង្គដឹងច្បាស់អំពីផែនការសម្ងាត់ របស់ព្រះចន្ទរាជា តែធ្វើជាល្ងង់ ឬ ព្រះអង្គ ជាអ្នករួមគំនិត ដើម្បី ធ្វើឱ្យអាណាប្រជារាស្ត្រខ្មែរ ជឿជាក់ក្នុងចិត្តថាព្រះចន្ទរាជា វិលត្រឡប់ទៅស្រុកខ្មែរ ធ្វើសង្គ្រាមនឹងស្តេចកន ជាទំនាស់រវាង ខ្មែរនិងខ្មែរសុទ្ធសាត គ្មានការគាំទ្រពីសៀមនោះឡើយ ដែលជាល្បិចមួយ សំរួលដល់ព្រះចន្ទរាជា ឱ្យទ្រង់ធ្វើការឃោសនាប្រឆាំងនឹងស្តេចកន ថាព្រះអង្គ មិនមែនជាអាយ៉ងសៀមនោះទេ។ ល្បិចព្រះចៅចក្រពត្តិទាំងពីរនេះ វាសំដៅទៅលើគោលដៅតែមួយគឺ ជួយព្រះចន្ទរាជា ដោយ

មិនចំពោះ។ តែបើ ព្រះចៅចក្រពត្តិ ទ្រង់លូង់មែន ដែលវាអាចជាការពិត នោះពិតជាព្រះចន្ទរាជា និង ស្ដេចព្ពក ពិតជាអ្នកមានឧបាយសឹកខ្ពង់ខ្ពស់មែន។

ព្រះចន្ទរាជា ឃើញថាម៉ឺនដាវិចិត្រ មានចិត្តកញ្ជ្រមហើយ ទ្រង់ត្រាស់ថា អស់ឯងរាល់គ្នាទាំង ៣០នាក់ វិលទៅវិញចុះ ទៅក្រាបទូលព្រះចៅថា ប្រោសលៀង (ចិញ្ចឹម) រក្សាអញ ជាង៧ឆ្នាំនេះ ជាព្រះគុណលើអញខ្លាំងណាស់ រកអ្វីមកប្រៀបផ្ទឹមពុំបានទេ។ មិនតែប៉ុណ្ណោះសោត ទ្រង់ឱ្យរេហ៍ពល ៥ពាន់នាក់ ដំរីផ្ទាក់១រយ ជូនអញមកស្រុកអញវិញ ក៏ជាព្រះគុណធ្ងន់លើសលែងទៅទៀត។ ប៉ុន្តែឥឡូវនេះ អញនៅក្រណាស់ អញនឹងរកអ្វីថ្វាយទៅវិញបានឱ្យបានសមគួរនឹងព្រះគុណនោះគ្មានទេ។ ដូច្នេះសុំព្រះចៅ ទ្រង់កុំពិរោធឡើយ។ ថាដល់អញឈ្នះអាកនហើយ ចាប់បានទាំងខ្លួនវា ហើយយកផែនដីបានវិញកាលណា អញនឹងនាំពលសៀម ដែលទ្រង់ព្រះទានមកនេះ និង សួយសារ មកក្រាបបង្គំទូលថ្វាយ តាមសំដី ដែលអញបានក្រាបទូល ទុកជាសម្មាត់ស្រាប់នេះ។

## អត្ថធិប្បាយទី១ ជាមតិផ្ទាល់ខ្លួន

« *លើចំណុចថា ទ័ពសៀម៥ពាន់នាក់ មកទាក់ដំរី គ្មានប្រតិកម្មអវិជ្ជមាន ព្រោះឃើញព្រះសែងអាជ្ញាសឹក វាជា*

*រឿងមួយគួរលើកមកអត្ថាធិប្បាយដែរ។ ចំនួនទ័ព ៥ពាន់នាក់ ជាចំនួនច្រើន ត្រូវមានមេទ័ពពិទ័គ្ឋ[50] និង នាយទ័ពសៀមយ៉ាងតិច១រយនាក់ ទើបត្រួតត្រាបាន។ កងទ័ពនេះទៀត ជាកងប្រយុទ្ធ ប្រដាប់អាវុធសំរាប់ធ្វើសង្គ្រាម មិនមែន គ្រាន់តែមកទាក់ដំរីនោះឡើយ។ ការជាក់ស្តែង គឺកងទ័ពនេះ វាយឈ្នះកងទ័ពខ្មែរ នៅខេត្តសៀមរាប ងាយស្រួលណាស់ ការណ៍នេះក៏រឹតតែបញ្ជាក់ថា ជាកងទ័ពនេះ ជាកងទ័ពសំរាប់ធ្វើសង្គ្រាម។ តែជ័យជំនះក៏អាចថា បានមកការប្រយុទ្ធផ្អេកក្តាមដែរ ព្រោះខ្មែរយើង នៅសម័យបុរាណ គ្មានយុទ្ធសាស្រ្តការពារព្រំដែនពិតប្រាកដទេ : នៅតាមព្រំដែនខ្មែរសៀម មិនដែលមានបន្ទាយគយឃ្លាំ[51] មាំទាំ សំរាប់ការពារ ដែលនាំឱ្យសៀម ចូលវាយស្រុកខ្មែរងាយស្រួលបំផុត ហើយការវាយចូលម្តងៗ សុទ្ធតែជាវាយផ្អេកក្តាម មកលើខ្មែរ។ ផ្លូវដែលសៀមដើរចូល មានតែមួយ គឺតាមខេត្តសៀមរាបនេះឯង ដូច្នេះ យុទ្ធសាស្រ្តរបស់ពញាយ៉ាតបោះបង់រាជធានីមហានគរ មិនទុកជា*

50 ពិទ័គ្ឋ : ឈ្លាស ប្រសប់ យល់កិច្ចកលជាក់ សំរាប់វាយសត្រូវ។
51 គយឃ្លាំ : រំពៃចាំមើល, ល្បាត។

*យុទ្ធសាស្ត្រស័ក្តិសិទ្ធ សំរាប់ការពារជាតិនោះឡើយ គឺថា មិនគិតពង្រឹងរបងនៅទល់ដែនឱ្យបានមាំមួន សាងបន្ទាយរេហ៍ពលរៀងរាយ ជាអចិន្ត្រៃយ៍ សំរាប់ការពាររាជធានី បែរជាបោះបង់ចោលទុកផ្លូវឱ្យទ័ពសៀមដើរចូលស្រុកខ្មែរនៅវិញ ហើយយកទឹកដីខ្មែរធ្វើជាសមរភូមិ នៅពេលណាដែលសៀមគេវាយខ្មែរ។*

*គួរគិតថា មេទ័ព និង នាយទ័ពសៀម តាមហែព្រះចន្ទរាជា ពិតជាស្គាល់ឋានៈម៉ឺនដាវិចិត្រច្បាស់ណាស់ថា ជានាយទាហានពិសេស បំរើផ្ទាល់ព្រះចៅខ្លួន ចុះហេតុអ្វី ក៏មានការសង្ស័យទៅវិញថា នាយនេះ ប្រឌិតរឿងរាជបញ្ជា ហើយក៏មិនកង្វល់អ្វីសោះ នៅពេលដែលព្រះចន្ទរាជា នាំខ្លួនដើរចូលស្រុកខ្មែរ ហើយថែមទាំងបញ្ជាឱ្យវាយបន្ទាយខ្មែរថែមទៀត។ សំនួរទាំងនេះ ជាទីម្លប់ ដែលគេអាចបកស្រាយបានថា មេទ័ពសៀម និង នាយទ័ពសំខាន់ៗ ទទួលបញ្ជាច្បាស់លាស់ ឱ្យអាសាស្តេចខ្មែរ តាមតែព្រះហឫទ័យទ្រង់ចង់បាន ដែលមាន ព្រះសែងអាជ្ញាសឹកជាទីអាងតែមួយគត់។ ដូច្នោះ វានឹងអាចមាន ការគាំទ្រពីព្រះចៅចក្រពត្តិចំពោះព្រះចន្ទរាជា លើកទ័ពសៀម ទៅវាយស្តេចកន។ ការគាំទ្រនេះ វាមានទាំង អត្ថរូប និង អត្ថរស់ នៅក្នុង ស្មារតី នៃសាមគ្គីភាព រវាងរាជានិយមផង និង រាជានិយមសៀម គេទុកគេ ជាអ្នកអាណាព្យាបាល លើរាជា*

*និយមខ្មែរផង។ បន្ទាប់ពីរាជ្យព្រះធម្មរាជាមក ដែលមានម្តាយជាសៀម, ស្តេច និង ឧត្តមមន្ត្រីខ្មែរណា មានទំនាស់នឹងរាជអាជ្ញាធរខ្មែរ រត់ទៅស្រុកសៀម ដើម្បីសុំ ការជ្រកអាស្រ័យ ពីព្រះចៅសៀម អ្នកនុះ តែងតែទទួលការសង្គ្រោះពីព្រះអង្គជានិច្ច។ ការណ៏នេះ វាទៅជាទម្លាប់ របស់រាជវង្សានុវង្សខ្មែរ ទុកស្រុកសៀម ជាកន្លែង សំរាប់រត់គៀសខ្លួន ឬរត់ទៅសូមការឧបត្ថម្ភ ដើម្បី វិលត្រឡប់មកដណ្តើមរាជបល័ង្ក »។*

ក្រោយពីទាហានសេះសៀម ត្រឡប់ទៅវិញ ព្រះចន្ទរាជាទ្រង់ ក៏លើកទ័ពទៅស្រុកបាត់ដំបង នៅទីនោះ ទ្រង់ក៏ចាត់ឱ្យនាយទ័ព ដើរបញ្ញុះបញ្ញូលរាស្ត្រក្នុងខេត្ត។ ខណៈនោះ បញ្ញមនោមេត្រី ចៅហ្វាយស្រុកបាតើដំបង ក៏ចូលទៅថ្វាយបង្គំព្រះចន្ទរាជា ថ្វាយរេហ៏ពល ១ម៉ឺននាក់ និងស្បៀងអាហារ ព្រមទាំងរទេះចំនួន១ពាន់ សំរាប់ជាសេចក្តីត្រូវការក្នុងការធ្វើសឹកសង្គ្រាម។ បីថ្ងៃបន្ទាប់មក ស្តេចខ្មែរក៏លើកទ័ពទៅតាំងនៅខេត្តពោធិ៍សាត់។ រីឯតាមឿងវិញ ដឹកដំណឹងថា ព្រះចន្ទរាជា ត្រឡប់មកដល់ស្រុកខ្មែរវិញហើយ ហើយកំពុងគង់នៅស្រុកបាត់ដំបង គាត់ក៏រៀបចំផែនការ ជាមួយស្ម័គ្រពួកគាត់ច្រើននាក់ ប្រហារពញាស្ទួគ៌ាលោក ចៅហ្វាយខេត្តពោធិ៍សាត់ ដែលមានគំនិតពុំ

ព្រមចុះចូលនឹងព្រះចន្ទរាជា ព្រមទាំង កេណ្ឌពលបាន ៤ ម៉ឺននាក់ សំរាប់តតាំងនឹងស្តេចខ្មែរនោះ។

នៅពេលរាត្រីមួយ តាមឿង និង ក្រុមគាត់ ដោយមានជំនួយពីក្នុងបន្ទាយ ជាពួកក្បត់នឹង ពញាសួគ៌ាលោក លួចបើកទ្វារបន្ទាយ ឱ្យពួកគាត់ ចូលវាយលុកបន្ទាយ ហើយក៏សម្លាប់ពញាសួគ៌ាលោកបានដូចប្រាថ្នា។ បន្ទាប់មក តាមឿង ស្រែកប្រកាសប្រាប់អស់ក្រមការខេត្ត និង បណ្តារាស្ត្រថា : ព្រះចន្ទរាជា ដែលព្រះអង្គ លើកទ័ពត្រឡប់ពីស្រុកសៀមមកនោះ ជាស្តេចពេញព្រះរាជត្រកូល នៃសម្តេចព្រះធម្មរាជាដែលស្តេចទ្រង់ធម៌ហើយ។ ឯស្តេចកន ជាចៅហ្វាយ របស់ពញាសួគ៌ាលោកនេះ ខាងម្តាយជាពលព្រះស្រីរតនត្រ័យសុទ្ធ។ ដូច្នេះ តើអស់អ្នករាល់គ្នានឹងសំពះព្រះ ឬ ក៏ចង់ថ្វាយបង្គំបាយ៉ាប (អារក្សទឹកសំរាប់ពួកនេសាទមច្ឆជាតិគោរព) ថាបើ អស់អ្នកធ្លាប់ពេញចិត្តស្តេចកន ជាកូនពលនោះ គួរតែឥឡូវទៅថ្វាយបង្គំស្តេចពេញត្រកូលវិញ ព្រោះព្រះអង្គ យាងមកដល់ខេត្តបាត់ដំបងហើយ។ តែបើអស់អ្នកនៅរក្សាចិត្តស្រឡាញ់រាប់អានស្តេចកន ជាវណ្ណៈថោកទាបបំផុត ជាពូជអំបូរអ្នកមានទោស ដែលមិនអាចលប់លាងបានឡើយ ដូច្នេះ ចូរអស់អ្នករៀបចំស្បៀងអាហារ នាំបុត្រភរិយា ចាកចេញពីទីនេះ ទៅបន្ទាយ

សន្លប់ដូនតីព្រៃនគ របស់ស្តេចកនចុះ យើងឥតប្រកាន់ទោសពៃរ៍អ្វីដល់អស់អ្នកទេ។

ស្តាប់ចប់សព្វគ្រប់អស់ហើយ ទាំង រាស្ត្រ ទាហាន ក្រុមការ និង មន្ត្រីទាំឡាយ ក៏នាំគ្នាស្រែកប្រកាសតបថា យើងរាល់គ្នាចូលចិត្ត ទៅថ្វាយបង្គំព្រះ មិនព្រម ទៅថ្វាយបង្គំបាយ៉ាបទេ។ ហេតុនេះហើយបានជាមានពាក្យថា : « ព្រះមានមិនចង់សំពះ មិនចង់ថ្វាយបង្គំ ម្តេចក៏ចង់ទៅសំពះឯបាយ៉ាបទៅវិញ » តាំងពីពេលនោះមក។

បន្ទាប់មក តាមឿង នាំក្រុមការ អ្នកមុខអ្នកការ និង បណ្តារាស្ត្រ ចេញទៅអញ្ជើញព្រះចន្ទរាជា ធ្វើព្រះរាជដំណើរចូលប្រថាប់ក្នុងបន្ទាយស្រុកពោធិ៍សាត់។ ជ័យជំនះ គេអាចចាត់ទុកតាមឿង ជាអ្នកយុទ្ធសាស្ត្រធំមួយ ព្រោះគាត់អាចធ្វើអព្យាកតកម្ម កងទ័ពស្តេចកន ចំនួន ៤ម៉ឺននាក់បាន ថែមទាំងអាចបញ្ចុះបញ្ចូលកងទ័ពនោះ ឱ្យត្រឡប់មកបំរើព្រះចន្ទរាជាវិញទៀត ដោយប្រើ វិធីនិយាយលោមជំនួសវិធីបង្ខិតបង្ខំ។ ខេត្តពោធិ៍សាត់ ជាទឹកដីរឹងមាំមួយរបស់ស្តេចកន ដូច្នេះព្រះចន្ទរាជា ត្រង់មានការប្រុងប្រយ័ន្ន ដូច្នេះឯង បានជាទ្រង់ហាមកងទ័ពទ្រង់ ទាំងខ្មែរ និង សៀម មិនឱ្យទៅកំហែងកំហល់រាស្ត្រប្រជាក្នុងខេត្តឱ្យសោះ ដើម្បីកុំឱ្យរាស្ត្រប្រជា មានសេចក្តីក្តៅក្រហាយ។ ទ្រង់ដាក់

អាយ័តថា : បើឈ្មោះណាពុំស្តាប់ព្រះរាជឱង្ការនេះទេ ស្តេចនឹងយក ទៅប្រហារជីវិត។ ទ្រង់ ឱ្យរឹបយក ទ្រព្យសម្បត្តិរបស់ពញាស្ងួគ៌ា មកព្រះរាជទានជារង្វាន់ ដល់នាយកងនាយទ័ព ដែលជាស្ន័គ្រពួកនឹងតាមឿង។ រួចទ្រង់តាំងតាមឿង ជាពញាស្ងួគ៌ា ជាចៅហ្វាយខេត្តពោធិ៍សាត់ និង ជាអគ្គមេបញ្ជាការកងទ័ពស្តេច។ ចំណែក កូនពញាមឿងទាំងបួននាក់ ទ្រង់តាំងឱ្យមានឋានន្តរសក្តិខ្ពង់ខ្ពស់ ជាមេទ័ពមុខក្រោយ :

កូនទី១ ឈ្មោះកែវ ឱ្យធ្វើជា ចៅពញាវង្សាអគ្គរាជ,

កូនទី២ ឈ្មោះអង ឱ្យធ្វើជា ចៅពញាបរទេស,

កូនទី៣ ឈ្មោះទេព ឱ្យធ្វើជា ចៅពញាវិបុលរាជ,

កូនទី៤ ឈ្មោះសុខ ឱ្យធ្វើជា ចៅពញារាជតេជះ។

បន្តិចក្រោយមក ចៅពញាទាំងបួន ទទួលព្រះរាជបញ្ជាលើកពល ៨០០នាក់ ទៅវាយស្រុក ក្រគរ, ខ្លុង, ក្រង ដើម្បីសាងបន្ទាយល្បាត ជាបន្ទាយមុខ នៃកងទ័ពស្តេច។



ស្ដេចនរោត្តម

## តាមឿងបូជាខ្លួន

ថ្ងៃមួយនៅ ក្រុងសន្លប់ដូនតីព្រៃនគ ស្ដេចកន នៅពេលថ្ងៃត្រង់ ម៉ោង ១១ នាំក្រុមបរិពារ ចុះស្រង់ទឹកក្នុងស្រះ រួចហើយនាំទៅប្រពាតសួន ឧទ្យានកំសាន្តហឫទ័យ។ បន្ទាប់មក ស្ដេចកន នាំស្រីស្នំ ទៅដល់ទីបន្ទប់ដំណេក ដែលមាននៅក្នុងសួនឧទ្យាននោះ នៅទីនោះ គាត់សណ្ដាប់ក្រុមភ្លេងមហោរី ក្រុមចម្រៀង ច្រៀង ភ្លុំប៉ីកែវ ពីរោះពេក បណ្ដាលឱ្យភ្លើតភ្លើនអារម្មណ៍ ហើយក៏ទម្រេកខ្លួន ទៅលើព្រះស្នំជាតិលាវម្នាក់ សំរានលក់ស្កប់ស្កល់ រហូតដល់ម៉ោង៣រសៀល។ ភ្ញាក់ពីដំណេកកាលណា ស្ដេចកន មានទឹកមុខព្រួយបារម្ភ ទើបបញ្ជាឱ្យ ហៅព្រាហ្មបុរោហិត និង ពិជ័យហោរា មកប្រាប់ថា ខ្ញុំសុបិនឃើញ « ព្រះចន្ទរះពីទិសខាងលិចលឿនគ្រឿនមកលើប្រាសាទ ហើយក៏បណ្ដាលឱ្យកើតជាភ្លើងឆេះ សន្ធោរសន្ធៅលើប្រាសាទ អណ្ដាតភ្លើងរាលដាល ទូទៅពេញព្រះនគរ ព្រមទាំងរាលក្ដៅដល់រាយកាយផង ខ្ញុំក៏ខំរត់ទៅទិសឦសាន តែភ្លើតក៏រាលឆេះរោលក្ដៅក្រហាយសព្វរាយកាយកាន់តែខ្លាំងឡើង »។

ពិជ័យហោរាទាយថា « ទ្រង់និមិត្តក្នុងថ្ងៃសៅរ៍នេះ ក្បួនទំនាយថា ត្រូវលើព្រះអង្គហើយគឺ ព្រះអង្គនឹងត្រូវទទួលគ្រោះកាច។តាមព្រះសុបិននេះ ព្រះអង្គនឹងដឹងការណ៍ឆាប់។ឯព្រះចន្ទដែលរះហើយ បង្កើតជាផ្កាភ្លើងឆេះរាលពាស

ពេញទសងនគរនោះ ទំនាយថា ទ្រង់នឹងមានសត្រូវ មកបៀតបៀនព្រះអង្គ នាំឱ្យព្រះអង្គថ្លោះការណ៍ធំណាស់ »។

ស្តេចកន ស្តាប់ហើយ ក៏ខឹងណាស់ចំពោះពិជ័យហោរា ដែលមិនចេះប្រចុប ឱ្យស្របនឹងគំនិត ក៏ឆ្លើតតបថា ហោរាទាយនេះ ដូចជាក្រៅក្បួនតម្រាហើយ ដូច្នេះ ចូរបុរោហិតពិនិត្យមើលវិញ តើខាងណាទាយខុស ខាងណាទាយត្រូវ។ ព្រះបុរោហិត ក្នុងព្រះរាជត្រកូល នឹកក្នុងចិត្តថា បើអញទាយ ដូចពិជ័យហោរា ច្បាស់ជា ស្តេចកនមិនពេញចិត្តឡើយ ដូច្នេះអញនឹងទាយប្រចុបប្រថែង រកផ្លូវឱ្យស្របចិត្តដែលស្តេចកនចង់បាន ថា « សូមទ្រង់មេត្តាប្រោសសុបិននិមិត្តព្រះអង្គនេះ បើតាមក្បួនហោរថា : ទេវតាមកប្រាប់ហេតុឱ្យទ្រង់ជ្រាបទាំង៥ប្រការ គឺ :

ប្រការទី១ ត្រង់ទ្រង់ ឃើញព្រះចន្ទ ពីទិសខាងលិចនោះ ទំនាយថា ព្រះអង្គនឹងបានសុខក្សេមក្សាន្ត ត្រជាក់ត្រជំទាំងអាណាប្រជានុរាស្ត្រ ក៏បានសេចក្តីរុងរឿង ប្រៀបបាននឹងពន្លឺព្រះចន្ទ។

ប្រការទី២ ត្រង់ព្រះចន្ទចេញភ្លើង ឆេះពាសពេញព្រះនគរនោះ ទំនាយថា ព្រះអង្គនឹងមានអំណាច អាចផ្សាយពេញទាំងប្រទេស ដូចភ្លើងឆេះទួទៅទាំង៨ទិស។

ប្រការទី៣ ត្រង់ថា ចំហាយក្តៅដល់ព្រះអង្គ ទំនាយថា នឹងមានសត្រូវមកប្រមាថព្រះនគរ។

ប្រការទី៤ ត្រង់ថា ត្រង់ទ្រង់ឃើញថា ព្រះចន្ទពេញបូរមីនោះ ទំនាយថា សត្រូវនោះ នៅក្នុងព្រះរាជត្រកូល បង្កើតហេតុចេញមកពីទិសមស្ចិម។

ប្រកាតទី៥ ត្រង់ឃើញថា ព្រះអង្គរត់ទៅទិសឦសាន ហើយភ្លើងនៅតែតាមរោលក្តៅដល់ព្រះអង្គនោះ ទំនាយថា បើកើតមានសត្រូវហើយ សូមព្រះអង្គស្តេចទៅតាំងទ័ព ទប់សត្រូវពីទិសឦសាន ទើបនឹងមានជ័យជំនះ។ សូមទ្រង់ព្រះមេត្តាប្រោស ! ព្រះសុបិននេះល្អទេ កុំព្រួយព្រះទ័យឡើយ។

ស្តេចកន ស្តាប់បុរោហិតព្យាករណ៍ហើយ មានចិត្តត្រេកអរខ្លាំងណាស់ តែដើម្បីរំដោះគ្រោះខ្លះ លោកក៏ឱ្យបុរោហិតផ្លុំប្រគំត្រែស័ង្ក ថ្វាយទឹកស័ង្ក សឹតព្នៅសៀតត្រចៀកដែរ ពេលនោះដែរ លោក ក៏យកស្លឹកព្នៅមួយសន្លឹក ទៅសៀតត្រចៀកឱ្យបុត្រាជាស្រឡាញ់ មានអាយុ ៥ឆ្នាំ។

ស្តេចកន ឱ្យរង្វាន់ដល់ព្រះបុរោហិត រីឯពិជ័យហោរា ត្រូវលោក ជេរប្រមាថ ប្រើគ្រប់ពាក្យអសុរោះ។ តែទោះបីយ៉ាងណា ពិជ័យហោរា ខំក្រាបទូលដោយជំនះថា សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គកុំអាលអរតាមទំនាយបុរោហិតក្រាបទូលនេះឱ្យសោះ ព្រោះការណ៍នេះ ប្រាកដជាមានដូច

ទូលថ្វាយ មិនដូចទំនាយបុរោហិតនេះទេ។ ឮដូច្នេះ ស្ដេចកនខឹងណាស់ លោកស្ទុះទៅយកដាវ មកកាប់ហោរាបណ្ដាលឱ្យហោរស្លាប់នៅទីនោះមួយរំពេច។

១០ថ្ងៃក្រោយមក នៅពេលប្រជុំជាមួយសេនាបតី និង មន្ត្រីទាំងពួក ចៅពញាលំពាំង ក្រាបទូលថា: ព្រះចន្ទរាជាបានត្រឡប់មកពីស្រុកសៀមវិញហើយ ឥឡូវស្ដេចសង្កត់បានខែត្របាត់ដំបង ពោធិ៍សាត់ថែមទៀត។ និយាយមិនទាន់ចប់សព្វគ្រប់ផង ព្រះរាជវរានុកូល ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ដំណឹងចុងក្រោយ ទើបមកដល់ថាចៅហ្វាយខេត្តពោធិ៍សាត់ លោកទទួលអនិច្ចកម្មក្នុងសង្គ្រាមទៅហើយ, ឥឡូវ ព្រះចន្ទរាជា តាំងពញាមឿងមេស្និលឱ្យឡើង ជាពញាសួគ៌ាលោកហើយ ហើយធ្វើជាមេទ័ពធំ។ ឥឡូវនេះ កូនទាំងបួន របស់មេស្និលនេះ តាំងជាមេទ័ពបាឡាត់មុខក្រោយ កំពុងវាយលុកយកស្រុកជាច្រើនបានថែមទៀត។

ស្ដេចកនដឹងដំណឹងនេះភ្លាម ក៏និយាយបញ្ជាទៅឱ្យមេទ័ពចក្រីថា: បងចក្រី ចូរបងឯងចេញទៅជាមេទ័ពធំ កេណ្ឌរាស្ត្រខែត្រខាងលិច ហើយលើកយ៉ាងស្រូតរូត ទៅទស់ទប់ទ័ព របស់ព្រះចន្ទរាជាឱ្យទាន់ការណ៍ សូមបងប្រឹងជួយខ្ញុំឱ្យអស់កម្លាំងចិត្តណ៎ា។ ពញាចក្រីឆ្លើយតបថា ទូលបង្គំ

លើកទ័ពទៅម្ដងនេះ បើចាប់បានតួខ្លា ឬ មិនបាន ក៏គង់ខ្លាត្រូវរបួស បង់ជន្ទ ឱ្យរាងចោលជាមិនខានដែរ។

សំដីសឹកនេះ នាំឱ្យស្ដេចកន មានហឫទ្ធចិត្ត លោកក៏ប្រគល់លំពែងក្រំ[52] មាសមួយ ជាអាជ្ញាសឹក ហើយឱ្យលើកទ័ពទៅតាំងនៅក្នុងខែត្រលង្វែក។ ចំណែក សម្ដេចចៅហ្វាកៅ ជាមា ឱ្យលើកទ័ពធំមួយទៀត ទៅតាំងនៅក្នុងខែត្រកំពង់សៀម។ ស្ដេចកន ប្រគល់ដាវមាស ជាអាជ្ញាសឹក ឱ្យកៅ។ លុះបាន កេណ្ឌរេហ៍ពលគ្រប់ខែត្រ បានគ្រប់គ្រាន់ហើយ ចៅហ្វាកៅ ក៏ចាត់ឱ្យឧទ័យធិរាជ ចៅហ្វាយអាសន្នទុក ឱ្យលើកទ័ពកាត់សំដៅទៅខែត្របាត់ដំបង សំរាប់ឆ្លងមកវាយបន្ទាយពោធិ៍សាត់ ពីក្រោយ កុំឱ្យព្រះចន្ទរាជារត់រួច។ ឯប៉ែកខាងកងទ័ព នៃចៅពញាចក្រី កាលកេណ្ឌរេហ៍ពលបានគ្រប់គ្រាន់ហើយ ក៏ចាត់ឱ្យ ពញាតេជោ ចៅហ្វាយស្រុកសំរោងទងលើកទ័ព ១ម៉ឺននាក់ ជាទ័ពមុខ, ឱ្យពញារាជាមេត្រី ចៅហ្វាយស្រុកភ្នំពេញ កាន់ពល ១ម៉ឺននាក់ជា

---

52 លំពែងក្រំ បញ្ចុះលោហធាតុផ្សេងៗ មានមាសជាដើមទៅក្នុងដែក។ សម័យបុរាណ គេទុកអាវុធបែបនេះ ពូកែសិក្តិសិទ្ធិណាស់។

ប៉ែកស្តាំ, ឱ្យចៅពញាវង្សាអនុជិត[53] ចៅហ្វាយស្រុកបាទី ដឹកនាំទ័ព ១ម៉ឺននាក់ ជាប៉ែកឆ្វេង, ឱ្យព្រះរាជវរានុកូល កាន់ទ័ព ១ម៉ឺននាក់ ជាទ័ពក្រោយ, ឯខ្លួនឯង កាន់ពល ១ម៉ឺន៥ពាន់នាក់ ជាទ័ពធំ។ ពេលទ័ព ចៅពញាចក្រី លើកមកដល់ស្រុកក្រគរ ក៏ប្រទះនឹងទ័ពពញាមឿង។ តាមឿងឃើញថា ទ័ពសត្រូវ មានចំនួនលើសទ័ពខ្លួនច្រើនណាស់ (ទ័ពតាមៀងមាន ៨ពាន់នាក់) តែមិនរួញរា ចេញតតាំងនឹងខ្លាំង។ នាយកែវ កូនច្បង របស់តាមឿង កាន់ទ័ព ២ពាន់នាក់ ចូលវាយទ័ពពញាតេជោ ជាទ័ពមុខ វាយកាប់សម្លាប់គ្នា ពពាក់ពពូន ស្លាប់ហូរឈាមដូចទឹកទរ តែទ័ពពញាតេជោមិនព្រមបែកសោះ។ ខណៈនោះ កូនតាមឿងឃើញពញាតេជោ ជិះសេះ ក៏ស្ទុះចូលដេញកាប់, សេះពញាតេជោ ក៏ភ្ញាក់គេចខ្លួនទៅប៉ះនឹងដើមឈើ បណ្តាលឱ្យធ្លាក់ម្ចាស់ខ្លួនទៅដី, កែវឆ្លៀតឱកាសដ៏ល្អនេះ រុកចូលទៅកាប់ពញាតេជាស្លាប់មួយរំពេច។ តែជ័យជំនះនេះ មិនបានហុចផលច្រើន នៅក្នុងសមរភូមិទេ ព្រោះទ័ពសពពញាតេជោនៅតែបន្តប្រយុទ្ធ មានមានៈរឹងរូសមិនព្រម

---

[53] អនុជិត មានន័យថា អ្នកឈ្នះរាប។

ចាញ់សោះ ថែមទាំង មានជំនួយ មកដល់ថែមហើយថែមទៀតផង។ កែវ យល់ឃើញថាបើបន្តតស៊ូ វាច្បាស់ជាចាញ់ជាពុំខានឡើយ ក៏សំរេចចិត្ត ថយទ័ពមកជម្រាបបិតាតាមដំណើរ។ ចំណែក ដៅពញារាជាមេត្រី និង ដៅពញាវង្សាអនុជិត ជួបប្រទះនឹងទ័ព ពញាអង និង ពញាទេពកូនទី២ និង ទី៣ របស់តាមឿង ម្នាក់កាន់ទ័ព ១ពាន់នាក់ចូលច្បាំងគ្នា កាប់ចាក់ពលនឹងពល ចៅហ្វាយនឹងចៅហ្វាយ ប្រកាប់គ្នាទៅវិញទៅមក។ ចៅពញាវង្សាអនុជិត ជាចៅហ្វាយស្រុកបាទី ក្នុងពេលដែលកំពុងប្រកាប់ជាមួយ ពញាវិបុលរាជទេព សេះរបស់ខ្លួន ផុងជើងក្នុងរណ្តៅផង និងប្រទ្បោតដោយស្នូរកាំភ្លើងផង ក៏បណ្តាលឱ្យធ្លាក់ទៅដី ដែលហុចឱកាសឱ្យពញាទេពកាប់ត្រូវស្មា បណ្តាលឱ្យគាត់ពិការជាទម្ងន់ តែត្រូវបាន នាយទ័ពរបស់ខ្លួននាំគ្នារត់ទៅជួយទាន់ ហើយនាំលោក ចេញពីសមរភូមិជាប្រញាប់។ តែនៅក្នុងសមរភូមិ ស្ថានការណ៍សឹក គ្មានដូរឡើយ ទ័ពទាំងសងខាងនៅតែបន្តច្បាំងគ្នាគ្មានថយដៃឡើង។ នៅពេលនោះ ទ័ពធំ របស់ពញាចក្រីមកដល់សមរភូមិ ពីលើខ្នងដំរី មេទ័ពស្តេចកន មោលឃើញ កូនតាមឿងទាំងពីរ កំពុងប្រយុទ្ធ ប្រកបដោយសេចក្តីក្លាហានណាស់ ក៏នឹកថប់ក្រែងទ័ពខ្លួនចាញ់ដៃសត្រូវ ក៏បញ្ជាឱ្យកងទ័ពចូលទៅជួយជាប្រញាប់។ តាមឿង និង កូនទី៤គាត់

ក៏លើកទ័ព ៦ពាន់នាក់ មកជួយច្បាំង ពញាអង និង ទេព ដែរ។ ការប្រយុទ្ធរវាងកងទ័ព បានប្រព្រឹត្តទៅអស់ពេលដ៏យូរ តែមិនមានខាងណាអន់ជាងខាងណាឡើយ។ តែតាមឿង មានចំនួនទ័ពតិចជាងច្រើនណាស់ ទោះបន្តច្បាំងក៏មិនអាចយកជ័យជំនះបានដែរ។ លុះពេលព្រលប់ តាមឿង ឱ្យវាយស្គរ ជាសញ្ញាឱ្យថយទ័ពឈប់ច្បាំង។ ពញាចក្រី ឃើញដូច្នោះ ក៏សុខចិត្តថយទ័ពដែរ ព្រោះឃើញថា រេហ៍ពលខ្លួន ក៏អស់កម្លាំងខ្លាំងណាស់ដែរ បើដេញតាម ក៏គ្មានប្រសិទ្ធិភាពអ្វីនោះដែរ នឹងអាចយកឈ្នះបាន ម្យ៉ាងទៀតវាដល់ពីយប់ទៅហើយ។ តាមឿង និង កូនប្អូននាក់ នាំគ្នាថយទ័ព មកបន្ទាយខេត្តពោធិ៍សាត់ យកដំណឹងគ្រប់ប្រការថ្វាយជំរាបព្រះចន្ទរាជា។

លុះព្រឹកឡើង ទ័ពរបស់ចៅហ្វាកៅ ក៏មកជួបទ័ពចៅពញាចក្រី។ មេទ័ពធំទាំង ប្រជុំគ្នា នឹងរៀបចំយុទ្ធសាស្ត្រវាយបន្ទាយពោធិ៍សាត់ ជាប្រញាប់។ ចៅហ្វាកៅ ចាត់ទ័ពជា៥កង ដូចតទៅ :

ចៅពញាចក្រី ឃុំទ័ព ៣ម៉ឺននាក់ ជាទ័ពមុខ ឬ ទ័ពស្រួច។

ចៅពញាមេត្រី ទិព្វ ឃុំទ័ព ២ម៉ឺននាក់ ជាទ័ពប៉ែកឆ្វេង។

ចៅពញាស្រែនៀសេនាឫទ្ធីជ័យ ចៅហ្វាយខេត្តលង្វែក ឃុំពល ១ម៉ឺន៥ពាន់នាក់ ជាទ័ពប៉ែកស្តាំ។

ថៅពញាសេនាសង្គ្រាម ជាថៅហ្វាយស្រុក ខេត្តអមរគីរីន្ទបូរ ឬ ស្រុកបរិបូណ៌ ឃុំពល ១ម៉ឺន៦ពាន់នាក់ជាទ័ពក្រោយ។

៦ខ្លួនឯង ថៅហ្វាកៅ ជាមាស្តេចកន ឃុំពល ៤ម៉ឺននាក់ជាមេទ័ពធំ។

លុះរៀបក្បួនទ័ពរួចហើយ ក៏ឱ្យកងពិសេស លើកទ័ពដេញតាមទ័ពតាមឿង តែតាមឿងរត់ចូលបន្ទាយពោធិ៍សាត់បាត់ទៅហើយ។ ដឹកដំណឹងថា ទព័សត្រូវលើកមកវាយបន្ទាយពោធិ៍សាត់ហើយ ព្រះចន្ទរាជា ទ្រង់ឱកេណ្ឌរាស្ត្រធ្វើទាហានបាន ២ម៉ឺននាក់ថែមទៀត។ មិនយូរប៉ុន្មាន កងទ័បថៅហ្វាកៅ មកដល់ ក៏ចូលវាយបន្ទាយ។ ពីកំផែងបន្ទាយ ព្រះចន្ទរាជា មើលឃើញ ទព័សត្រូវ ណែនណាន់តាន់តាប់ ដូចស្រមោចរោមស្ករ វាយទ័ពទ្រង់ តែវាយមិនបាន។ កាលដឹងថាវាយបែបនេះ ពុំបានជ័យជំនះសោះ ថៅហ្វាកៅ ក៏ដូរយុទ្ធសាស្ត្រ បោះទ័ពព័ទ្ធថោមបន្ទាយម្តងដើម្បី បង្អត់អាហារទ័ពស្តេច ដរាបដាច់ពោះគ្រប់ៗគ្នាផងរហូតដល់ស្លាប់។ ព័ន្ធនោះ យូររហូតដល់១ឆ្នាំ កងទ័ពព្រះចន្ទរាជា ចេញពីបន្ទាយមិនរួច ស្បៀងអាហារក្នុងបន្ទាយក៏ចេះតែហោចទៅ គួរបារម្ភណាស់។ តែក្នុងរយៈពេលដ៏យូរនោះ ទ័ពថៅហ្វាកៅ ជួបប្រទះនឹងបញ្ហាជញ្ជូនស្បៀងដែរ

ក៏នាំគ្នាដកថយ ចម្ងាយ ៣សិន[54] (៩០ ម៉ែត្រ) ពីបន្ទាយខ្លាំង។ ឱ្យថយនេះ ប្រយោជន៏ឱ្យកងទ័ព ផ្លាស់ប្តូរគ្នា ចេញទៅរកស្បៀងអាហារ ក្នុងភូមិជិតខាង។ ចរភាព នៃកងទ័ពចៅហ្វាកៅនេះ បើកសេចសង្ឃឹម ដល់ទ័ពព្រះចន្ទរាជាថានឹងអាចវាយ រត់ចេញពីការឡោមព័ទ្ធ របស់សត្រូវបាន។ តែតាមឿងក្រាបទូលព្រះចន្ទរាជាថា : យើងនឹងគិតវាយទំលាយចេញ នោះក៏ចេញរួចបានដែរ តែពលយើងត្រូវស្លាប់ច្រើនជាមិនខាន ព្រោះទ័ពយើងមានតែ២ម៉ឺននាក់ ៦ទ័ពសត្រូវវិញមានប្រមាណ១សែននាក់, តែបើយើងរឹងតែនៅក្នុងបន្ទាយ ប្រាកដជាយើងជួបប្រទះនឹងការខ្វះខាតស្បៀងអាហារ សំរាប់រេហ៏ពល។ នៅចំពោះមុខទ្វេគ្រោះនេះ ទូលព្រះបង្គំជាខ្ញុំ គិតយកគំនិតមួយមកសូមទទួលអាសាគឺ ទៅកេណ្ឌកងទ័ពបិសាច ឱ្យមកចោមវាយទ័ពសត្រូវ, បើទ្រង់ព្រះរាជអនុញ្ញាត ទូលព្រះបង្គំយល់ឃើញថា មុខជានឹងឈ្នះខ្លាំងដោយងាយ, បើទ្រង់ព្រះករុណាពិសេស យល់ព្រម

---

54 ១សិន មានប្រវែង ២០ព្យាម, ១ព្យាម ប្រវែងមួយកាងដៃគឺប្រវែងបួនហត្ថ។ បើគិតជាប្រវែងជាមែត្រ ១សិន មានចម្ងាយប្រមាណ ៣០ ម៉ែត្រ។

ផងនោះ សូមឱ្យជិក រណ្តៅកណ្តាលបន្ទាយនេះ ជាប្រញាប់ ដើម្បីទូលព្រះបង្គំនឹងបានគិតថ្វាយ ឱ្យទាន់ពេលវេលា។

ព្រះចន្ទរាជា កាលទ្រង់ព្រះសណ្តាប់តាមឿង ទូលសុំយ៉ាងនេះ ទ្រង់ពុំជឿសោះទេ ទើបទ្រង់គ្រវីព្រះសិរសា ហើយត្រាស់ថា : « ពីបុរាណរៀងមក យើងពុំដែលឮថា មានឈ្មោះណាទៅកេណ្ឌយក ខ្មោចបិសាច មកជួយច្បាំង មនុស្សម្តងឡើយ, ណ្ហើយអ្នកថៅពញា លែងគិតគំនិតបែបនេះទៅចុះ ព្រោះជា គំនិតមិន ដែលមានអ្នកណាធ្វើបានពីមុនផង និង ជាកិច្ចការមួយ ដែលខ្ញុំមិនជឿថា មានប្រសិទ្ធិភាពទាល់តែសោះផង »។

តាមឿងក្រាបទូលតបថា : « បើទ្រង់មិនសព្វព្រះហឫទ័យឱ្យគិតធ្វើតាមថំណេះ និង តាមមន្តវិជ្ជាកាតទូលព្រះបង្គំទេ ព្រោះទូលព្រះបង្គំនឹង អារ-ក ឱ្យស្លាប់នៅទីនេះក្នុងឥឡូវនេះហើយ ព្រោះបើនឹងរស់នៅតទៅ ក៏មិនបានជួយយកអាសាផែនដីថ្វាយព្រះអង្គដល់កម្រិតដែរ »។

ថាហើយ តាមឿង ក៏ហូតដាវនឹងអារ-ក តាមពាក្យដែលខ្លួនបានក្រាបទូល។ ខណៈនោះ ព្រះចន្ទរាជា ត្រង់ក្រឡេកឃើញទាន់ ក៏ទ្រង់ស្ទុះទៅចាប់ដាវនោះចេញពីដៃ ហើយទ្រង់ត្រាស់ថា : « កុំ ! កុំ ថៅពញា កុំសម្លាប់ខ្លួន ខ្ញុំស្តាយ

លោកណាស់ ខ្ញុំព្រមតាមថៅពញាហើយ ដូច្នេះ បើថៅពញាគិតឃើញដូចម្ដេចស្រួល សូមធ្វើតាមគំនិតចុះ »។

ទទួលបានការអនុញ្ញាតរួចហើយ តាមឿង ក៏ចាត់កូនទាហានឱ្យជីករណ្ដៅធំមួយ ជម្រៅ៨ហត្ថ ៤ជ្រុង, ឱ្យធ្វើរានទេវតា ៧ថ្នាក់ដាក់បាយសី ទឹកអប់ និង គ្រឿងបូជា ហើយឱ្យធ្វើរាជវតិព័ទ្ធជុំវិញ។ លុះរៀបចំសព្វគ្រប់ហើយ តាមឿងក៏ស្លៀក-ស ពាក់-ស ហើយឱ្យរៀបចំភ្លេងចាំប្រគំទាំង៨ទិស ផ្ដាំនឹងចន្ទជាសំឡាញ់ ដែលជាជំទប់មេស្នឹងភ្នំក្រវាញថា : ឱសម្លាញ់ឯង នៅជាមេស្នឹងជំនួសអញ ដើម្បីនិយាយតពីព្រះមហាក្សត្រមកអញ កុំបីឱ្យព្រះអង្គនិយាយផ្ទាល់នឹងអញឡើយ។ មួយទៀតដល់ថ្ងៃស្អែកពេញបូណ៌មី ខែពិសាខ វេលាយប់ បើឯងឮសូរសន្ធឹកខ្ទរខ្ទារមេឃក្នុងដីហើយ ឱ្យឯងក្រាបទូលព្រះចន្ទរាជា លើកទ័ពចេញពីបន្ទាយទៅច្បាំងនឹងសត្រូវ ប្រាកដជាមានជ័យជំនះលើសត្រូវជាពុំខាន។ ផ្ដាំសព្វគ្រប់ហើយ តាមឿង ក៏ថ្វាយបង្គំលាព្រះចន្ទរាជារួចក៏លោតចូលក្នុងរណ្ដៅសម្លាប់ខ្លួនទៅកេណ្ឌបិសាចមកជួយច្បាំង។

រឿងតាមឿងនេះ មានចារទុកបែបផ្សេងមួយទៀតនៅក្នុងព្រះរបាក្សត្រថា : ពញាមឿងនេះ ជាមេស្នឹង មានកូនបួននាក់ មានសម្លាញ់ម្នាក់ឈ្មោះចន្ទ ធ្វើជាជំទប់មេ

ស្នឹងក្រវាញ។ ក្នុងគ្រានោះ សម្តេចចៅពញាចន្ទរាជា ទ្រង់មានម្នាងម្នាក់ឈ្មោះអ្នកម្នាងខៀវ។ អ្នកម្នាងនេះ មានគភ៌៧ខែ ហើយមានបាវស្រីម្នាក់ឈ្មោះនាងពេញ។ សាស្ត្រាវបាក្សនោះចារបន្តថា ក្នុងគ្រាដែលព្រះចន្ទរាជា លើកទ័ពពីក្រុងស្រីអយុធ្យាមកខេត្តពោធិ៍សាត់នោះ តាមឿង នាំដំរីសេះ ជាច្រើនទៅថ្វាយ ទុកធ្វើសង្គ្រាម ប្រយុទ្ធនឹងស្តេចកន។ ព្រះចន្ទរាជា មកដល់ខេត្តក្រគរ បានប្រយុទ្ធនឹងទ័ពស្តេចកន ប៉ុន្តែខាងទ័ពស្តេចកនឈ្នះ, ព្រះចន្ទរាជាក៏ដកទ័ពថយ ទៅប្រថាប់ទ័ព នៅបន្ទាយមានជ័យ ខែត្រពោធិ៍សាត់ក្នុងឃុំបាក់នឹមវិញ។ ចំណែក តាមឿង ក៏រៀបចំពិធីធ្វើអត្តឃាតកម្មទៅកេណ្ឌបិសាចឱ្យមកជួយច្បាំងព្រះចន្ទរាជា។ មុននឹងលោតចូលរណ្តៅសម្លាប់ខ្លួន តាមឿងផ្តាំឱសម្លាញ់ចន្ទ ឱ្យធ្វើមេស្នឹងជំនួសគាត់ ដើម្បីនិយាយតពីព្រះមហាក្សត្រ មកខ្មោចគាត់។ មួយទៀតដល់ថ្ងៃស្អែកពេញបូណ៌មី ខែពិសាខ វេលាយប់ បើឯងឮសូរសទ្ទឹកខ្ទរខ្ទារមេឃក្នុងដីហើយ ឱ្យឯងក្រាបទូលព្រះចន្ទរាជា លើកទ័ពចេញពីបន្ទាយទៅច្បាំងនឹងសត្រូវ ប្រាកដជាមានជ័យជំនះលើសត្រូវជាពុំខាន។ រីឯអ្នកម្នាងខៀវ កាលឮថា តាមឿង ចូលរោងរាជវ័តិ តាំងពិធីបួងសួងទេវតាដូច្នោះ អ្នកម្នាង ក៏ថ្វាយបង្គំលា ព្រះចន្ទរាជា ចូលទៅក្នុងទីព្រះរាជពិធីដែរ។ លុះបួងសួងទេវតាស្រេចហើយ អ្នកមេនាងខៀវ

និង តាមឿង ក៏លោតទាំងពីរនាក់ទៅក្នុងរណ្តៅ។ ព្រះចន្ទរាជា និង បណ្តាជាខ្ញុំ ក្រុមរាជាការជួយឃាត់ផងក៏ពុំស្តាប់។ ក្នុងគ្រានោះ កូនតាមឿង ៤ទាំងនាក់ កាលឃើញបិតាលោតសម្លាប់ខ្លួន ទៅកេណ្ឌបិសាចដូច្នោះ ក៏និយាយគ្នាថា បិតាយើងទៅតែម្នាក់ឯង គ្មានគេទៅជួយបម្រើ ជួយគិតកេណ្ឌបិសាចសោះ បើយ៉ាងនេះ ក្រែងឱពុកយើងធ្វើការនេះពុំទាន់ការ ដូច្នេះត្រូវយើងទៅកេណ្ឌទ័ពខ្មោចជាមួយនឹងគាត់។ ថាតែប៉ុណ្ណោះ កូនទាំង៤នាក់នោះ ក៏ស្ទុះលោតទៅតាមបិតាទាំងអស់គ្នា។ តែខណៈនោះ ខ្ញុំរាជាការ ចាប់មិនឱ្យលោតតាម បានពីរនាក់មកវិញគឺ ថៅពញទេព និង សុខ។

ដូចបណ្តាំតាមឿងផ្តាំសម្លាញ់ចន្ទ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខនោះ ក៏ស្រាប់តែឮសូរសន្ធឹកខ្ទរខ្ទារមហិមានៅលើមេឃ និង ក្នុងដី នាំឱ្យភិតភ័យតក្កមាក្រៃៈលែង ហាក់បីដូចជាកក្រើកក្រឡាមហាប្រពី។ ខណៈនោះ ចន្ទមេស្ទឹងយកសេចក្តីក្រាបទូលព្រះចន្ទរាជា តាមបណ្តាំតាមឿងដែលផ្តាំនោះ។ ព្រះចន្ទរាជា ក៏លើកទ័ពចេញទៅចោមបន្ទាយសត្រូវ។ ឯទ័ពសត្រូវ បានឮសូរសន្ធឹកខ្ទរខ្ទារ កើតមេឃក្នុងដីដូច្នោះ ក៏ភិតភ័យញ័រដៃ រន្ធត់តក់ស្លុត រត់ចោលបន្ទាយ ចោលសាស្ត្រាវុធ រត់គេចខ្លួនឱ្យតែបានរួចជីវិតតែសព្វខ្លួន។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

ថ្ងៃក្រោយមក នាងពេញ ជាខ្ញុំបំរើសេពអ្នកម្នាងខៀវ ក៏ទៅលោតទឹកសម្លាប់ខ្លួន នៅស្ទឹងពោធិ៍សាត់ ជិតផ្សារក្រោមនោះ ទៅតាមបំរើចៅហ្វាយខ្លួននៅឋានខ្មោច, រួចកើតជាបិសាច ចិតនៅទីកន្លែងដែលមានដំបូក៣។ អ្នកម្នាងខៀវ កើតជាដំបូកមួយនៅខាងជើង, តាមឿង កើតជាដំបូងមួយនៅខាងត្បូង កូនច្បងតាមឿង ពេញកែវ កើតជាដំបូកមួយនៅខាងលិច។ ដំបូកទាំង៣នោះ ដុះជាប់គ្នាជា៣ដុំ ទៅជាដំបូកផ្នូកផ្នូល នៃព្រះនគរ ដូចដែលនិយាយក្នុងទំនាយខាងក្រោមនេះ :

១. ដំបូកខាងជើង គឺដំបូកអ្នកម្នាងខៀវ ជាដំបូកផ្នូកផ្នូល ខាងម្ចាស់ផប្អូនដី។

២. ដំបូងខាងត្បូង គឺដំបូកតាមឿង ជាដំបូកផ្នូកផ្នូល ខាងចៅហ្វាយស្រុក។

៣. ដំបូងខាងលិច គឺដំបូកកូនពេញមឿងទាំងពីរនាក់ ជាដំបូកផ្គូកផ្នូលខាងក្រវាញ។

៤. កោះមួយនៅក្នុងស្ទឹង នៃខែត្រពោធិ៍សាត់នោះ នៅផ្សារក្រោម ជាកោះនាងពេញ, កោះនេះ ជាផ្នូកផ្នូលខាងចៅហ្វាយស្រុកដែរ។

ក្រោយមកដំបូកនាងខៀវ ប្រែឈ្មោះថា ដំបូកកន្ទោងខៀវ។ បើដំបូកនេះ ដុះលូតលាស់ ទំនាយថា ព្រះមហាក្សត្រនឹង

ក្សេមក្សាន្ត។ បើដំបូលនេះ របេះរិលរេច ទំនាយថា ព្រះមហាក្សត្រនឹងមានទុក្ខ ឬ មានរោគ។ បើដំបូលនេះប្រេះ ឬ បែក ទំនាយថា ព្រះមហាក្សត្រនឹងអស់ព្រះជន្ម។

ដំបូកតាមឿង ប្រែឈ្មោះថា ដំបូកឃ្លាំងមឿង ពីដើមហៅខ្លោងមឿង តែពាក្យនេះ ជាពាក្យសៀម ប្រែជាខ្មែរថា អ្នកតាចាស់ស្រុក។ បើដំបូកដុះលូតលាស់ ទំនាយថា ចៅហ្វាយស្រុកនឹងក្សេមក្សាន្ត។ បើដំបូលនេះ របេះរិលរេច ទំនាយថា ចៅហ្វាយស្រុកនឹងមានទុក្ខព្រោះកិច្ចការរាជការ ឬ មានរោគ។ បើដំបូលនេះប្រេះ ឬ បែក ទំនាយថា ចៅហ្វាយស្រុកនឹងអស់បុណ្យ ឬ មស់ជីវិត។

ដំបូកកូនតាមឿងខាងលិច ប្រែឈ្មោះថា ដំបូកក្រវាញ។ ដុះលូតលាស់ ទំនាយថា ក្រវាញនឹងកើតដើមច្រើន ។ បើដំបូលនេះ របេះរិលរេច ទំនាយថា ក្រវាញនោះពុំសូវផ្លែផ្កាទេ។ បើដំបូលនេះប្រេះ ឬ បែក ទំនាយថា ភ្លើងព្រៃនឹងឆេះក្រវាញអស់។ បើសត្វទៅធ្វើរូងនៅក្នុងដំបូកនេះ ទំនាយថា នឹងមានបរទេសដណ្តើមយកសួយ[55]ក្រវាញនោះ។

---

55 សួយ : អាករ, ពន្ធខ្លួន ដែលត្រូវហូតយកក្នុងទីតំបន់មួយៗ។

រីឯកន្លែងដែលនាងពេញលោយសម្លាប់ខ្លួនក្នុងស្ទឹងនោះ ឈ្មោះថា « កន្លែងដូនពេញ »។ បើប្រាំងស្ទឹងនោះ ដុះលូតលាស់ ទំនាយថា ថៅហ្វាយស្រុកនឹងក្សេមក្សាន្ត។ បើប្រាំងស្ទឹងនោះ របេះរិលរេច ទំនាយថា ថៅហ្វាយស្រុកនឹងមានទុក្ខក្នុងផ្ទះ ឬ មានទុក្ខពីរាជការ។ បើប្រាំងស្ទឹងនោះបាក់ ទំនាយថា ថៅហ្វាយស្រុកនឹងអស់បុណ្យ។

## របៀបដែលគេគោរព អ្នកតាឃ្លាំងមឿង

១. ដល់ខែពិសាខ មេស្ទឹងត្រូវតែងខ្លួន ឱ្យមានមនុស្សពាក់ស្នែងទន្សោង តាមរបៀបពញាមឿង កាលដែលលោកនៅរស់ ដើរបរបាញ់សត្វព្រៃ។ ត្រូវឱ្យមានភ្លេងលេងច្រៀងរាំថ្វាយក្នុងពេលព្រឹក។ ក្នុងច្បាប់ដើម មិនមានបង្គាប់ឱ្យលេងភ្លេងបទអ្វីទេ ប៉ុន្តែតាមពាក្យចចាមរាមថា ត្រូវលេងភ្លេងរាមរបៀបលៀងអារ័ក្ស។

២. ឯរបៀបដង្វាយអ្នកតាឃ្លាំងមឿងគឺ ចំអាបពីរគូ, ប្រាក់៥ស្លឹក, សំពត់សមួយអារ, កាស៥ទៀន, ស្លាធ័រ៤, ស្លាជម៤, ក្បាលជំរឺមួយគូ, មាន់ស្ងោមួយគូ, ផ្លែឈើ៤តោក។ មួយតោកៗ ត្រូវមានអង្ករទ្រាប់បាតតោកនោះ ចំនួនមួយនាឡិ, ស្លាពីរពាន់, ស្រាពីរដប។ នេះជាដង្វាយព្រមទាំងរបៀប ដែលត្រូវរៀបចំឱ្យពួកអ្នកល្បែងនោះសប្បាយជាច្រើនផង។

៣. ឯដង្វាយអ្នកតាកន្ទោងខៀវនោះ របៀបដូចដង្វាយអ្នកតាឃ្លាំងមឿងដែរ ខុសគ្នាតែត្រង់ដង្វាយកន្ទោងខៀវត្រូវមានកន្ទោងជំមួយ ដាក់បង្អែម ចំអាប និង ពងមាន់៧។

៤. ក្នុងថ្ងៃដែលឡើងអ្នកតានោះ មេស្រុក និង អ្នកស្រុកទាំងបួនទិសត្រូវយកទឹកទៅជូនចៅហ្វាយស្រុក។ ចៅហ្វាយស្រុក ត្រូវទទួលទឹកនោះហើយ លើកទឹកចាក់ឱ្យចំក្បាលដំបូកអ្នកតាឃ្លាំងមឿង។ បើទឹកនោះ ហូរទៅទិសខាងណាច្រើនជាង ទំនាយថា ភ្លៀងច្រើនខាងទិសនោះ។

ឯត្រង់ទីដីដែលហៅថា « កន្លែងដូនពេញ » នោះ ក្នុង១ឆ្នាំ មេស្រុក និង អ្នកស្រុក ត្រូវយកកន្ទោងជំមួយ ដាក់ពងមាន់៧ និង បង្អែមចំអាប ទៅថ្វាយនៅត្រង់ទីនោះ សូមសុខសប្បាយ បើខាន មិនដាក់ទេ អ្នកស្រុក និងកើតជម្ងឺដម្កាត់ជាខ្លាំង។

## អត្ថាធិប្បាយទី២ ជាមតិផ្ទាល់ខ្លួន

រឿងតាមឿង សម្លាប់ខ្លួនទៅកេណ្ឌបិសាច មកជួយច្បាំងព្រះចន្ទរាជានេះ វាពិតជារឿងប្រឌិត ឬ ជាអបិយជំនឿ តែបុព្វបុរសខ្មែរ លោកបញ្ចូលទៅក្នុងព្រះរាជពង្សាវតា ព្រោះគិតថាតាមឿង ជាអ្នកជួយអាសាច្រើនណាស់ ដល់ព្រះចន្ទរាជា ដែលជាគុណូបការៈមួយ ដែលរាជានិយមខ្មែរ ពុំអាច

ភ្លេចបាននោះឡើយ។ ម្យ៉ាងមួយទៀត ជ័យជំនះ របស់ទ័ព ព្រះចន្ទរាជា នៅខេត្តពោធិ៍សាត់ ដែលវាគ្មានសង្ឃឹម ទាល់តែសោះ ដ្បិតរេហ៍ពល មានចំនួនតិច បើប្រៀបធៀប នឹងទ័ពថៅហ្វាកែវ ដែលមានចំនួនច្រើនលើសលុប នាំឱ្យ បុព្វបុរសខ្មែរយើង លោកគិតថា វាជាស្នាដៃ នៃកម្លាំង អធម្មជាតិ ដោយសារតាមឿង ជាមេស្នឹង មានឈ្មោះ ល្បី ល្បាញនៅភ្នំក្រវាញ ហ៊ានបូជាជីវិត ទៅស្វែងរកបិសាចនៅ បរលោក នាំមកជួយមនុស្ស។ កត្តា សគុណ និង ជ័យជំនះ ពិសេសនោះ ត្រូវចាំបាច់ យកវាមកកត់ទុក ឱ្យមានជីវិត នៅក្នុងសតិប្រជារាស្ត្រ។

តែបើយើង សាកល្បងពិចារណាបន្តិច អំពីជ័យជំនះនោះ យើងឃើញថា វាមានកត្តាពីរ ដែលតាមឿង យកមកធ្វើជា ផែនការកលល្បិចសឹក គឺ រដូវភ្លៀង និង បញ្ហាខ្វះស្បៀង របស់ទ័ពសត្រូវ។ ទ័ពថៅហ្វាកែវ មានរេហ៍ពល ប្រមាណ ១ សែននាក់ យកកលយុទ្ធ ឡោមព័ទ្ធ តែបើយើង សាកល្បង ពិចារណាបន្តិច អំពីជ័យជំនះនោះ យើងឃើញថា វាមាន កត្តាពីរ ដែលតាមឿង យកមកធ្វើជាផែនការកលល្បិច សឹក គឺ រដូវភ្លៀង និង បញ្ហាខ្វះស្បៀង របស់ទ័ពសត្រូវ។ ទ័ព ថៅហ្វាកែវ មានរេហ៍ពល ប្រមាណ ១សែននាក់ យកការ ឡោមព័ទ្ធបន្ទាយ ជាកលយុទ្ធសឹក តែតាមឿងជាមេទ័ព ឈ្លាសស្ទាត់ ឥតភាំងភ្លឹក មិនភ័ន្តវង្វេង ទោះបីខ្លាំងសន្ធឹក

គាត់អាចវាយគបានជានិច្ច ដែលពន្យារពេល ការឡោមព័ន្ធនោះដ៏យូរ នាំបង្កើតបញ្ហាខ្វះស្បៀង នាំឱ្យរេហ៏ពលរបស់ចៅហ្វាកែវ បាក់កម្លាំងចិត្ត ហើយប្រហែលជា ជួបប្រទះនឹងជម្ងឺគ្រុនចាញ់ ព្រោះនៅដំបន់នោះ ជាដំបន់ចាញ់ផង។ តាមឿង ស្គាល់ដីស្រុកគាត់ច្បាស់ណាស់ ដូច្នេះគាត់ដឹងច្បាស់ កន្លែងណា ដែលសត្រូវ អាចធ្វើបន្ទាយមាំមួនបាន និង មិនអាចធ្វើបាន។ម្យ៉ាងមួយទៀត គាត់យកពេលដែលកំពុងធ្លាក់ភ្លៀងខ្លាំង[56] (ខែពិសាខ) ឱ្យព្រះចន្ទរាជា វាយចេញពីការឡោមព័ន្ធសត្រូវ ដែលខ្មាំងមិនគិតស្មានដល់។ រឿងតាមឿង និង កូនពីរនាក់ បូជាជីវិតយើងឧបមាថា តាមឿង និង កូនប្រុសពីរនាក់ មានរបួសធ្ងន់នៅសមរភូមិនៅស្រុកក្រគរ តែគេនាំគ្នាលាក់ជិត មិនឱ្យសាធារណជន និង រេហ៏ពលដឹង ព្រោះជាការលាក់បាំង

56 បណ្ដាំតាមឿង ទៅចន្ទ ជាសំឡាញ់ថា ពេញបូណ៌មី ខែពិសាខ វេលាយប់ បើឯងឮស្គរ សន្ទឹកខ្ទរខ្ទារលើមេឃ ក្នុងដីហើយ ឱ្យឯងក្រាបទូលព្រះចន្ទរាជា លើកទ័ពចេញពីបន្ទាយ ទៅច្បាំងនឹងសត្រូវ ប្រាកដជាមានជ័យជំនះលើសត្រូវជាពុំខាន។ បណ្ដាំ អាចបកស្រាយបានថា នៅថ្ងៃពេញបូណ៌មី បើប៉ែរ ជាមានភ្លៀងធំមានផ្គរលាន់ និង រន្ទះខ្លាំងពេកក្រៃ ត្រូវនាំទ័ពចេញវាយបន្ទាយចំណុចខ្សោយខ្មាំង រំដោះខ្លួន ពិតជាបានជាពុំខាន។

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

ជាកលល្បិចសឹក។ ហើយលុះគេ នាំគាត់មកដល់បន្ទាយពោធិ៍សាត់ តាមឿងដឹងថារបួសគាត់និង កូនគឺពិជាមិនអាចព្យាបាលសះជាបាននោះឡើយ រង់ចាំតែមរណភាពតែប៉ុណ្ណោះ។ ដូច្នោះ គាត់មានគំនិត យកសេចក្ដីស្លាប់គាត់ និង កូនប្រុសទាំងពីរ ជាប្រយោជន៍ដល់កងទ័ព ហើយផ្ដាំផ្ញើរ កលយុទ្ធសឹកដល់សំឡាញ់ចន្ទ ជាបាឡាត់មេស្នឹងឱ្យយកទៅអនុវត្ត។ អត្ថគំនិតទាំងឡាយរបស់គាត់នោះឯងដែលនាំឱ្យខ្មែរយើងទាំងនគរ ទុកព្រលឹងគាត់ ជាអ្នកតាស្រុកពោធិ៍សាត់, ជាមេទ័ពមានទេពកោសល្យ និង ជាវិរបុរសជាតិ រហូតមកដល់សព្វថ្ងៃ។



## កម្លាំងប្រយុទ្ធ នៃកងទ័ព របស់ព្រះចន្ទរាជា

ជ័យជំនះ ព្រះចន្ទរាជា នៅខេត្តពោធិ៍សាត់ ជាការលើកទឹកចិត្តខ្លាំងណាស់ដល់ព្រះអង្គខ្លួនឯង និង រេហ៍ពលព្រះអង្គ។ ជាជ័យជំនះ ឮទូទ័រសព្វទិសទីនៅក្នុងនគរ។ ក្រោយពីធ្វើបុណ្យឧទ្ទិសកុសលជូនខ្មោចតាមឿង, ក្នុងពេលព្រឹក មានមនុស្សម្នាក់ឈ្មោះហ្វជ័យ យកដំរីផ្លុកមួយ កំពស់ ៦ ហត្ថ ១២ ធ្នាប មានរូបល្អបរិសុទ្ធ មកក្រាបទូលថ្វាយព្រះចន្ទរាជា។ ព្រះអង្គសព្វព្រះទ័យណាស់ ទុកដំរីជាព្រះទីនាំង តាំងថ្វាយនាមជា ព្រះពិជ័យគជា។ បន្ទាប់មក មានបណ្ដារាស្ត្រ និង អ្នកមុខអ្នកការ ចូលក្រាបថ្វាយ ដំរី សេះ សំរាប់បន្តធ្វើសឹកនិងស្ដេចកន។ ចំណែកទ័ព ចៅហ្វាកៅ និង ចក្រីកែវ កាលបែកទ័ព ក៏ដកថយមកតាំងនៅស្រុកក្រគរ។ បីថ្ងៃក្រោយមក ចៅហ្វាកៅ និង ចក្រីកែវ ក៏លើកទ័ពមកវាយបន្ទាយព្រះចន្ទរាជាម្ដងទៀត តែមិនទាន់វាយចូលភ្លាមទេ ព្រោះចាប់ទ័ពពញាឱទយធិរាជ ជាចៅហ្វាយស្រុកខែត្រអាសន្ទទុក មកព័ន្ធ បន្ទាយសត្រូវពីក្រោយ។ ដឹងដំណឹងថា កងទ័ពសត្រូវ កាន់តែកង្ហើញ ចូលជិតបន្ទាយណាស់ហើយ ព្រះចន្ទរាជា ទ្រង់លើកកងទ័ពចេញច្បាំងភ្លាម។ កូនខ្មោចតាមឿងពីរនាក់ដែលនៅរស់ដឹកនាំទ័ពស្រួចចំនួន ១ម៉ឺននាក់ វាយទ័ពមុខចៅហ្វាកៅ មានចំនួន ៣ម៉ឺននាក់។ ព្រះអង្គខ្លួនឯង ដឹកនាំទ័ពចំនួន ១

ម៉ឺន៥ពាន់នាក់ ជាទ័ពពំនឹង។ ជាការអស្ចារ្យប្រមាណណាស់ នៅពេលដែលទ័ពទាំងសងខាង កំពុងបាញ់កាប់ចាក់គ្នា ស្រាប់តែឮសូរសន្ទឹក លាន់ករក្រើកទសងក្រឡាប្រថពី ដូចជាសូររន្ទះ ឬ ដូចជាភ្នំរលំមកលើទ័ពចៅហ្វាកៅ នឹងហាក់បីដូចជាមាន ទ័ពជាច្រើនកងទៀត មកព័ទ្ធក្រោយខ្នង នាំឱ្យទ័ពចក្រីកែវ ក៏ផ្អើលវឹកវរ ជាន់ជល់ដួលអស់សេនាទាហាន រត់យកតែអាយុជីវិត គ្រប់ខ្លួនទីទៃៗគ្នា នាំឱ្យបែកទ័ព។ ពញាកែវ និង ពញាសុខ កូនខ្មោចតាមឿង ក៏បញ្ជាឱ្យរេហ៍ពលឱ្យចូលចោមកងទ័ពចក្រីកែវ។ ពញាកែវ ជាកូនតាមឿង ដេញទាន់ចក្រីកែវ ក៏ឱ្យហ្គដំរីខ្លួន បរទៅជិតដំរីជំនិះមេទ័ពខ្មាំង នាំឱ្យដំរីនោះភ្ញាក់ផ្អើល បោលគេចពេញទំហឹង បណ្តាលឱ្យចក្រីកែវធ្លាក់ខ្លួនទៅលើភ្លុងដំរី ជាជំនិះ ពញាកែវ ជាកូនតាមឿង។ ឃើញដូច្នេះ កូនតាមឿង ក៏កាប់ពញាចក្រីកែវ ដាច់ក ស្លាប់មួយរំពេច។ រេហ៍ពលខាងពញាចក្រីកែវ ឃើញមេទ័ពខ្លួនស្លាប់ហើយ មិនហ៊ានទល់ទៅទៀត ក៏បែកទ័ព រត់ខ្ចាត់ខ្ចាយទៅទីទៃៗអស់។ ទ័ព កូនតាមឿង ចាប់បានដំរី សេះ គោ ក្របី ស្បៀងអាហារ សស្ត្រាវុធ របស់ទ័ពខ្មាំងជាច្រើន។ ព្រះចន្ទរាជា ទ្រង់ឱ្យដោតក្បាល ចៅបញ្ញាចក្រីកែវ នៅទីកន្លែងសាធារណៈ រួចព្រះអង្គ ក៏យាងមកគង់នៅស្រុកក្រគរ។ ទ្រង់ឱ្យតាំងបន្ទាយសឹក និង តាំងចៅហ្វាយស្រុកថ្មី។ បន្ទាប់មក ទ្រង់

យាងទៅស្រុកក្រង លើលទ័ពរំលង ទៅដល់ខែត្រខ្លុង។ នៅទីនោះ ទ្រង់ ឱ្យតាំងបន្ទាយមួយទៀត និង តែងតាំងចៅហ្វាយស្រុកថ្មី សំរាប់រក្សាខែត្រ។ នៅទីនោះ ទ្រង់ទៅថ្វាយបង្គំព្រះពុទ្ធរូប នៅព្រះវិហារប្របភូមិប្រាសាទ រួចទ្រង់អធិស្ឋានបន់ឱ្យបានឈ្នះសង្គ្រាម។ ហេតុនេះហើយ បានជាជាប់ពាក្យហៅវត្តនោះថា « វត្តព្រះជីវល្អងបន់ » នៅខែត្រខ្លុង រៀងមកដល់សព្វថ្ងៃ។ បន្ទាប់មកទៀត ព្រះចន្ទរាជា លើកទ័ពចេញពីខែត្រខ្លុង ទៅខែត្រអម្រិន្ទបូរ (អមរគិរិន្ទបូរ)។ មកដល់ទីនោះ អស់រាស្ត្រប្រជា នាំគ្នាមកថ្វាយបង្គំព្រះចន្ទរាជា។ ឃើញដូច្នោះ ចៅហ្វាយខែត្រ ក៏នាំគ្រួសាររត់ទៅខែត្ររលាប្អៀរ។ ព្រះចន្ទរាជា ទ្រង់ឱ្យជួសជុលបន្ទាយបុរាណ តែក្រោយមក ទ្រង់ឱ្យបោះបង់បន្ទាយចាស់នោះ មកតាំងបន្ទាយថ្មីនៅឯត្បូងចុងខែត្រអម្រិន្ទបូរ លើស្ថានដីមួយអន្លី ដែលមានទីរាបស្មើល្អ ជាទីឧត្តមជំទូលាយមាំមួន។ ហេតុនេះ បានជាមានពាក្យអ្នកស្រុក ហៅបន្ទាយដែលបោះបង់នោះថា « បន្ទាយចាស់ » រៀងមក។ ក្នុងពេលដែលព្រះចន្ទរាជា យាងគង់នៅបន្ទាយថ្មីនោះ មានចៅអធិការមួយ ព្រះនាម ជ័យ ងារជា មង្គលសត្ថា។ ព្រះថេរៈអង្គនេះ នាំទូក-ងមួយ ជាដង្វាយមកថ្វាយ ហើយទូលប្រាប់ថា : សូមថ្វាយព្រពរ ទូក-ងនេះ ឈ្មោះ សារាយអណ្តែត កាលចុងផែនដី នៃព្រះបាទស្រីសុគ្នធបទ បរមពិត្រ

ជាសម្តេចព្រះរៀម នៃទ្រង់ ដែលកើតចលាចល ព្រោះស្តេចកនសព្វថ្ងៃនេះ អាចក្តី[57] បានលាក់ទុកឈើ ដែលធ្វើទូកពុំទាន់ហើយនោះ ទុកចោល នៅវាលមួយ ឆ្ងាយពីព្រៃចម្ងាយ ៦សិនប្លាយ។ ដល់ត្រូវខែប្រាំរាំងរឹះ ត្រូវក្តៅ មានហ្វូងដំរីព្រៃ ទៅបោចសារាយត្រឹបបឿន យកមកគ្របឈើ ដែលធ្វើទូកនេះ មិនឱ្យត្រូវថ្ងៃ ក្រែងប្រេះឆា។ លុះស្រុកសាន្តត្រាណបន្តិចទៅ អាចក្តី ក៏នាំសិស្សានុសិស្ស ទៅកាប់ចាំឈើនោះ ធ្វើទូក-ង។ លុះយកទូកមកនេះអកអុំទៅ អាចក្តី ក៏ឃើងថា ទូកនេះលឿនជាងទូកទាំងពួង។ ហេតុនេះហើយ បានជាអាចក្តី ឱ្យឈ្មោះទូកនេះថា « សារាយអណ្តែត »។ មួយទៀត កាលពីខែវស្សា អាចក្តី ជិះទូកនេះ ទៅបិណ្ឌបាត ឯស្រុកមហានគរ, អាចក្តី ត្រឡប់មកវិញទាន់ពេលឆាន់ ហើយចង្ហាន់ក៏នៅហុយៗ។ ហេតុនេះហើយបានជាមានពាក្យហៅថា « ទូកចង្ហាន់ហុយ »។ អាចក្តី យល់ថាទូក-ងនេះ លឿនលឿសចម្លែកទូងទាំងពួង ជារបស់អស្ចា

---

57 សម័យបុរាណ លោកសង្ឃ ប្រើសព្វនាម ជាជំនួនាមព្រះអង្គលោកថា អាចក្តី មិនថា អាត្មា ឬ អាត្មាភាព ដូចសម័យបច្ចុប្បន្ននេះទេ។

រក្លុងព្រះនគរបានជាអាចក្តីនាំមកថ្វាយព្រះមហាបពិត្រ។ ព្រះចន្ទរាជា ទ្រង់ជ្រាបហើយ ទ្រង់មានព្រះអំណរណាស់ ទ្រង់ថ្វាយអភិវន្ទកម្ម ហើយត្រាស់ថា : ព្រះជីតុន[58] ឱ្យទូក នេះ មកញោមៗមានអំណរណាស់ តែសព្វថ្ងៃញោមនៅទ័លពេក។ បើទៅថ្ងៃមុខ ញោមបានព្រះនគរមកកាលណា ញោមនឹងតបស្នងព្រះគុណឱគាប់ព្រះទ័យពុំខានឡើយ។

រួចទ្រង់ត្រាស់ ឱ្យធ្វើរោងដាក់រក្សាទូកទិព្វនេះ ហើយទ្រង់តាំងនាមទូកនោះជា «ព្រះទីនាំងចក្រព័ត្រ»។ បន្ទាប់មក ព្រះចន្ទរាជា ធ្វើដំណើរទ័ព ទៅដល់វាលសាបអង្គាម (ភូមិនេះនៅខាងលិខកំពង់ឆ្នាំ)។ នៅទីនោះ ទ័ពស្តេចពេញត្រកូល ជួបប្រទះនឹងទ័ពចៅហ្វាកៅ ជាមាស្តេចកន ទ្រង់ ក៏បញ្ជា ឱ្យទ័ពចូលច្បាំងតតត្រូញរា។ ទ័ពទាំងសងខាង បាញ់កាប់ចាក់គ្នាជាកោលាហល។ ខណៈនោះ មានដំរីមួយ ខាងកងទ័ពស្តេចកន វាផ្អើលរត់ទៅដល់ព្រៃចដំបូកមួយ រលើងរលំដើមឈើ រមៀលទៅលើទ័ពខ្លួនឯង បែកទាំង

---

58 ពាក្យសំរាប់គ្រហស្ថហៅអ្នកបួស ដែលជាញាតិ ឬ ដែលខ្លួនស្និតស្នាលដោយបានផ្គត់ផ្គង់ចតុប្បច្ច័យដល់លោក។ នៅសម័យបុរាណ ព្រះមហាក្សត្រខ្មែរ ទ្រង់ហៅព្រះថេរធំៗថា ជីតុន យ៉ាងនេះឯង។

សំបុកឧម៉ាល់ ព្រលួតល័ខ ហើយហើរទៅទិចកងទ័ពចៅហ្វាកៅទៀត។ រហ៏ពលទាំងនោះ ទ្រាំនឹងឧម៉ាល់ ព្រលួតល័ខ[59] ពុំបាន ក៏រត់ខ្ចាត់ខ្ចាយបែកទ័ពទៅ។ តែកងទ័ពព្រះចន្ទរាជាដេញតាមកិតពីក្រោយ។ ព្រះចន្ទរាជា ដេញទាន់ចៅហ្វាកៅ ក៏ចូលកាប់នរះនោះត្រូវស្នា។ ឃើញមេទ័ពខ្លួន មានរបួសជាទម្ងន់ សេនាទាហាន ចៅហ្វាកៅ ក៏ជួយការពារ នាំគាត់រត់ចេញពីសមរភូមិ ឆ្លងទន្លេទៅទិសខាងកើតបាន។ ជ័យជំនះថ្មីនេះ ទ័ពស្តេចពេញត្រកូល ប្រមូលបានស្បៀងអាហារ និង សាស្ត្រាវុធជាច្រើន ដែលស្តូរូបបោះបង់ចោល។ មិនឱ្យខាតពេលវេលា ព្រះចន្ទរាជា ក៏បន្តលើកទ័ពទៅវាយបន្ទាយខ្មាំងនៅភូមិរលាប្អៀ (ខែត្រកំពុងឆ្នាំសព្វថ្ងៃ)។ ដឹងដំណឹងថា ទ័ពព្រះចន្ទរាជា កាន់តែកង្ខើញចូលជិតណាស់ហើយ រាស្ត្រប្រជា ក៏នាំគ្នារត់គេចពីកំណែតចៅហ្វាយស្រុករលាប្អៀ ឈ្មោះសោម ខាងកងទ័ពស្តេចកន នាំគ្នាទៅសូនជ្រកកោនខាងទ័ពស្តេចពេញត្រកូល។ ពញាសោម ដឹងថារាស្ត្រប្រជា បែរទៅគាំទ្រទ័ពសត្រូវ ក៏នាំគ្រប់គ្រួរ ដឹកកូនជ

59 ព្រលួតល័ខ ឬ ប្រលួតលាក់ : ខ្មៅនិហក្រហមអង្គន់ៗឆ្លាស់គ្នា។ ឈ្មោះឧម៉ាល់មួយប្រភេទសម្បុរប្រលួតលាក់។

ញូនថៅ រត់តាមថៅហ្វាកៅ តែរត់ពុំទាន់ ក៏នាំគ្នាទៅជ្រក ក្នុងបន្ទាយភ្នំពេញ ហើយស្លាប់នៅទីនោះ[60]។ ព្រះចន្ទរាជា យាងចូលបន្ទាយរលាប្អៀ ដោយមិនបាច់ច្បាំងនឹងសត្រូវ។ ព្រះអង្គ តែងតាំង ហ្លួងរាជា ភឹម ឱ្យធ្វើជាថៅហ្វាយស្រុក ជំនួស បញ្ញាសោម។ ចំណែក ថៅហ្វាយស្រុកលង្វែក ខាង ស្តេចកន ដឹងថា ទ័ពព្រះចន្ទរាជា មានជ័យជំនះគ្រប់សមរ ភូមិ ក៏នាំរាស្ត្រប្រជា និង ពួកអ្នករាជាខែត្រ ចូលថ្វាយបង្គំ ស្តេចពេញត្រកូល ហើយថ្វាយខ្លួនចូលបំរើលុះក្ស័យជីវិត។

ស្តេចកន លុះជ្រាបថា ទ័ពព្រះចន្ទរាជា វាយយកខែត្រខាង លិច ប៉ែងខាងជើងបានហើយ ព្រមទាំងសម្លាប់ចក្រីកែវ និង ធ្វើឱ្យមានរបួសជាទម្ងន់ដល់ថៅហ្វាកៅ ជាមាទៀត ថែមទៀត នាំឱលោកមានទុក្ខទោមនស្សណាស់ រហូតដល់ ដល់ទៅយំរហាមសោកស្តាយជាខ្លាំង។ លុះស្វាងសោកហើយ ស្តេចកន ក៏បញ្ជាមុខមន្ត្រី ឱ្យចេញទៅកេណ្ឌទ័ពនៅត្រើយ ខាងកើតបានចំនួន ១២សែននាក់។ បន្ទាប់មក ស្តេចក

---

60 ពញាសោមម ប្រហែលត្រូវមេទ័ពនៅបន្ទាយភ្នំពេញ សម្លាប់ ចោលព្រោះរត់ចោលបន្ទាយ មិនព្រមចេញច្បាំងនឹងទ័ពព្រះចន្ទ រាជា។

ន ចាត់បម្រើសេះ ឱ្យទៅតាមកងទ័ព ចៅពញាឧទ័យធិរាជា ជាចៅហ្វាយស្រុកខែត្រអាសន្ទទុក ដែលកំពុងនាំទ័ព ៥ម៉ឺននាក់ ទៅខេត្តបាត់ដំបង ដើម្បីព័ន្ធទ័ពព្រះចន្ទរាជាពីខាងក្រោយ ឱ្យវិលត្រឡប់មកបន្ទាយភ្នំពេញ។ ចៅបញាតេជោកុយ ចៅហ្វាយស្រុកខែត្រសំរោងទង និង ចៅបញាវង្សាអនុជិតយស ចៅហ្វាយស្រុកខែត្របាទី ត្រូវស្តេចកនតាំងជាមេទ័ពក្រវែល មានចំនួន ១ម៉ឺននាក់ សំរាប់ការពារបន្ទាយភ្នំពេញ។ ផែនការយុទ្ធសាស្ត្រ របស់ស្តេចកនមានដូចតទៅ។ កងទ័ពទី១ មាន :

១. ចៅពញាយមរាជ ព្រាប យុំពល ១ម៉ឺននាក់ ជាទ័ពមុខ,

២. ចៅពញាវង្សាអគ្គរាជា ស្រី យុំពល ១ម៉ឺននាក់ ជាប៉ែងឆ្វេង,

៣. ចៅពញាពិស្ណុលោក ទេន ចៅហ្វាយស្រុកទ្រាំង យុំញពល ១ម៉ឺននាក់ ជាប៉ែលស្តាំ,

៤. ចៅពញាអធិករវង្សា វេត ចៅហ្វាយស្រុក ខែត្របាសាក់ យុំពល ១ម៉ឺននាក់ ជាប៉ែកក្រោយ,

៥. ឧកហ្លួង សួរ ត្រូវជាមាម៉ែបាន តាំងឡើងជា ចៅពញាចក្រីធិបតីកុញ្ជរ ជាមហាក្របត្រសឹក ដឹកនាំទ័ពស្រួច។

កងទ័ពទី២ ស្តេចកន តែងតាំងក្ជួយម៉ែបាន ៤នាក់ ជាមេទ័ព :

១. ឧកលួង សួរ ជាឧកញ៉ាវៀង ឃុំពល ២ម៉ឺននាក់ ជាទ័ពមុខ,

២. ឧកលួង នៅ ជា ឧកញ៉ាវាំង ឃុំពល ១ម៉ឺន៥ពាន់នាក់ ជាទ័ពឆ្វេង,

៣. ឧកលួង ទេព ជាឧកញ៉ាលំពាំង ឃុំពល ១ម៉ឺន៥ពាន់នាក់ ជាទ័ពស្តាំ,

៤. ឧកលួង មាន់ ជាឧកញ៉ាស្រាល ឃុំពល ១ម៉ឺន៥ពាន់នាក់ ជាទ័ពក្រោយ។

ទ័ពទាំងបួន មានទង់ជ័យទ័ពពណ៌ និង រូបខុសៗគ្នា ដើម្បីមិនឱ្យច្រឡូកច្រឡំគ្នាឡើយ។

ចំណែក ស្តេចកន ខ្លួនឯង ដឹកនាំទ័ព ចំនួន ៣ម៉ឺននាក់ ជាទ័ពលួង ហើយ មានទ័ពក្រវែល ១៥កង ដឹកនាំដោយពួកចៅហ្វាយស្រុក ជាបាឡាត់ និង ជាយោក្បាត់ទ័ព ដើម្បីពង្រឹងរបៀបរៀបពល។

សេនា សេនីយ៍ ដែលស្តេចកនចាត់ហើយនោះ បានមកគ្រប់មុខងារ គឺអ្នកកាន់ស្វេតច្ឆ័ត្រអភិរម្យសែនត្វាន់ ចាម៉ឺរ បាយមន តួរ្យតន្ត្រី តាមលំដាប់ព្រះមហាក្សត្រ។ លុះដល់ពេលមានដោកេជ័យបើកហើយ បុរោហិតផ្លុំត្រែស័ង្ខ ពួកតូរ្យតន្ត្រី ក៏ប្រគំ នូវរគាំស្គរស្នែង ដែលតាក់តែងសម្រាប់បង្គាប់ទ័ព។ ស្តេចកន ជាម្ចាស់ផែនដី ស្រឡប់ពីជ័យ

ព្រៃនគរ លោកឡើងគង់ ព្រះទីនាំ ព្រះគជេន្ទ្រយារុជ កំពស់ ១០ហត្ថ ៤ធ្នាប់ មានកម្លាំងបោលក្នុងមួយថ្ងៃកំណត់ ២.០៥០សិន ហែលទឹកលឿនបីដូចរន្ទះ ឈ្មោះ « ព្រះទីនាំងស័ង្ខរង្សី » លើករេហ៍ពល ចេញទៅសួរស័ព្ទរេហ៍ពល និង សួរស័ព្ទ រទេះ សេះ ដំរី ព្រមទាំងសួរស័ព្ទគួរ្យតន្ត្រីនោះ នាំឱ្យព្យុហៈយាត្រាកងទ័ព ជាឧត្តម រងំ ខ្ទរខ្ទារ ទាំងព្រៃព្រឹក្សាក្រឡាមហាប្រថពី។ លុះទៅដល់ស្ទឹងក្រាំងពន្លៃ (សព្វថ្ងៃនៅក្នុងខែត្រកំពង់ស្ពឺ ក្បែរផ្សារខដុង្គ) ក៏តាំងបន្ទាយទ័ពធំជាបន្ទាប់បង្គាប់អស់កងទ័ព។ បន្ទាប់មក ស្តេចកន បញ្ជាឱ្យ ចៅពញាយមរាជ ព្រាប ដែលជាមេទ័ពមុខ នៃកងទ័ពទី១ លើកទ័ពទៅចោមវាគបន្ទាយលង្វែក។ ទ័ពស្តេចពេញត្រកូល ក៏ចេញទ័ពមកតតាំងច្បាំងគ្នាសែនមហាសាហាវ។ ព្រះចន្ទរាជា ជ្រាបថា សត្រូវចោមបន្ទាយលង្វែក ក៏ប្រញាប់ប្រើទ័ពសេះ ឱ្យទៅប្រាប់ចៅហ្វាយខែត្រលង្វែកថា ឱ្យក្លែងធ្វើជាចាញ់ ហើយ រត់តាមផ្លូវទៅទិសខាងជើង។ ក្រោយបម្រើសេះ ចេញទៅនោះ ទ្រង់លើកទ័ព ចំនួន ៤ម៉ឺន៥ពាន់នាក់ ស្រូតរូតទៅតាំងទ័ពនៅក្នុព្រៃធំ ដើម្បីធ្វើការវាយឆ្មក់ទ័ពសត្រូវនៅពេលដែលកំពុងដេញតាមទ័ព ចៅហ្វាយខែត្រលង្វែក។ ដូចការគ្រងទុកមែន នៅពេលឃើញទ័ពបន្ទាយលង្វែក ថាយទ័ព រត់ទៅទិសខាងជើង ចៅពញាព្រាប មេទ័ពស្តេចកន នឹកថា មានជ័យជំនះ

ហើយ មានចិត្តកម្រើក ក៏បញ្ជាឱ្យទ័ពខ្លួនដេញជិតប្រកិត តាមទ័ពបន្ទាយលង្វែក តែមកដល់កន្លែងទ័ពព្រះចន្ទរាជា ទ្រង់ ក៏បញ្ជាឱ្យទ័ព ចេញវាយទ័ពសត្រូវពុំដឹងខ្លួនពីក្រោយ។ ទ័ពសត្រូវ ស្លាប់ដោយក្របីវថ ដំរីជលព្រេច និង ដោយត្រូវអាវុធវែងខ្លី អស់ប្រមាណ ៣ពាន់នាក់ ឈាមក្រហម ដាលច្រាលទាំងព្រៃវាល ព្រមទាំង ចាប់បាន ចៅពញាព្រាប និង នាយកងទ័ព ១០នាក់។ ព្រះចន្ទរាជា ទ្រង់ត្រាស់ឱ្យកាត់ក្បាល ពញាយមរាជព្រាប និង នាយកងទ័ព ១០នាក់នោះ ហើយ ឱ្យចៀរត្រចៀក មេកងសត្រូវ ១០នាក់ទៀត ហើយទ្រង់ត្រាស់ថា : អាឯង ១០នាក់នេះ ចូរនាំក្បាលទាំង ១១នាក់នេះ ទៅឱ្យអាព្រះស្តេចកន ចុះ ហើយប្រាប់ថា បើវាអាងពលច្រើន ឱ្យលើកមកទៀត ឬបើយល់ថាភ្លៀងធ្លាក់មកហើយ ជិតរដូវល្មមនឹងឱ្យរាស្ត្រធ្វើស្រែចំការហើយ នឹងឈប់ច្បាំងឱ្យរាស្ត្រធ្វើស្រែចំការសិន ក៏តាមចិត្តវាចុះ។

ស្តេចកន យល់ព្រមតាមសំណើរ របស់ព្រះចន្ទរាជា ហើយឱ្យមន្ត្រីទូតបីនាក់នាំពានមាសមួយ តម្កល់ព្រះរាជសារ និង ព្រៃផ្កាមាស ១០គី, ព្រៃញ៉ូរ ២០, ព្រាំយ៉ាងធំ ២ក្បាលជាគ្រឿងបណ្ណាការ ទៅថ្វាយស្តេចជាសត្រូវនឹងខ្លួន។ នៅក្នុងសារនោះមានសេចក្តីដូចខាងក្រោមនេះ :

« ដ្បិតអ្នកអូនលើកចតុរង្គសេនាទាហាន មកធ្វើសង្គ្រាមនេះ យើងមានចិត្តអំណរណាស់ ដោយហេតុថា យើងនឹងបានទត នូវសេនាទាហាន ច្បាំងប្រកាប់គ្នា ដោយអាវុធវែង អាវុធខ្លី លើខ្នងសេះ ដំរី ជាសិរីសួស្តី នៃចក្ខុទាំងសងខាង។ ប៉ុន្តែឥឡូវនេះ ជិតដល់វស្សារដូវហើយ ត្រូវរាស្ត្រធ្វើស្រែ, ដូច្នេះ យើងសុំឱ្យឈប់ធ្វើសង្គ្រាមនឹងគ្នា ក្នុងមួយរដូវនេះចុះ តែសុំឱ្យចាំពាក្យដែលសន្មតសញ្ញា កុំឱ្យលបលួចវាយយកខែត្រគ្នា ដូចទ័ពចោរនោះឡើយ។ បើដល់រាស្ត្រធ្វើស្រែចំការរួចហើយ, មុននឹងធ្វើសង្គ្រាមនឹងគ្នាកាលណា ឱ្យមានរាជសារ ចារជាព្រះរាជកំណត់ទៅមក ទើបគួរសម ជាឧត្តមមហាក្សត្រាធិរាជ »។

លុះអាល័ក្ស ថ្លែងព្រះរាជសារចប់ហើយ ព្រះចន្ទរាជា ទ្រង់ពិរោធខ្លាំងណាស់ ទ្រង់ត្រាស់ថា : « អារាជទូតឯង វិលត្រឡប់ទៅប្រាប់ម្ចាស់ឯងថា អញព្រមសម្រាកឱ្យរាស្ត្រធ្វើស្រែហើយ តែថាអញសុំកុំឱ្យម្ចាស់ឯង ហៅអញថា ជាបង ជាប្អូនឡើយ ដ្បិតម្ចាស់ឯងនឹងអញនេះ មានជាតិត្រកូលឆ្ងាយពីគ្នាណាស់ »។ ទ្រង់ត្រាស់ហើយ ទ្រង់ព្រះរាជទានមាសដួងមួយជញ្ជីងសៀម ប្រាក់ដួងពីរជញ្ជីង ដែលបានមកពីក្រុងស្រីអយុធ្យានោះ ហើយប្រទានឱ្យជារង្វាន់រាជទូត ជាគ្រឿងឧបរាជបណ្ណាការ រួចទ្រង់បណ្តេញឱ្យទៅជាប្រញាប់។

---

**និព័ន្ធដោយ ឧប សៅ សង្ហា**
**ឆ្នាំ ២០១៥**

លុះរាជទូតចេញផុតទៅនោះ អស់នាយកងទ័ព យកសេចក្តីក្រាបទូលយោបល់ថា : យុទ្ធសាស្ត្រផ្អាកសង្គ្រាមសិន ដែលកងទ័ពកំពុងឈ្នះឈ្នះ វាហាក់បី ទុកពេលវេលាឱ្យសត្រូវរៀបចំផែនការកលល្បិចថ្មីសំរាប់វាយកងទ័ពយើង។ សត្រូវនៅមានខែត្រច្រើនណាស់ គឺថានៅក្រោមអំណាចគេជាង ១០សួន បានមកយើងមិនទាន់ពេញមួយសួនទេ។ បើសត្រូវឱ្យកេណ្ឌបណ្តារាស្ត្រតាំងពីខែត្រខាងជើង ទល់នឹងស្រុកលាវ, ខាងត្បូងទល់នឹងសមុទ្រ, ខាងកើតទល់នឹងនគរចាម បានមកទាំងអស់ ប្រហែល ១០សែននាក់ ទៅហើយ, ឯខាងយើង យើងវាយទើបបានតែ ៦-៧ ខែត្រ គឺមហានគរ[61], បាត់ដំបង និងខែត្រតូចៗ ១២ ឬ ១៣។ ម្យ៉ាងទៀត ខែត្រនេះ កាលបែកព្រះមហានគរកម្ពុជាហើយ សៀមកៀរគ្រួយកទៅអស់ នៅតែពីរ បីពាន់នាក់តែប៉ុណ្ណោះ បើដូច្នេះ យើងធ្វើដូចម្តេចនឹងទទួលជ័យពីសត្រូវបាន។ ទូលបង្គំយល់ថា យើងរក្សាខ្លួនពិបាកណាស់នៅក្នុងលក្ខខណ្ឌដូច្នោះ។ ព្រះចន្ទរាជា ទ្រង់ត្រាស់តបថា : ការណ៏

[61] ខែត្រមហានគរនេះ ក្រោយពីពញាវាយ ដណ្តើមពីសៀមបានមកវិញ, ទ្រង់ដូរឈ្មោះថា សៀមរាប។

នេះព្រះអង្គបានគិតស្រេចហើយ ព្រោះវាមានប្រយោជន៍ ៧ ប្រការ គឺ :

ទី១. មានសុភាបុរាណថា : « ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ » បើយើងខំតែធ្វើសង្គ្រាម កូនប្រពន្ធរបស់ឈ្មោះដែលមកចុះកំណែននោះ នឹងដាច់ពោះស្លាប់។ បើកូនប្រពន្ធនោះ អត់បាយហើយ វាពុំយកចិត្តទុកដាក់ក្នុងការធ្វើរាជការនឹងយើងឡើយ។

ទី២. យើងបានខេត្តតូចធំ ចំនួន ១២ ឬ ១៣ ខេត្តនេះល្មមទុកជាទីសំណាក់បានហើយ, បើយើងមិនទាន់ឱ្យទៅបញ្ចុះបញ្ចូលខែត្រផ្សេងៗទេ ហើយស្រាប់តែលើកទ័ពទៅវាយគេតែម្តងនោះ នឹងខ្ទេចខ្ទារកាំចិត្ត នៃអាណាប្រជានុរាស្ត្រជាមិនខាន។ លះតែ យើងបញ្ចុះបញ្ចូលចិត្តចៅហ្វាយស្រុក និង បណ្តារាស្ត្រជាមុនសិន ឱ្យចូលចិត្តនឹងយើងដែលជាព្រះរាជត្រកូល ឬ បើគេមិនចូលចិត្តនឹងយើងទេ គេបែរជាចូលចិត្តទៅពួកក្បត់ ដែលតាំងខ្លួនជាស្តេចនោះ ចាំយើងបានចំណាប់កាលណា សុំលើកទ័ពទៅបង្ក្រាបពួកដែលរឹងទទឹងនោះ ធ្វើឱ្យបានសម្រេចការណ៍ ក្នុងកាលខាងក្រោយ។

ទី៣. ខេត្តអាសន្នទុក្ខ ជាខេត្តធំ មានអាណាខែត្រឡើងក៏ច្រើន, ចៅពញាឧទ័យធិរាជប្រាង្គ ជាចៅហ្វាយស្រុក នៃ

ខេត្តនេះ គាត់មានថ្វីដៃ និង តម្រិះប្រាជ្ញាម៉ាំមួនណាស់, ប្រសិនបើ យើងខំធ្វើចម្បាំង រហូតទៅមិនឈប់ ហើយពញ្ញាប្រាង្គ គេលើកទ័ពមកព័ទ្ធឃោះងពីក្រោយ យើងនឹងនៅជាកណ្តាលចំណោមគេ នោះយើងពិបាកនឹងរក្សាខ្លួនណាស់។ ហេតុនេះហើយ បានជាយើងព្រមបង្អង់ច្បាំង ចាំប្រាប់ប្រាម នូវខែត្រធំៗនេះ និង ខែត្រតូចៗ ត្រើយខាងកើត ទិសខាងជើងនោះ ឱ្យបានមកជារបស់យើងសិន។

ទី៤. ខាងព្រះស្តេចកន ដែលវាតាំងខ្លួនជាស្តេចនោះ តែវាចេញច្បាំងកាលណា វាបាំងស្វេតច្ឆ័ត្រ និង ចាម៉រ បាយមន់សែនត្វាន់ តាមទំនៀមព្រះមហាក្សត្រ, ឯខាងយើង ដែលពេញជាព្រះរាជត្រកូលនោះ យើងគ្មានអ្វីសោះ យើងចេញច្បាំងកាលណាឥស្សរិយសយើង ជាទ័ពថោកជាងវា។ នោះយើងឈ្នះប៉ុន្មានដងក្តី ឥស្សរិយសយើងនោះ ក៏នៅតែថោកទាបជាងវា។

ទី៥. កាលដែលបម្រើ នៃស្តេចកន នាំព្រះរាជសារមកហើយទៅវិញនោះ យើងផ្តាំថា បើចង់ឈប់សង្គ្រាម ឱ្យរាស្ត្រធ្វើស្រែ ក៏ឈប់តាមចិត្ត។ បើរាស្ត្រកំពុងមានចិត្តត្រេកអរព្រោះបានទៅមូលកូនប្រពន្ធផង ត្រេកអរនឹងយើងជាដើមគំនិតនេះផង ហើយបើយើងត្រឡប់ជាប្រែសំដីវិញ, រា

ស្ត្រកំពុងបាក់ចិត្តស្រឡាញ់យើងនោះ ក៏នឹងប្រែចិត្តស្អប់យើង ព្រោះយើងមានវាចាពុំទៀងទាត់។

ទី៦. សេនាទាហានខាងយើង មានថ្មីដែក៏ច្រើននាក់ តែយើងពុំបានឱ្យប្រឡងថ្វីដៃ ឱ្យឃើញច្បាស់នៅឡើយ។

ទី៧. ខាងយើងពិតជាព្រះត្រកូលមែន តែទើបតាំងខ្លួនថ្មី ពុំទាន់មានទុកចម្បាំងដល់មួយសោះ គេមានទូកចម្បាំងក៏ច្រើន។ បើគេលើកទ័ពជើងទឹក មកព័ទ្ធថើមយើងកាលណា យើងគ្មានអ្វីតទល់គេឡើយ។ ហេតុនេះហើយ បានជាយើងព្រមតាមស្តេចកនសុំ ដែលវាស្របគំនិត របស់យើង។

ស្តាប់ ការពន្យល់ នៃយុទ្ធសាស្ត្រ របស់ព្រះចន្ទរាជា ចប់សព្វគ្រប់ហើយ ពួកសេនាមន្ត្រី និង សេនាទាហានទាំងប៉ុន្មានបានថ្លែងកោតសរសើរព្រះប្រាជ្ញាញាណ នៃទ្រង់គ្រាប់ៗគ្នា។

បន្ទាប់មក ព្រះចន្ទរាជា តាំង ចៅពញាសួគ៌ាទេព ជាកូនទី៣ របស់តាមឿង ជាចៅហ្វាយស្រុក រលាប្អៀរ និង ខែត្រលង្វែក ហើយព្រះអង្គ លើកទ័ព ទៅប្រថាប់នៅបន្ទាយអមរិន្ទបូរ វិញ (នៅក្នុងខែត្រកំពុងឆ្នាំ)។ រីឯស្តេចកន ក៏លើកទ័ពទៅរស់នៅ ក្រុងស្រឡប់ព្រៃនគរ នៅទិសខាងកើតវិញ។ តែឱ្យកងទ័ព ឈររក្សាខែត្រ ជាប់តាំងពីស្ទឹងក្រាំងពន្លៃ រៀងដល់ខាងត្បូង។

## បន្តនៅពេលខាងមុខ

និព័ន្ធដោយ ឧប សៅ សង្ហា
ឆ្នាំ ២០១៥